សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de droit et des Sciences Economoiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# របៀបតាក់តែងកិច្ចសន្យា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ស្រស់ ឬទ្ធី**

សាស្ត្រាចារ្យណែនាំ
លោក **ម៉ៅ បុណ្ណា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# **សេចក្តីថ្លែងអំណរគុណ**

ការទទួលបានភាពជោគជ័យមួយមិនមែនជារឿងងាយនោះទេ ហើយក៏មិនអាចធ្វើទៅរួចតែម្នាក់ឯងបាននោះ គឺត្រូវមានអ្នកជួយលើកទឹកចិត្ត និងឧបត្ថម្ភគាំទ្រពីអ្នកនៅជុំវិញខ្លួនទើបទទួលបានជោគជ័យ។

យ៉ាងណាមិញ ក្នុងនាមខ្ញុំបាទជានិស្សិតឈ្មោះ **ស្រស់ ឫទ្ធី** និង **លឹម ភក្តិកា** ដែលទើបទទួលបានជោគជ័យក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ អាស្រ័យដោយមានការជួយជ្រោមជ្រែងពីបុគ្គលសំខាន់ៗដែលក្នុងនោះ យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ លោកអ្នកមានគុណយើងទាំងពីរនាក់ដែលមានព្រហ្មវិហារធម៌ចំពោះកូនៗមានបងប្អូនយាយ តា ពូ មីង ជាដើមដែលតែងតែជួយមើលការខុសត្រូវ និងអប់រំណែនាំ ផ្តល់ដំបូន្មានល្អៗ ដល់រូបយើងខ្ញុំ។

ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យារង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ បុគ្គលិកបម្រើការនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំដឹកនាំគ្រប់គ្រងបំពេញការងារ បង្ហាត់បង្រៀន យ៉ាងយកចិត្តទុកដាក់ដើម្បីបណ្តុះបណ្តាលនិស្សិតអោយក្លាយជាធនធានមនុស្សពិតប្រាកប្រកបដោយគុណភាពជួយប្រទេសជាតិប្រកបដោយសុខសន្តិភាព សុវត្ថិភាព យុត្តិធម៌ និងការអភិវឌ្ឍន៍លើគ្រប់វិស័យ។

លោកសាស្ត្រាចារ្យ **ម៉ៅ មុន្នី** ដែលជាសាស្ត្រាចារ្យណែនាំដ៏ល្អមួយរូប ក្នុងការជួយឱ្យសារណារបស់យើងខ្ញុំមានភាពពេញលេញល្អប្រសើរតាមរយៈការខិតខំប្រឹងប្រែងក្នុងការពន្យល់ណែនាំផ្តល់ជាមតិល្អៗ និងការកែតម្រូវរាល់ខ្លឹមសារដែលលើស ឬខ្វះខាតជាដើម ។ ដោយអំណាចនៃគុណបុណ្យដែលពួកយើងបានធ្វើសេចក្តីល្អក៏ដូចជាការខិតខំប្រឹងប្រែងសព្វបែបយ៉ាងមក លើយើងខ្ញុំ។

ដូច្នេះយើងខ្ញុំគ្មានអ្វីជាការតបស្នងសងគុណធំដុំនោះទេ មានតែម្រាមដៃដប់ សូមគោរពជូនពរឱ្យលោកអ្នកមានគុណទាំងអស់គ្នាជួបតែសេចក្តីសុខ សុភមង្គលគ្រប់ពេលវេលា និងជោគជ័យគ្រប់កិច្ចការទាំងអស់កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

សូមស្វាគមន៍មិត្តៗនិស្សិត ប្រិយមិត្តអ្នកអាន អ្នកស្រាវជ្រាវ និងអ្នកដែលចង់ស្វែងយល់ឯកសារ ផ្សេងៗជាទីរាប់អាន យើងខ្ញុំជានិស្សិតរៀននៅសាកលវិទ្យាល័យ ភូមិនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំមានសេក្តីសប្បាយរីករាយណាស់ ចំពោះការដាក់កិច្ចការ ស្រាវជ្រាវសាណាបញ្ចប់ការសិក្សា។ យើងខ្ញុំសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីពង្រីកចំណេះដឹង នឹងបទពិសោធន៍ទៅថ្ងៃក្រោយ។ ហើយយើងខ្ញុំក៏បាន សិក្សាស្រាវជ្រាវ និងសរសេរទុកធ្វើជាសៀវភៅស្នាដៃនេះឡើង។

សៀវភៅនេះ បកស្រាយបញ្ហាមួយចំនួនតូច តាមលទ្ធភាពដែលយើងខ្ញុំធ្លាប់បានសិក្សាស្រាវជ្រាវកន្លងមក និងតាមឯកសារយោងខ្លះៗនៅបណ្ណាល័យ តាមអ៊ីនធឺនេត និងកន្លែងផ្សេងៗ។ យើងខ្ញុំសង្ឃឹមថាសៀវភៅនេះជាមូលដ្ឋានមួយសម្រាប់ការស្រាវជ្រាវបន្ត។

ជាចុងក្រោយយើងខ្ញុំរង់ចាំទទួលការរិះគន់ពីសំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ សាស្ត្រាចារ្យ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយ រាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនា ពាក្យពេចន៍ វគ្គ ឃ្លា វេយ្យាករណ៍ អក្ខរក្រម ដើម្បីជួយកែលំអរឱ្យសៀវភៅនេះកាន់តែល្អ និងមានភាពសុក្រិត។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរដល់ មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ ទទួលបានពរទាំងឡាយបួនប្រការ សម្បត្តិបី អរិយទ្រព្យប្រាំពីរ និងមានសេក្តីសុខ សំណាងល្អគ្រប់ពេលវេលា ជោគជ័យលើការសិក្សា និងជោគជ័យលើគោលបំណងដែលប៉ងគ្រប់ៗគ្នាកុំបីខានឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............................................................ ១

**ជំពូកទី១**

**ការបង្កើតកិច្ចសន្យា**

**ផ្នែកទី១ ៖ សញ្ញាណទូទៅនៃកិច្ចសន្យា** .................................... ៣

**កថាខណ្ឌទី១ និយមន័យ និងប្រភេទនៃកិច្ចសន្យា** ........................... ៣

១. និយមន័យ ............................................................ ៣

២. ប្រភេទនៃកិច្ចសន្យា ..................................................... ៣

២.១. កិច្ចសន្យាផ្ទាត់មាត់ ................................................. ៣

២.២ កិច្ចសន្យាធ្វើដោយលាយលក្ខណ៍អក្សរ ...................................... ៤

២.២.១.កិច្ចសន្យាឯកជន ឬលិខិតឯកជន ........................................ ៤

២.២.២.លិខិតយថាភូត ....................................................... ៥

**កថាខណ្ឌទី២ ៖ សំណើរ** ................................................... ៥

១. និយមន័យ ............................................................ ៥

២. លក្ខខណ្ឌនៃសំណើរ ..................................................... ៥

២.១. គោលបំណងពិតប្រាកដ .................................................. ៥

២.២. លក្ខខណ្ឌច្បាស់លាស់ ................................................... ៦

២.៣. ជូនដំណឹងដល់អ្នកទទួលសំណើរ .......................................... ៦

៣. ប្រភេទនៃសំណើ ........................................................ ៦

៣.១. សំណើរមានកំណត់អំឡុងពេលសម្រាប់ស្ទីការ ................................. ៧

៣.២. សំណើគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ ................................. ៧

៤.បុគ្គលដែលទទួលសំណើ ................................................... ៧

៤.១.បុគ្គលដែលកំណត់ជាក់លាក់ ............................................... ៧

៤.២.បុគ្គលដែលមិនកំណត់ជាក់លាក់ ............................................ ៧

៥.វិធីនៃការធ្វើសំណើ ..................................................... ៨

៦.ការបញ្ចប់សំណើ.........................................................................................................៨
៦.១.ការដកសំណើ ....................................................................................................៨
៦.២.ការបដិសេធសំណើ..............................................................................................៩
៦.៣.សំណើតប ឬបដិសំណើ.........................................................................................៩
៦.៤.កាលៈទេសៈជាក់លាក់មួយ.......................................................................................៩
**កថាខណ្ឌទី៣ ៖ ស្វីការ** .............................................................................................................១០
១.និយមន័យ .................................................................................................................១០
២. លក្ខខណ្ឌ ..................................................................................................................១០
២.១.ស្វីការត្រូវធ្វើឡើងដោយអ្នកទទួលសំណើ......................................................................១០
២.២.ស្វីការត្រូវតែជូនដំណឹងដល់អ្នកស្នើ...............................................................................១០
២.៣. ស្វីការត្រូវតែដូចគ្នាទៅនឹងសំណើ................................................................................១០
២.៤.ស្វីការត្រូវតែធ្វើមុនពេលកំណត់លក់..............................................................................១១
៣. វិធីនៃការធ្វើស្វីការ.......................................................................................................១១

# ជំពូកទី២

# លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌធម្មតា

**ផ្នែកទី១ ៖ លក្ខខណ្ឌគ្រឹះ** ........................................................................................... ១៣
១.១ ការព្រមព្រៀង..........................................................................................................១៣
១.១.១ ការភន់ច្រឡំ...........................................................................................................១៣
១.១.១.១ គោលគំនិត...........................................................................................................១៣
១.១.១.២ ការភន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា...........................................................១៣
១.១.១.៣ ការភាន់ច្រឡំទៅលើចំណុចសំខាន់នៃកិច្ចសន្យា ដែលភាគីយល់ថាសំខាន់ .១៤
១.១.១.៤ ការភាន់ច្រឡំដោយភាគីភាគីទាំងសងខាង............................................................១៤
១.១.១.៥ ការការពារតតិយជន .............................................................................................១៥
១.១.២ ការឆបោក................................................................................................................១៥
១.១.២.១ គោលគំនិត .............................................................................................................១៥
១.១.២.២ ការឆបោករបស់តតិយជន.....................................................................................១៦
១.១.២.៣ ការការពារតតិយជន..............................................................................................១៦

១.១.៣ ពត៌មានមិនពិត..........................................................................................១៦
១.១.៣.១ គោលគំនិត..........................................................................................១៦
១.១.៣.២ ការការពារតតិយជន..........................................................................................១៧
១.១.៤ ការរំលោបបំពានលើស្ថានភាព..........................................................................................១៧
១.១.៤.១ គោលគនិត..........................................................................................១៧
១.១.៤.២ ការការពារតតិយជន..........................................................................................១៨
១.១.៥ ការគម្រាមកំហែង..........................................................................................១៨
១.១.៥.១ គោលគំនិត..........................................................................................១៨
១.១.៥.២ ការការពារតតិយជន..........................................................................................១៩
១.១.៦ ការគេងចំណេញហួសហេតុ..........................................................................................១៩
១.១.៦.១ គោលគំនិត..........................................................................................១៩
១.១.៦.២ ការការពារតតិយជន..........................................................................................២០
១.១.៧ ឋបនីយផ្លូវចិត្ត..........................................................................................២០
១.១.៧.១ គោលគំនិត..........................................................................................២០
១.១.៧.២ ការការពារតតិយជនលើស្ថានភាព..........................................................................................២០
១.១.៨ ការបង្ហាញឆន្ទៈមិនពិត..........................................................................................២១
១.១.៨.១ គោលគំនិត..........................................................................................២១
១.១.៨.២ ការការពារតតិយជន..........................................................................................២២
១.២ សមត្ថភាព..........................................................................................២២
១.២.១ សមត្ថភាពខាងឆន្ទៈ..........................................................................................២២
១.២.១.១ គោលគំនិត..........................................................................................២២
១.២.១.២ អានុភាព..........................................................................................២៣
១.២.២ សមត្ថភាពក្នុងការធ្វើសកម្មភាព..........................................................................................២៣
១.២.២.១ អនីតិជន..........................................................................................២៦
១.២.២.២ ជននៅក្រោមអាណាព្យាបាលទូទៅ..........................................................................................២៧
១.២.២.៣ ជននៅក្រោមហិត្តូបត្ថម្ភ..........................................................................................២៩
១.២.២.៤ ការការពារភាគីម្ខាងទៀត..........................................................................................៣០

១.៣ កម្មវត្ថុ....................................................................................................៣០
១.៣.១ ភាពខុសច្បាប់....................................................................................៣០
១.៣.២ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ ......................៣០
១.៣.៣ អលទ្ធភាពតាំងពីដំបូង...........................................................................៣០
១.៤ តម្លៃតបស្នង...............................................................................................៣១
**ផ្នែកទី២ ៖ លក្ខខណ្ឌទម្រង់**........................................................................ ៣២
២.១ កិច្ចសន្យាធ្វើដោយផ្ទាល់មាត់ .........................................................................៣២
២.១.១ និយមន័យ.................................................................................................៣២
២.១.២ គុណសម្បត្តិមាន .......................................................................................៣២
២.១.៣ គុណវិបត្តិ..................................................................................................៣២
២.២ កិច្ចសន្យាធ្វើឡើងដោយលាយលក្ខណ៍អក្សរ ......................................................៣៣
២.២.១ និយមន័យ ................................................................................................៣៣
២.២.២ គុណសម្បត្តិ..............................................................................................៣៣
២.២.២ គុណវិបត្តិ..................................................................................................៣៤

## ជំពូកទី ៣

## ការអនុវត្តកិច្ចសន្យា

**កថាខណ្ឌទី ១ ៖ ការអនុវត្តកិច្ចសន្យា**...........................................................៣៥
១.១. ករណីកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច....................................................៣៥
១.២. សិទ្ធិទាមទាររបស់ម្ចាស់បំណុលអោយអនុវត្តកាតព្វកិច្ច...............................................៣៥
១.៣. ការតវ៉ាអោយអនុវត្តព្រមគ្នា ..........................................................................................៣៦
**កថាខណ្ឌទី២ ៖ មោឃភាព និងការលុបចោល**.................................................៣៧
១. មោឃភាព..........................................................................................................៣៧
១.១ គោលគំនិត ........................................................................................................៣៧
១.២ អានុភាព.............................................................................................................៣៧
១.៣ មោឃភាពដោយផ្នែក ........................................................................................៣៨
១.៤ បុគ្គលដែលអាចអះអាងលើមោឃភាព...................................................................៣៩

២.ការលុបចោល ........................................................................................................................................ ៣៩
២.១. គោលគំនិត ................................................................................................................................ ៣៩
២.២. អានុភាព................................................................................................................................... ៣៩
២.៣. ជនដែលអាចលុបចោលបាន ..................................................................................................... ៣៩
២.៣.១. ករណីវិការៈក្នុងការបង្ហាញឆន្ទៈ ......................................................................................... ៣៩
២.៣.២. ករណីសមត្ថភាពក្នុងការបង្ហាញឆន្ទៈ .................................................................................. ៤០
២.៤. ការផ្ដល់សច្ចានុមតិ....................................................................................................................... ៤០
២.៤.១. គោលគំនិត ............................................................................................................................ ៤០
២.៤.២. អានុភាព ................................................................................................................................ ៤០
២.៤.៣. ជនដែលអាចធ្វើសច្ចានុមតិ....................................................................................................... ៤០
២.៤.៤. សច្ចានុមតិដែលច្បាប់បានកំណត់............................................................................................. ៤១
២.៤.៤.១. ការអនុវត្តកាតព្វកិច្ច ឬការផ្តល់នូវប្រាតិភោគ ........................................................................ ៤១
២.៤.៤.២. ការអនុវត្តសិទ្ធិ ឬការទាមទារឲ្យអនុវត្តកាតព្វកិច្ច .................................................................. ៤១
២.៤.៤.៣. អនុប្បទាន ឬចាត់ចែងសិទ្ធិ........................................................................................... ៤១
២.៥. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល .................................................................................. ៤១
២.៦. ការប្រៀបធៀបរវាង មោឃភាព និងការលុបចោល ........................................................................ ៤២
**សន្និដ្ឋាន និងអនុសាសន៍**.................................................................................................................... ៤២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ក្រោយពេលបានសន្តិភាព ប្រទេសកម្ពុជាយើងបានក្លាយជាប្រទេស ដែលប្រកាន់យក លទ្ធិប្រជាធិបតេយ្យ ដោយអនុវត្តសេដ្ឋកិច្ចបែបទីផ្សារសេរី ដើម្បីធ្វើការដោះដូរទំនិញ ឬសេវា ដូច្នេះ យើងត្រូវការ ច្បាប់កិច្ចសន្យាសម្រាប់ធ្វើការគ្រប់គ្រងសកម្មភាពទីផ្សារទាំងនេះ។ កិច្ចសន្យា មានសារៈសំខាន់ណាស់ចំពោះសកម្មភាពរបស់ រដ្ឋាភិបាល ក្រុមហ៊ុន និងបុគ្គលក ជាពិសេសកិច្ចសន្យាអាចជួយដល់ការលូតលាស់សេដ្ឋកិច្ចរបស់សង្គម។ មូលហេតុសំខាន់ដែលយើងត្រូវយល់ដឹងពីច្បាប់កិច្ចសន្យា គឺដោយសារតែទំនាក់ទំនងដែលកើតចេញពីមនុស្សក្នុងសង្គមតែងតែមានវិវាទនឹងគ្នា ដូចជាវិវាទដែលកើតឡើង ដោយសារ ការបង្កើតកិច្ចសន្យា ឬការអនុវត្តកិច្ចសន្យាជាដើម។ ដូចនេះ ដើម្បីដោះស្រាយវិវាទដែលមានលក្ខណៈស្មុកស្មាញ យុត្តិធម៌ នឹងប្រសិទ្ធភាព គឺយើត្រូវការច្បាប់កិច្ចសន្យា។

គេត្រូវបង្កើតកិច្ចសន្យាដើម្បីទិញអ្វីៗដែលត្រូវការសំរាប់ដំណើរការមិនថាស្ថាប័នឯកជន ឫរដ្ឋ។ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់ប្រទេសជាតិដូចជា ព្រលានយន្តហោះ ផ្លូវអោយស្ព័យាន និងការធ្វើផ្លូវថ្នាល់។ រដ្ឋាភិបាលធ្វើកិច្ចសន្យាជាមួយរដ្ឋាភិបាលផ្សេងៗ តាមរយៈ សន្ធិសញ្ញា អនុសញ្ញា ដែលពាក់ព័ន្ធនឹង ពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៍ សិទ្ធមនុស្ស បរិស្ថានជាដើម។ ក្រុមហ៊ុន ចាប់ពីអាជីវកម្មខ្នាតតូចរហូតដល់ខ្នាតធំ សុទ្ធតែត្រូវការកិច្ចសន្យាសំរាប់ដំណើរការអាជីវកម្មរបស់ពួកគេ ដូចជា ការទិញវត្ថុធាតុដើម ការលក់ផលិតផលសំរេចជាដើម។ យើងពិបាកនឹងរកឧទាហរណ៍ ដែលក្រុមហ៊ុនអាចដំណើរការអាជីវកម្មដោយមិនប្រើកិច្ចសន្យា នេះដោយហេតុផលថា ក្រុមហ៊ុនត្រូវបានបង្កើតឡើងដើម្បីស្វែងរកប្រាក់ចំណេញ ដូចនេះគេចាំបាច់ត្រូវតែប្រើកិច្ចសន្យាដើម្បីលក់ដូរផលិតផលរបស់គេ។ ចំណែក រូបវន្តបុគ្គល និងនីតិបុគ្គលវិញ ត្រូវការកិច្ចសន្យម្រាប់ជីវភាពរស់នៅរបស់គេដូចជា ទិញអាហារ ជួលផ្ទះ ការដឹកជញ្ជូន ការងារ កំចីប្រាក់ ផ្ញើរឡាន ឬម៉ូតូ ការបញ្ញាំវត្ថុ ការដូរវត្ថុ ការអប់រំ ការថែទាំសុខភាព ការរៀបអាពាហ៍ពិពាហ៍។ល។

ដូច្នេះហើយទើបក្រុមរបស់យើងខ្ញុំជ្រើសរើសប្រធានបទមួយស្តីពី ៖ **របៀបតាក់តែងកិច្ចសន្យា** មកសរសេរជាស្នាដៃនេះឡើង។ ជាទូទៅមនុស្សពិបាកនឹងរស់នៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះណាស់ ប្រសិនបើគេមិនបង្កើតកិច្ចសន្យាចង់គ្នានោះទេ មនុស្សជាច្រើនមិនបានយល់ច្បាប់ពី សារៈសំខាន់របស់កិច្ចសន្យាដោយសារការធ្វើកិច្ចសន្យាមានភាពសាមញ្ញពេក។ ពេលខ្លះអ្នកធ្វើកិច្ចសន្យាមិនបានដឹងថា អ្វីទៅជាកិច្ចសន្យា?

តាមការសិក្សាស្រាវជ្រាវកន្លងមកយើងខ្ញុំនឹងខិតខំប្រឹងប្រែងធ្វើបទបង្ហាញ និងអធិប្បាយឱ្យបានលម្អិត និថមានភាពច្បាស់លាស់ទៅលើចំណុចមួយចំនួនក្នុងនោះរួមមាន៖

**ជំពូកទី១ ៖ ការបង្កើតកិច្ចសន្យា**

**ជំពូកទី២ ៖ លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់**

**ជំពូកទី ៣ ៖ ការអនុវត្តកិច្ចសន្យា**

ចំពោះខ្លឹមសារលម្អិតនៃជំពូកនីមួយៗខាងលើនេះ និងមានការអធិប្បាយបង្ហាញជូនទាងស្រុងនៅក្នុង អត្ថន័យនៃសារណាបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំដូចដែលមានការរៀបរាប់ខាងក្រោមដូចតទៅ៖

# ជំពូកទី១ ៖ ការបង្កើតកិច្ចសន្យា

## ផ្នែកទី១៖ សញ្ញាណទូទៅនៃកិច្ចសន្យា

### កថាខណ្ឌទី១ ៖និយមន័យ និងប្រភេទកិច្ចសន្យា

#### ១.និយមន័យ

កិច្ចសន្យា[1] គឺជាការព្រមព្រៀងរវាងបុគ្គលពីរនាក់ ឬពីរក្រុមដើម្បីបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច។

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមព្រៀងគ្នាបង្កើតកែប្រែ ឬរំលត់កាតព្វកិច្ច។ មាននន័យថា កិច្ចសន្យាត្រូវបានកើតឡើងដោយសារតែឆន្ទៈព្រមព្រៀងគ្នា រវាងបុគ្គលពីរនាក់ ឬច្រើននាក់ ព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចណាមួយដែលសមីខ្លួនបានបង្កើតឡើង។ ពោលគឺភាគីមានចំណង់ចង់បង្កើតកិច្ចសន្យា ហើយកិច្ចសន្យា បានបង្កើតឱ្យមានកាតព្វកិច្ច ត្រូវឱ្យភាគីនៃកិច្ចសន្យា ត្រូវអនុវត្តដោយភាពស្មោះត្រង់តាមអ្វីដែលខ្លួនបានព្រមព្រៀងរួចហើយ។

#### ២.ប្រភេទកិច្ចសន្យា

កិច្ចសន្យាត្រូវបែងចែកជាពីរប្រភេទ គឺ៖

- កិច្ចសន្យាផ្ទាល់មាត់
- កិច្ចសន្យាលាយលក្ខណ៍អក្សរ។

##### ២.១.កិច្ចសន្យាផ្ទាល់មាត់

កិច្ចសន្យាធ្វើឡើងដោយផ្ទាល់មាត់ គឺជាកិច្ចសន្យាដែលធ្វើឡើងដោយការនិយាយរវាងគូរ ភាគីនៃកិច្ចសន្យា ដោយមិនធ្វើជាលាយលក្ខណ៍អក្សរទេ[2]។

<u>**ឧទាហរណ៍៖**</u> **ក** ដែលជាអតិថិជន បាននិយាយទៅ **ខ** ដែលជាអ្នកលក់ថា តើទឹកបរិសុទ្ធមួយដបថ្លៃប៉ុន្មាន? **ខ** បាននិយាយថា មួយដបតម្លៃ ១០០០៛ (មួយពាន់រៀល) ហើយបន្ទាប់មក **ក** ក៏ប្រគល់លុយ ហើយ **ខ** ក៏ប្រគល់ទឹកសុទ្ធ។

##### ២.២.កិច្ចសន្យាធ្វើដោយលាយលក្ខណ៍អក្សរ

[1] មាត្រា៣១១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[2] មាត្រា៣៣៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

កិច្ចសន្យាធ្វើដោយលាយលក្ខណ៍អក្សរ គឺជាកិច្ចសន្យាដែលត្រូវបានសរសេរជាលាយលក្ខណ៍អក្សរដោយគូរភាគីនៃកិច្ចសន្យា។ ជាទូទៅត្រូវមានចុះកាលបរិច្ឆេទ ព្រមទាំងស្នាមមេដៃរបស់ភាគីទាំងពីរនាក់ និងស្នាមមេដៃរបស់សាក្សីផងដែរ។

ការធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ភាគច្រើនប្រើចំពោះកិច្ចសន្យាដែលមានកម្មវត្ថុមានតម្លៃខ្ពស់ ហើយមានប្រភេទកិច្ចសន្យាមួយចំនួន ច្បាប់តម្រូវឲ្យធ្វើជាលាយលក្ខណ៍អក្សរ។

**<u>ឧទាហរណ៍៖</u>** ចំពោះមតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី។

**<u>ឧទាហរណ៍៖</u>** កិច្ចសន្យាគ្រប់ប្រភេទសស្តីពីប្រាក់ ឬវត្ថុដែលមានចំនួន ឬមានតម្លៃ លើសពី ៥០០០រ (ប្រាំពាន់រៀល) ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

កិច្ចសន្យាជាលាយលក្ខណ៍អក្សរ ត្រូវបានបែងចែកជាពីរប្រភេទដូចជា ៖ **លិខិតយថាភូត និងលិខិតឯកជន**។

- លិខិតយថាភូត គឺជាលិខិតធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈ ដែលត្រូវបានប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀត គឺជាលិខិតទាំងឡាយណាដែលរៀបចំឡើងដោយសារការី។
- លិខិតឯកជន គឺជាលិខិតទាំងឡាយណាដែលបង្កើតឡើងដោយបុគ្គលឯកជន ដោយមានហត្ថលេខា ឬស្នាមមេដៃ។

### ២.២.១.កិច្ចសន្យាឯកជន ឬលិខិតឯកជន

កិច្ចសន្យាឯកជន គឺជាកិច្ចសន្យាដែលធ្វើឡើងដោយគូរភាគី តាមការព្រមព្រៀងណាមួយដើម្បីបង្កើតឱ្យមានលក្ខណៈគតិយុត្តតាមច្បាប់។

កិច្ចសន្យាឯកជន គឺជាកិច្ចសន្យាដែលធ្វើឡើងតែគ្នាឯង ឥតមានមន្ត្រីរាជការសាធារណៈណាមួយដឹងឮឃើញផងទេ មានតែហត្ថលេខានៃគូរភាគីតែប៉ុណ្ណោះ។

កិច្ចសន្យាឯកជន គឺគេអាចធ្វើឡើងដោយផ្ទាល់មាត់ និងជាលាយក្ខណ៍អក្សរ។ ច្បាប់អាចកំណត់ឲ្យមានទម្រង់មួយជាក់លាក់ក្នុងការធ្វើកិច្ចសន្យា។

តាមក្រមរដ្ឋប្បវេណីមាត្រា ៥១៧ បានចែងថា កិច្ចសន្យាលក់ទិញ អាចត្រូវបានបង្កើតឡើងដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែ ក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់។ ប៉ុន្តែ ភាគីអាចកំណត់ការធ្វើលិខិតយថាភូត ឬលិខិតឯកជន ជាលក្ខខណ្ឌសម្រាប់ការបង្កើត

កិច្ចសន្យាបាន។ តាមមាត្រានេះ មានន័យថា កិច្ចសន្យាលក់ទិញអាចធ្វើឡើងដោយផ្ទាល់មាត់បាន តែត្រូវធ្វើដោយលិខិតឯកជនបាន លើកលែងតែកិច្ចសន្យាមួយចំនួនដែលច្បាប់បានកំណត់នៅទម្រង់មួយជាក់លាក់ ដូចជាកិច្ចសន្យាលក់អចលនវត្ថុជាដើម ដែលត្រូវធ្វើឡើងតាមទម្រង់ជាលិខិតយថាភូត។

**២.២.២.លិខិតយថាភូត**

លិខិតយថាភូត គឺជាលិខិតដែលធ្វើឡើងដោយសារការី ឬលិខិតឯកជន ដែលសារការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និង ហត្ថលេខាក្រោយបេលខ្លួនបញ្ជាក់ថាលិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់[3]។ ការធ្វើកិច្ចសន្យាតាមលិខិតយថាភូតនោះ គឺដាច់ខាតត្រូវតែមាន មន្ត្រីដែលមានសមត្ថកិច្ចចូលរួមក្នុងការធ្វើ ដូចជាច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៦៥ បានចែងថា « ការផ្ទេរកម្មសិទ្ធិមុនអាចជំទាស់ពីអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី »។ កិច្ចន្យាលក់ឯកជនមិនអាចចាត់ជាការផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិនោះពេញលេញលក្ខណៈច្បាប់បានឡើយ។

**កថាខណ្ឌទី២ ៖ សំណើ**

**១.និយមន័យ**

សំណើ[4] គឺជាការសុំបង្កើតកិច្ចសន្យា ដែលធ្វើឡើងដែលមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្ទីការ របស់ភាគីម្ខាងទៀតចំពោះសំណើនេះ។ សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត។ ប៉ុន្តែប្រសិនបើ ដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើរដល់ ឬមុនពេលសំណើដល់ នោះអានុភាពនៃសំណើមិនត្រូវកើតឡើងឡើយ។

<u>**ឧទាហរណ៍៖**</u> **ក** បាននិយាយថា ប្រសិនបើ **ខ** ចង់បានទូរស័ព្ទរបស់ **ក** នោះ **ខ** ត្រូវអោយប្រាក់ទៅ **ក** ៥០០$ (ប្រាំរយដុល្លារ)។ នេះជាសំណើលក់ទូរស័ព្ទរបស់ **ក** ទៅកាន់ **ខ**។

**២.លក្ខខណ្ឌនៃសំណើ**

**២.១.គោលបំណងពិតប្រាកដ**

ត្រូវកំណត់តាម ពាក្យសំដី ឬអំពើរបស់ភាគីដែលជាមនុស្សប្រកបដោយគតិ ដោយសម្រេចមានហេតុផលត្រឹមត្រូវ។ ប្រសិនបើ អ្នកស្នើធ្វើសំណើដោយការ ភ័យខ្លាច ខឹង លេងសើច បញ្ឆេីចបញ្ឆេី ញុះញង់ សំណើបែបនេះ គឺគ្មានគោលបំណងច្បាស់លាស់ទេ ដែលជាហេតុមិនអាចចាត់ទុកជាសំណើមានប្រសិទ្ធភាពនោះទេ។

[3] មាត្រា ៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
[4] មាត្រា ៣៣៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**<u>ឧទាហរណ៍៖</u> ក** ទើបតែទិញទូរស័ព្ទថ្មីមួយគ្រឿងតម្លៃ ១០០០$ (មួយពាន់ដុល្លារ) ដើម្បីប្រើប្រាស់ តែបានតែប៉ុន្មានថ្ងៃក្រោយមក ពេល **ក** កំពុងប្រើ ស្រាប់តែទូរស័ព្ទនោះគាំងអត់ដំណើរការ ដែលធ្វើឲ្យ **ក** ខឹងយ៉ាងខ្លាំង ហើយស្រែកថា អ្នកណាចង់បានខ្ញុំលក់ ១០០$ (មួយរយដុល្លារ)។ សំណើរបស់ **ក** មិនមានលក្ខខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ទេ ព្រោះ **ក** ធ្វើសំណើនេះដោយកំហឹងដែលមិនបានគិតពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយ។

**២.២.លក្ខខណ្ឌច្បាស់លាស់**

សំណើត្រូវមានខ្លឹមសារ ជាក់លាក់ ច្បាស់លាស់ និងសមហេតុផល នេះមានន័យថា សំណើត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់អំពី ប្រភេទនៃវត្ថុ បរិមាណ តម្លៃ គុណភាព ពេលវេលា ទីកន្លែង ជាដើម។

**<u>ឧទាហរណ៍៖</u> ក** បាននិយាយទៅកាន់ **ខ** ថា ខ្ញុំចង់លក់ម៉ូតូមួយគ្រឿងទៅឱ្យអ្នកដែលមានម៉ាក ហុងដា-សេ ១២៥ ពណ៌ក្រហម ស៊េរីឆ្នាំ ២០១៦ ក្នុងតម្លៃ២០០០$ (ពីរពាន់តម្លៃ)។

**២.៣.ជូនដំណឹងដល់អ្នកទទួលសំណើរ**

សំណើ ត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ដូចនេះអ្នកធ្វើសំណើត្រូវតែបញ្ជូនសំណើ អោយដល់អ្នកទទួលសំណើ តាមគ្រប់មធ្យោបាយ ដែលអ្នកធ្វើសំណើអាចធ្វើទៅបាន។ នៅពេលដែលអ្នកទទួលសំណើមិនបានទទួលសំណើទេ នោះអ្នកទទួលសំណើក៏គ្មានសិទ្ធិដើម្បីធ្វើស្វីការតបនឹងសំណើនោះដែរ នេះមានន័យថា គ្មានកិច្ចសន្យា រវាងអ្នកធ្វើសំណើ និងអ្នកទទួលសំណើទេ។

**<u>ឧទាហរណ៍៖</u>** ប្រសិនបើ **ក** ដាក់សំណើដើម្បីលក់ម៉ូតូ មួយគ្រឿងទៅឲ្យ **ខ** ប៉ុន្តែ **ខ** មិនបានដឹងពីសំណើនេះទេ តែ **ខ** បានប្រាប់ **ក** វិញថា ខ្លួនចង់ទិញម៉ូតូរបស់ **ក**។ ពេលដែល **ខ** ប្រាប់ **ក** ថា ខ្លួនចង់ទិញម៉ូតូរបស់ **ក** មិនមែនជាស្វីការទេ ពីព្រោះគាត់ មិនដឹងពីសំណើរបស់ **ក** នោះទេ តែវាជាសំណើថ្មីមួយទៀតដែលយើងហៅបាតុភូតនេះថាជា សំណើខ្វែង។ ដូចនេះ **ខ** មិនអាចធ្វើស្វីការចំពោះសំណើនោះបានទេ។

**ឧទាហរណ៍៖ ក** បានបាត់គោមួយក្បាល ហើយបានប្រាប់អ្នកភូមិថា ប្រសិនបើអ្នកណារកឃើញគោរបស់គាត់ គាត់នឹងជូនរង្វាន់១០០$ (មួយរយដុល្លារ)។ នៅថ្ងៃបន្ទាប់ **ខ** បានឃើញគោរបស់ **ក** ហើយបានយកមកប្រគល់អោយ **ក** វិញ ដោយគាត់មិនបានដឹងថាមានរង្វាន់នោះទេ ហើយ **ក** ក៏មិនបានឲ្យរង្វាន់ដល់ **ខ** ដែរ។ ថ្ងៃបន្ទាប់ **ខ** បានដឹងពីរង្វាន់នោះ ហើយក៏មកទាមទាររង្វាន់ពី **ក** វិញ។ ដូចនេះ **ខ** មិនអាចទាមទាររង្វាន់បានទេ ព្រោះគ្មានកិច្ចសន្យា រវាង **ក** និង **ខ** កើតមានឡើយ ។

**៣.ប្រភេទនៃសំណើ**

ប្រភេទនៃសំណើត្រូវបែងចែកជាពីរប្រភេទគឺ ៖

- សំណើមានកំណត់អំឡុងពេលសម្រាប់ស្ទីការ
- សំណើគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ។

**៣.១. សំណើរមានកំណត់អំឡុងពេលសម្រាប់ស្ទីការ**

សំណើមានកំណត់អំឡុងពេលសម្រាប់ស្ទីការ គឺជាប្រភេទសំណើមួយបែបដែលអ្នកធ្វើសំណើ បាន កំណត់អំឡុងពេលជាក់លាក់មួយសម្រាប់អ្នកទទួលសំណើដើម្បីធ្វើស្ទីការ។ ស្ទីការត្រូវគិតចាប់ពីថ្ងៃដែលជូល ដំណឹងអំពីសំណើ បើមិនច្បាស់ថាអ្នកស្នើកំណត់ពេលផ្សេង[5]។

**<u>ឧទាហរណ៍៖</u> ក** បានប្រាប់ **ខ** ថាគាត់ចង់លក់ម៉ូតូរបស់គាត់ម៉ាក ហុងដាសេ ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ ២០១៦ ឲ្យ **ខ** ដើម្បីទិញម៉ូតូថ្មី ដោយទុករយៈពេលឲ្យ **ខ** ចំនួន ៥ថ្ងៃ។

**៣.២. សំណើគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ**

សំណើគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ គឺជាប្រភេទនៃសំណើមួយបែបដែលអ្នកធ្វើសំណើ មិន បានកំណត់អំឡុងពេលជាក់លាក់មួយសម្រាប់ទទួលសំណើដើម្បីធ្វើស្ទីការទេ។

**<u>ឧទាហរណ៍៖</u> ក** បានប្រាប់ **ខ** ថាគាត់ចង់លក់ម៉ូតូរបស់គាត់ម៉ាក ហុងដា ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ ២០១៦ ឱ្យ **ខ** ដើម្បីទិញម៉ូតូថ្មី។

**៤.បុគ្គលដែលទទួលសំណើ**

**៤.១.បុគ្គលដែលកំណត់ជាក់លាក់**

បុគ្គលដែលកំណត់ជាក់លាក់ សំដៅលើបុគ្គលដែល អ្នកធ្វើសំណើស្គាល់យ៉ាងច្បាស់ ហើយអ្នកធ្វើ សំណើ មានបំណងចង់ធ្វើសំណើចំពោះបុគ្គលនោះតែម្តង។

**<u>ឧទាហរណ៍៖</u> ក** បានប្រាប់ **ខ** ថាគាត់ចង់លក់កុំព្យូទ័រដែលគាត់កំពុងប្រើនេះឱ្យ **ខ** ក្នុងតម្លៃ ១០០$ (មួយរយដុល្លារ) ។ ដូចនេះបុគ្គលដែលបានកំណត់ជាក់លាក់គឺជា **ខ**។

**៤.២.បុគ្គលដែលមិនកំណត់ជាក់លាក់**

បុគ្គលដែលមិនកំណត់ជាក់លាក់ សំដៅទៅលើបុគ្គលដែលអ្នកធ្វើសំណើមិនបានបញ្ជាក់នៅពេល ដែលគាត់បានធ្វើសំណើ បុគ្គលណាក៏អាចធ្វើស្ទីការបានដែរ ឬ យើងអាចនិយាយបានថា បុគ្គលដែលមិនបាន កំណត់ជាក់លាក់ គឺជាសាធារណៈជន។

[5] មាត្រា ៣៣៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**<u>ឧទាហរណ៍</u>៖ ក** បានប្រកាសលក់ទូរស័ព្ទរបស់ខ្លួនម៉ាក IPhone6 ពណ៌ខ្មៅមួយគ្រឿង តម្លៃ៧០០$ (ប្រាំពីររយដុល្លារ) តាមរយៈ Internet។ ក្នុងករណីនេះ ក មិនបានបញ្ជាក់ពីអ្នកដែលត្រូវធ្វើស្វីការទេ (អ្នកទិញ) ដូចនេះ អ្នកណាក៏អាចទិញទូរស័ព្ទរបស់ **ក** បានដែរ។

**៥.វិធីនៃការធ្វើសំណើ**

សំណើអាចត្រូវបានធ្វើឡើងតាមរយៈវិធីជាច្រើនដូចជា ៖

- ផ្ទាល់មាត់
- លាយលក្ខណ៍អក្សរ
- អាកប្បកិរិយា
- ប្រព័ន្ធទំនាក់ទំនងសង្គម ទូរស័ព្ទ ទូរសារ Email ហ្វេសប៊ុក ជាដើម។

**៦.ការបញ្ចប់សំណើ**

**៦.១.ការដកសំណើ**

សំណើដែលត្រូវបានធ្វើឡើងដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ មិនអាចដកបានទេ[6]។ ការកំណត់អំឡុងពេលនេះ គឺចង់ទុកពេលឲ្យអ្នកទទួលសំណើធ្វើការពិចារណា តើទទួលយកសំណើនេះ ឬមិនទទួលយក ម៉្យាងវិញទៀត ការកំណត់អំឡុងពេលសម្រាប់ស្វីការគឺដើម្បីបញ្ជាក់អំពី ឆន្ទៈរបស់អ្នកស្នើក្នុងការរង់ចាំអំឡុងពេលសម្រាប់ស្វីការ។

ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្វីការ ក្នុងអំឡុងពេលដែលបានកំណត់ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិនៅពេលផុតអំឡុងពេលសម្រាប់ស្វីការ។

សំណើដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ រវាងគូរភាគីដែលកំពុងនិយាយគ្នានៅក្នុងស្ថានភាពដែលអាចឆ្លើយភ្លាមៗបាន ។ ប្រសិនបើភាគីដែលទទួលសំណើ មិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព។

**<u>ឧទាហរណ៍</u>៖ ក** បាននិយាយទៅកាន់ **ខ** ថាខ្លួនចង់លក់ អង្ករ ឱ្យទៅ **ខ** ១០០គីឡូក្រាម ក្នុងមួយគីឡូតម្លៃ ៤៥០០៛ (បួនពាន់ប្រាំរយរៀល) តែ **ខ** មិនបានឆ្លើយតបទេ។ ករណីនេះ **ក** អាចដកសំណើរបស់ខ្លួនបាន។

ចំពោះសំណើដែលធ្វើរវាងគូរភាគីដែលមិននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ។ អំឡុងពេលសមរម្យ សំដៅទៅលើ

[6] មាត្រា ៣៣៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អំឡុងពេលមួយដែលចាំបាច់សម្រាប់ការវិនិច្ឆ័យថា តើទទួលយកសំណើ ឬអត់។ រយៈពេលនេះ អាស្រ័យទៅតាមខ្លឹមសារ និងប្រភេទកិច្ចសន្យា។

**ឧទាហរណ៍៖** ប្រសិនបើចំនួនទឹកប្រាក់ក្នុងកិច្ចសន្យាមានចំនួនច្រើន ឬប្រសិនបើកម្មវត្ថុនៃកិច្ចសន្យាគឺជាវត្ថុមានតម្លៃ ដូចជាអចលនវត្ថុ អំឡុងពេលសមរម្យនោះប្រហែលជាមានរយៈពេលវែង តែប្រសិនបើកិច្ចសន្យាសាមញ្ញធម្មតាអំឡុងពេលសមរម្យនោះមានរយៈពេលខ្លី។

ចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់ តាមការផ្សាយជាសាធារណៈ ឬតាមវិធីផ្សេងទៀតអាចដកបាន តែតាមវិធីដូចគ្នានឹងសំណើនោះ[7]។ ជាគោលការណ៍ ការដកសំណើត្រូវធ្វើចំពោះបុគ្គលដែលបានទទួលសំណើ ប៉ុន្តែក្នុងករណីដែលសំណើមិនបានកំណត់បុគ្គលជាក់លាក់ អ្នកស្នើមិនអាចដកសំណើនោះចំពោះបុគ្គលទាំងអស់ដែលទទួលសំណើទេ ដូច្នេះដើម្បីភាពងាយស្រួលអ្នកស្នើអាចដកសំណើតាមវិធីដូចគ្នានឹងការធ្វើសំណើនោះ។

**ឧទាហរណ៍៖** ប្រសិនបើការធ្វើសំណើតាមរយៈកាសែតណាមួយ ការដកសំណើក៏អាចធ្វើបានតាមរយៈកាសែតដូចគ្នានោះបានដែរ។

### ៦.២.ការបដិសេធសំណើ

ការបដិសេធសំណើរបស់អ្នកទទួលសំណើ គឺជាការបញ្ចប់សំណើដោយសារអ្នកទទួលសំណើមិនមានចេតនា ដើម្បីធ្វើស៊ីការក្នុងគោលបំណងបង្កើតកិច្ចសន្យានោះឡើយ។

**ឧទាហរណ៍៖** **ក** បានប្រាប់ថា គាត់ចង់លក់សៀវភៅដែលគាត់បានទិញមកឲ្យ **ខ** តែ **ខ** បានប្រាប់ **ក** ថាគាត់មានសៀវភៅនេះហើយ គាត់មិនត្រូវការទេ។ នេះមានន័យថា **ខ** បានបដិសេធសំណើរបស់ **ក**។

### ៦.៣.សំណើតប ឬបដិសំណើ

អ្នកទទួលសំណើ អាចធ្វើសំណើតប ដោយមានការកែប្រែលក្ខខណ្ឌណាមួយពីសំណើដើម។ សំណើតប បានបង្កើតសំណើថ្មីមួយទៀត ហើយឋានៈ របស់ភាគីត្រូវបានប្តូរអ្នកធ្វើសំណើដើម ក្លាយទៅជាអ្នកទទួលសំណើថ្មី ដែលមានអំណាចក្នុងការទទួល ឬបដិសេធសំណើថ្មី។

**ឧទាហរណ៍៖** **ក** និយាយទៅកាន់ **ខ** ថាបើសិនជា **ខ** ចង់បាននាឡិកា របស់គាត់ **ខ** ត្រូវឱ្យលុយគាត់ ៥០$ (ហាសិបដុល្លារ) តែ **ខ** និយាយថា គាត់យកនាឡិកានេះលុះត្រាតែតម្លៃត្រឹមតែ ៣០$ (សាមសិបដុល្លា)។ **ខ** បានធ្វើសំណើតបទៅ **ក** ដូចនេះ **ក** មានជម្រើស ថាតើចង់លក់ ឬមិនចង់លក់នាឡិការបស់ខ្លួន។

### ៦.៤.កាលៈទេសៈជាក់លាក់មួយ

[7] មាត្រា ៣៤៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សំណើត្រូវបានបញ្ចប់ដោយសារកាលៈទេសៈជាក់លាក់មួយចំនួនដូចជា៖

- កម្មវត្ថុនៃសំណើត្រូវអន្តរាយ
- ភាគីណាមួយ ទទួលមរណភាព ឬក្លាយទៅជាមនុស្សអសមត្ថភាព
- ការកែប្រែ ឬវិសោធនកម្មច្បាប់ ដែលបណ្ដាលឲ្យសំណើក្លាយជាខុសច្បាប់។

**កថាខណ្ឌទី៣ ៖ ស្វីការ**

**១.និយមន័យ**

ស្វីការ[8] គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើ យល់ព្រមចំពោះសំណើនោះ។ មានន័យថា ជាការឆ្លើយតបយល់ព្រមទៅនឹងសំណើក្នុងគោលបំណងដើម្បីបង្កើតកិច្ចសន្យា។ ស្វីការត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដកស្វីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្វីការដល់ ឬមុនពេលស្វីការដល់នោះអានុភាពនៃស្វីការ មិនត្រូវកើតឡើយ។

**ឧទាហរណ៍៖ ក** បាននិយាយទៅកាន់ **ខ** ថាប្រសិនបើ **ខ** ចង់បានទូរស័ព្ទ របស់នាង **ខ** ត្រូវឲ្យប្រាក់ទៅនាង ៥០០$ (ប្រាំរយដុល្លារ) ។ ហើយ **ខ** បានយល់ព្រមទិញទូរស័ព្ទរបស់ **ក**។

ប៉ុន្តែប្រសិនបើគ្មានសំណើទេ តែបុគ្គលម្នាក់បង្ហាញឆន្ទៈថា <<ខ្ញុំចង់ទិញទំនិញនេះ>> ការបង្ហាញឆន្ទៈនេះមិនមែនជាស្វីការទេ ប៉ុន្តែវាត្រូវចាត់ទុកថាសំណើ។

**២. លក្ខខណ្ឌ**

**២.១.ស្វីការត្រូវធ្វើឡើងដោយអ្នកទទួលសំណើ**

មានតែអ្នកទទួលសំណើតែប៉ុណ្ណោះ ទើបអាចធ្វើស្វីការចំពោះសំណើនោះក្នុងគោលបំណងបង្កើតកិច្ចសន្យាមួយបាន។ លើកលែងតែ ការតំណាង ឬជនដែលត្រូវបានកម្រិតសមត្ថភាព។

**<u>ឧទាហរណ៍៖</u> ក** បាននិយាយទៅកាន់ **ខ** ថាប្រសិនបើអ្នកចង់បានសៀវភៅរបស់ខ្ញុំ អ្នកត្រូវឲ្យប្រាក់ខ្ញុំ ១$ (មួយដុល្លារ)។ ដូចនេះ មានតែ **ខ** ទេទើបអាចធ្វើស្វីការចំពោះសំណើរបស់ **ក** បាន។

**២.២.ស្វីការត្រូវតែជូនដំណឹងដល់អ្នកស្នើ**

ស្វីការ ត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ។ កិច្ចសន្យាកើតឡើងនៅពេលដែលសំណើជួប នឹងស្វីការ។ ដូចនេះប្រសិនបើអ្នកទទួលសំណើចង់បង្កើតកិច្ចសន្យា នោះគាត់ត្រូវធ្វើយ៉ាងណាបញ្ជូនស្វីការរបស់គាត់ឲ្យបានទៅដល់ភាគីអ្នកធ្វើសំណើ ។

**២.៣. ស្វីការត្រូវតែដូចគ្នាទៅនឹងសំណើ**

[8] មាត្រា ៣៣៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ស្ទីការ[9] ដែលអ្នកធ្វើបានដាក់លក្ខខណ្ឌលើសំណើ ឬកែប្រែសារធាតុផ្សេងនៃសំណើ មិនត្រូវក្លាយជាស្ទីការ សុពលភាព តែស្ទីការនោះមានអានុភាពជាសំណើថ្មី។ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើមធ្វើស្ទីការចំពោះសំណើថ្មីនោះ។

**<u>ឧទាហរណ៍៖</u> ក** ចង់លក់ម៉ូតូរបស់ខ្លួនក្នុងតម្លៃ ១០០០$ (មួយពាន់ដុល្លារ) ទៅឱ្យ **ខ** តែ **ខ** ឆ្លើយតបថាគាត់សុខចិត្តទិញម៉ូតូនេះតែក្នុងតម្លៃ ៨០០$(ប្រាំបីរយដុល្លារ)។ ដូចនេះស្ទីការ របស់ **ខ** គឺមិនមានសុពលភាពនោះទេ តែវាក្លាយជាទៅជាសំណើថ្មីមួយទៀត។

ប្រសិនបើលក្ខខណ្ឌ ឬការកែប្រែដែលភ្ជាប់ជាមួយនឹងស្ទីការ មិនធ្វើឲ្យមានការកែប្រែសារធាតុនៃសំណើទេ ស្ទីការនោះមានសុពលភាព លុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាម។

### ២.៤.ស្ទីការត្រូវតែធ្វើមុនពេលកំណត់លក់

ប្រសិនបើសំណើត្រូវបានគេរំលត់ មុនពេលស្ទីការកើតឡើងនោះគ្មានសន្យាដែលមានសុពលភាពកើតឡើងទេ ដោយហេតុថា កិច្ចសន្យាដែលមានសុពលភាពត្រូវកើតឡើងដោយសារ ការជួបគ្នារវាងសំណើដែលមានសុពលភាព និងស្ទីការដែលមានសុពលភាព។ ប្រសិនបើគូរភាគី កំពុងតែនិយាយទល់មុខគ្នា នោះនឹងមានភាពងាយស្រួលក្នុងការកំណត់ថា ពេលណាសំណើនឹងត្រូវរលត់ តែប្រសិនបើភាគីបានធ្វើទំនាក់ទំនងជាមួយគ្នាពីចម្ងាយ នោះ វានឹងមានភាពពិបាកក្នុងការកំណត់ថាពេលណាសំណើនឹងត្រូវរលត់។

អ្នកស្នើ អាចចាត់ទុកថាស្ទីការដែលបានមកដល់អ្នកស្នើ ក្រោយពេលផុតអំឡុងពេលសម្រាប់ស្ទីការ ជាសំណើថ្មី។

**<u>ឧទាហរណ៍៖</u> ក** និយាយទៅកាន់ **ខ** ថាប្រសិនបើ **ខ** ចង់ទិញអាវដូច **ក** នោះ **ខ** ត្រូវឲ្យលុយ ក ៥$ (ប្រាំដុល្លារ) នៅថ្ងៃនេះ។ តែ **ខ** នៅធ្វើព្រងើយ ស្រាប់តែថ្ងៃស្អែក **ខ** ដឹងថាអាវនេះអស់ពីស្តុកហើយ ប្រសិនបើចង់បានត្រូវចាំរហូតដល់ ១ខែទៀត ដូចនេះ **ខ** ប្រាប់ **ក** ថាគាត់ចង់បាន។ ដូចនេះស្ទីការរបស់ **ខ** មិនមាន សុពលភាពទេ ពីព្រោះសំណើត្រូវបានរលត់ទៅហើយ តែ **ក** អាចចាត់ទុកស្ទីការរបស់ **ខ** ថាជាសំណើថ្មីបាន ។

### ៣.វិធីនៃការធ្វើស្ទីការ

ស្ទីការ អាចត្រូវបានធ្វើឡើងតាមរយៈវិធីជាច្រើនដូចជា ៖

- ផ្ទាល់មាត់
- លាយលក្ខណ៍អក្សរ

---

[9] មាត្រា ៣៣៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- អាកប្បកិរិយា
- ប្រព័ន្ធទំនាក់ទំនងសង្គម ទូរស័ព្ទ ទូរសារ Email ហ្វេសប៊ុក ជាដើម។

# ជំពូកទី២ ៖ លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់

## ផ្នែកទី១ ៖ លក្ខខណ្ឌគ្រឹះ

### ១.១ ការព្រមព្រៀង

កិច្ចសន្យាដែលមានសុពលភាព គឺត្រូវធ្វើឡើងដោយ មានការព្រមព្រៀងពិតប្រាកដ និងដោយសេរី របស់គូរភាគីទាំងសង់ខាង។ រាល់ការព្រមព្រៀងពិតប្រាកដ ត្រូវតែកើតចេញពិឆន្ទៈពិតប្រាកដ របស់គូរភាគី ពោលគឺការព្រមព្រៀងនេះត្រូវតែប្រាកដថា គ្មានវិការៈក្នុងការបង្ហាញឆន្ទៈជាដាច់ខាត់។ វិការៈក្នុងការបង្ហាញឆន្ទៈ មានដូចជា ការឆបោក ពត៌មានមិនពិត ការភាន់ច្រឡំ ការគម្រាម់កំហែង អំពើកេងយកផលចំណេងហួសហេតុ ព្រមទាំងការបង្ហាញឆន្ទៈមិនពិត ជាដើម។

#### ១.១.១ ការភន់ច្រឡំ

##### ១.១.១.១ គោលគំនិត

ការភាន់ច្រឡំ មានន័យថា ជាការបង្ហាញឆន្ទៈ ដែលមានលក្ខខណ្ឌផ្ទុយទៅនឹងឆន្ទៈពិតរបស់ខ្លួន ហើយបានធ្វើឲ្យភាគីម្ខាងទៀតមិនបានដឹងពីភាពខុសគ្នានោះ នៅពេលដែកគេធ្វើការបង្ហាញ់ឆន្ទៈ។

<u>**ឧទាហរណ៍ ៖**</u> **ក** លក់ផ្ទះនៅភំពេញទៅឱ្យលោក **ខ** ប៉ុន្តែលោក **ខ** បែរជាមានការភន់ច្រឡំថាលោក **ក** លក់ផ្ទះនៅខេត្ត កណ្តាល មកឱ្យខ្លួនទៅវិញ។

##### ១.១.១.២ ការភន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា

ក្នុងករណីដែលភាគី ណាម្នាក់មានការភាន់បច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ប៉ុន្តែបើមានភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ដូច្នេះភាគីដែលបានភាន់ច្រឡំ អាចលុបចោលនូវកិច្ចសន្យានោះបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[10]។

ជាការលំបាកក្នុងការកំណត់ចំណុចសំខាន់ៗនៃកិច្ចសន្យា ព្រោះពុំមានច្បាប់ណា មួយចាយអត់បានច្បាស់លាស់អំពីចំណុចសំខាន់ៗនោះទេ។ វាត្រូវបានសម្រេចដោយការពិចារណា ទៅលើខ្លឹមសារនៃកិច្ចសន្យា ដែលអាចនិយាយបានថា ប្រសិនបើពួកគាត់ពុំមានការភ័ន្តច្រឡំនោះទេ គាត់ក៏មិនបង្ហាញឆន្ទៈព្រមព្រៀងដែរ។

[10] មាត្រា ៣៤៦ (១) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

លទ្ធភាពនៃការយល់ដឹងរបស់ភាគីម្ខាងទៀត មានសារៈសំខាន់ណាស់ ដើម្បីលុបកិច្ចសន្យាដោយយោងទៅលើការភ័ន្តច្រឡំ។ ប្រសិនបើអ្នកបង្ហាញឆន្ទៈ អាចលុបចោលកិច្ចសន្យាដោយគ្មានកម្រិតនោះសុវត្ថិភាពនៃកិច្ចសន្យាជំនួយហ្នឹងត្រូវបានធ្វើឲ្យប៉ះពាល់ ព្រោះវាមានការលំបាកខ្លាំងណាស់ក្នុងការវិនិច្ឆ័យថា អ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួនដោយមានឬគ្មានការភាន់ច្រឡំ។

<u>**ឧទាហរណ៍**</u> **៖ ក** មានដីពីរកន្លែង ដែលទីតាំងទីមួយស្ថិតនៅខេត្ត កណ្ដាល ទីតាំងទីពីរស្ថិតនៅខេត្តកំពង់ចាម។ **ក** បានយល់ព្រមលក់ដីទី១ ទៅឱ្យ **ខ** ហើយ **ខ** ព្រមទិញដីនោះដោយគិតថាដីនោះ មានទីតាំងស្ថិតនៅខេត្ត កំពង់ចាមដែលជាប់នឹងផ្ទះរបស់ខ្លួន។ ដូច្នេះ **ខ** មានការភាន់ច្រឡំ ទៅលើកម្មវត្ថុនៃកិច្ចសន្យាដែលជាចំណុចសំខាន់នៃកិច្ចសន្យា។

### ១.១.១.៣ ការភាន់ច្រឡំទៅលើចំណុចសំខាន់នៃកិច្ចសន្យា ដែលភាគីយល់ថាសំខាន់

ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា យល់ឃើញថាមានការភាន់ច្រឡំអំពីចំណុចសំខាននៃកិច្ចសន្យាដែលខ្លួន យល់ឃើងថាសំខាន់ ឬចំណុចណាដែលខ្លួនយល់ថាសំខាន់នៅក្នុងការបង្កើតកិច្ចសន្យា បើគូភាគីម្ខាងទៀត បានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃកិច្ចសន្យានេះ និងការភាន់ច្រឡំរបស់អ្នកបង្ហាញ ឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យានោះបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[11]។

ចំណុចដែលគូភាគីយល់ឃើញថាសំខាន់នៅក្នុងកិច្ចសន្យានោះ អាចមិនមែនពាក់ព័ន្ធទៅនឹងកម្មវត្ថុចម្បងនៃកិច្ចសន្យា ហើយមិនមែនសំខាន់សំរាប់ភាគីទាំងសងខាង់នោះទេ គឺវាមានសារៈសំខាន់តែទៅលើភាគីតែម្ខាងប៉ុណ្ណោះ។

<u>**ឧទាហរណ៍**</u> **៖ ក** ចង់ទិញសៀវដែលនិយាយពីការរកស៊ី។ ថ្ងៃមួយ **ក** ទៅទិញសៀវភៅមួយក្បាល់ដែលមើលពីខាងក្រៅហាក់ដូចជាសៀវភៅដែលនិយាយពីការរកស៊ី ដូច្នេះ **ក** ក៏បានទិញសៀវភៅនោះមក តែតាមការពិតវាមិនមែនជាសៀវភៅដែលនិយាយពីការរកស៊ីទេ។ ដូច្នេះ **ក** មានការភាន់ច្រឡំ ទៅលើសៀវភៅដែលនិយាយពីការរកស៊ីនោះ ដែលគាត់យល់ឃើញថាសំខាន់សម្រាប់គាត់។

### ១.១.១.៤ ការភាន់ច្រឡំដោយភាគីភាគីទាំងសងខាង

ក្នុងករណីដែលភាគីទាំងសងខាង មានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមាន

[11] មាត្រា ៣៤៦ (២) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

លទ្ធភាពអាចដឹង អំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

ភាគីទាំងសងខាងមានការភាន់ច្រឡំ ដូចនេះភាពចាំបាច់ក្នុងការការពារភាគីម្ខាងទៀត គឺមានកម្រិតទាបដែលខុសពីករណីមានតែ ភាគីម្ខាងមានការភាន់ច្រឡំ។ ដូចនេះ វាមានភាពចាំបាច់ក្នុងការពិចារណាទៅលើលទ្ធភាពក្នុងការដឹងរបស់ភាគីម្ខាងទៀត។

**ឧទាហរណ៍ ៖ ក** និង **ខ** បានបង្កើតកិច្ចសន្យាលក់កង់មួយ ដោយពួកគាត់ជឿជាក់ថាជាកង់ថ្មី តែតាមការពិតជាកង់មួយទឹក ទៅវិញ។ ដូច្នេះ ពួកគាត់មានការទន់ច្រឡំរួម។

#### ១.១.១.៥ ការការពារតតិយជន

ការលុបចោលនៃកិច្ចសន្យា ដោយភាន់ច្រឡំក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះ តតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ[12]។

ការការពារតតិយជនគឺ មានសារៈសំខាន់ណាស់ដើម្បីការពារដល់ប្រយោជន៍របស់ តតិយជន ដែលកើតចេញអំពីការបង្កើតកិច្ចសន្យាដោយមានវិការៈនោះ។

**ឧទាហរណ៍ ៖ ក** បានលក់កង់ទៅឱ្យ **ខ** ហើយ **ខ** បានលហក់កង់នោះទៅឱ្យ **គ** បន្តទៀត។ បន្ទាប់មកទៀត **ក** ក៏បានលុបចោលកិច្ចសន្យាវវាង **ខ** ដោយសារការភាន់ច្រឡំ។ នៅក្នុងករណីនេះ **គ** ត្រូវបានចាត់ទុកថាបានទិញពី **ខ** ដែលមិនមែនជាកម្មសិទ្ធិ ព្រោះអានុភាពនៃកិច្ចសន្យាវវាង **ក** និង **ខ** ត្រូវបានចាត់ទុកថាមោឃៈតាំងពីដំបូង។ **ខ** ត្រូវបង់មូលដ្ឋានតាមផ្លូវច្បាប់ក្នុងការកាន់កាប់កង់នេះ ហើយគាត់ត្រូវប្រគល់កង់នោះមកវិញ។ ក៏ប៉ុន្តែវានឹងធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពនៃកិច្ចការជំនួយរបស់ **គ**។ ដូច្នេះប្រសិនបើ **គ** គឺជាជនដែលសុចរិត និងគ្មានកំហុស **ក** មិនអាចអះអាងពីអានុភាពនៃការលុបចោលនៃកិច្ចសន្យានេះទេ។

### ១.១.២ ការឆបោក

#### ១.១.២.១ គោលគំនិត

ការឆបោក មានន័យថា បុគ្គលណាម្នាក់ ឬតតិយជន បានធ្វើឲ្យអ្នកបង្ហាញឆន្ទៈ មានការភាន់ច្រឡំដោយសារ មធ្យោបាយឆបោកណាមួយ ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួន ដោយផ្ទុយពីឆន្ទៈពិតប្រាកដរបស់ខ្លួន និងគាត់មិនបានដឹងពីភាពខុសគ្នានោះ នៅពេលដែលគាត់ធ្វើការបង្ហាញឆន្ទៈ។

[12] មាត្រា ៣៨៦ (៣) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ការឆបោក មានលក្ខណៈស្រដៀងគ្នាទៅនឹងការភាន់ច្រឡំដែរ ត្រង់ចំណុច ដែលឆន្ទៈពិតប្រាកដនិងការបង្ហាញឆន្ទៈចេញមកក្រៅមិនត្រូវគ្នា។ ប៉ុន្តែ ភាពខុសគ្នានេះកើតពិតប្រាកដ និងការបង្ហាញឆន្ទៈចេញមកក្រៅមិនត្រូវគ្នានេះកើតឡើងពីសកម្មភាពឆបោករបស់ភាគីម្ខាងទៀត ឬតតិយជន នៅក្នុងករណីនៃការឆបោក ដែលមានលក្ខណៈខុសគ្នាពីការភាន់ច្រឡំ។

**<u>ឧទាហរណ៍ ៖</u> អ្នកលក់** បានប្រាប់ **អ្នកទិញ** ថាមានផលិតផលពិសេសមួយដែលនាំមកពីប្រទេកូ៉រេ តែតាមការពិតជាផលិតផលនោះ ជាផលិតផលធម្មតាដែលផលិតនៅតាមផ្ទះសោះ។ ក្នុងករណីនេះជាការឆបោកដែលប្រព្រឹត្តិដោយអ្នកលក់ ព្រោះគាត់បានដឹងអំពីប្រភព នៃផលិតផលនោះយ៉ាងច្បាស់។

### ១.១.២.២ ការឆបោករបស់តតិយជន

ក្នុងករណីដែលការបង្ហាញឆន្ទៈ បានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនៃកច្ចសន្យា ដោយហេយុថា ការបង្ហាញឆន្ទៈនោះមានវិការៈលុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះបានដឹង ឬអាចដឹងអំពីការឆបោកនោះ។

ការឆបោកដោយតតិយជន គឺសំដៅទៅលើជន ដែលក្រៅពីភាគីក្នុងកិច្ចសន្យា បានប្រើមធ្យោបាយឆបោក ដើម្បីធ្វើឲ្យអ្នកបង្ហាញឆន្ទៈមានការភាន់បច្រឡំដោយសារមធ្យោបាយឆបោកនោះ ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាឆន្ទៈរបស់ខ្លួនដោយខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន។

**<u>ឧទាហរណ៍ ៖</u>** ក បានប្រាប់ទៅកាន់ ខ ថាទីតាំងផ្ទះរបស់ គ នឹងមានការអភិវឌ្ឍន៍ដោយមានក្រុមហ៊ុនដ៏ល្បីមួយមកវិនិយោគនៅទីនោះ។ គ្រាន់តែលឺដូចនេះ ខ បានទិញផ្ទះរបស់ ក ភ្លាមៗ នៅក្នុងករណីនេះដែល ខ មានការភាន់ច្រឡំ ដោយសារតែការជឿលើការឆបោករបស់ ក។ ដូច្នេះ ខ អាចលុបចោលកិច្ចសន្យាបាន ប្រសិនបើ គ បានដឹង ឬអាចដឹងពីការឆបោលរបស់ ក។

### ១.១.២.៣ ការការពារតតិយជន

ការលុបចោលនូវកិច្ចសន្យា ដោយការឆបោកក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងអានុភាពចំពោះតតិយជននោះបានឡើយ។

**<u>ឧទាហរណ៍ ៖</u> ក** បានឆបោក **ខ** ឱ្យលក់ទូរស័ព្ទរបស់ខ្លួនក្នុងតម្លៃទាប ហើយ **ក** បានលក់ទូរស័ព្ទ នោះបន្តទៅ **គ**។ បន្ទាប់មក **ខ** ក៏បានដឹងថា **ក** បានឆបោកខ្លួនក៏បានសុំលុបចោលកិច្ចសន្យានេះចោល។

ក្នុងករណីនេះ **ខ** អាចអះអាងពីអានុភាពនៃការលុបចោលចំពោះ **ក** បានដោយយោងទៅលើការឆបោករបស់ **ក** ទើបធ្វើឱ្យ **ខ** បង្ហាញឆន្ទៈក្នុងការលក់ដីនេះ ដែលជាការបង្ហាញឆន្ទៈមានវិការៈ។ ក៏ប៉ុន្តែ ប្រសិនបើ **គ**

ជាជនសុចរិត និងគ្មានកំហុស **ខ** មិនអាចអះអាងពីអានុភាពនៃការលុបចោលនេះចំពោះ គបានទេ។ ដូចនេះ **ខ** មិនអាចទាមទារទូវស័ព្ទពី **គ** ដែលជាជនសុចិត និងគ្មានកំហុសបានទេ។

### ១.១.៣ ពត៌មានមិនពិត

#### ១.១.៣.១ គោលគំនិត

នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាះដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថាហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសោនបើភាគីណោះដឹងថា ហេតុនោះមិនមែនជាកាពិតខ្លួននិងមិនបង្ហាញឆន្ទៈនោះទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

ក្នុងករណីនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាត ពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនោះមានកំហុស។

នៅក្នុងករណីនៃពត៌មានមិនពិត គេតម្រូវឲ្យភាគីម្ខាងទៀតមិនបានដឹងថាហេតុ ដែលគាត់បានលើកឡើងនោះមិនមែនជាការពិត។ ប្រសិនបើគាត់បានដឹងថាហេតុនោះខុសពីការពិត ត្រូវបានគេចាត់ទុកជាការឆបោក។

<u>**ឧទាហរណ៍ ៖**</u> ក ជាអ្នកលក់សំលៀកបំពាក់ បានប្រាប់ ខ ដែលជាភ្ញៀវថាសំលៀកបំពាក់នេះផលិសតអំពីក្រណាត់ល្អប្រណិតដែលផលិតនៅប្រទេសថៃ ហើយលក់ក្នុងតម្លៃ១៥០$ (មួយរយហាសិបដុល្លាសហរដ្ឋអាមេរិក ) ក្នុងមួយអាវ បន្ទាប់មក **ខ** ក៏បានទិញអាវនោះ តែតាមការពិតអាវនោះ ផលិតពីក្រណាត់ធម្មតាតែប៉ុណ្ណោះ។ ក្នុងករណីនេះ **ខ** អាចលុបចោលកិច្ចសន្យាបានដោយផ្អែកលើព័ត៌មានមិនពិតរបស់ **ក** ព្រោះគាត់មិនបានពិនិត្យក្រណាត់នេះឱ្យបានត្រឹមត្រូវនោះទេ។ ករណីនេះអាចចាត់ទុកថាជាកំហុសរបស់ **ក** ព្រោះគាត់មិនបានពិនិត្យក្រណាត់ឱ្យបានត្រឹមត្រូវ។ ដូច្នេះ ប្រសិនបើ **ខ** ទទួលរងការខូបខាត នោះ **ខ** អាចទាមទារសំណងនៃការខូចខាតពី **ក** បាន។

#### ១.១.៣.២ ការការពារតតិយជន

ការលុបចោលនូវកិច្ចសន្យាដោយពត៌មានមិនពិត ក្រៅពីភាគីម្ខាងអាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែ ប្រសោនបើតតិយជនជាជនសុចរិត ហើយគ្មានកុំហុសអំពីពត៌មាន មិនអាចអះអាងនូវអានុភាព នៃការលុបចោលចំពោះតតិយជននោះបានឡើយ[13]។

### ១.១.៤ ការរំលោបចំពានលើស្ថានភាព

[13] មាត្រា ៣៨៧ (៣) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**១.១.៤.១ គោលគនិត**

នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាង ភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម ឬបានប្រើប្រាស់ស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[14]។

ការរំលោបបំពានលើស្ថានភាព មានលក្ខណៈស្រដៀងគ្នាទៅនឹង អំពើកេងយកចំណេញហួសហេតុត្រង់ចំណុចដែល ភាគីម្ខាងទៀត បានឆ្លៀតឱកាសមិនត្រឹមត្រូវ នៅពេលមានការលំបាកខាងផ្នែកសេដ្ឋកិច្ច ។ ក៏ប៉ុន្តែវាតម្រូវឲ្យ ភាគីម្ខាងទៀតកេងយកយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យា នៅក្នុងករណីនៃអំពើកេងយកកេងចំណេញយ៉ាងហួសហេតុ ដែលមានក្ខណៈខុសពីគ្នាពីករណី នៃការរំលោភបំពានលើស្ថានភាព។

**<u>ឧទាហរណ៍ ៖</u>** កម្មករ ម្នាក់ទើបតែទិញបានចានបុរាណ ដែលកំររកបាន បន្ទាប់មក **ថៅកែរ** របស់គាត់បានឃើងចានបុរាណនោះ ហើយក៏ស្រលាញ់ ហើយបានប្រាប់ទៅកាន់ **កម្មករ** នោះថា ត្រូវតែលក់ចានបុរាណនោះមកឱ្យគាត់ក្នុងតម្លៃដើម បើមិនដូច្នេះទេគាត់នឹងបញ្ឈប់ **កម្មករ** នោះភាម។

**១.១.៤.២ ការការពារតតិយជន**

ការលុបចោលកិច្ចសន្យាដោយការរំលោភបំពានលើស្ថានភាពនេះ មិនអាចអះអាងបំពោះ តតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ[15]។

**១.១.៥ ការគម្រាមកំហែង**

**១.១.៥.១ គោលគំនិត**

ការគម្រាមកំហែងសំដៅលើករណីដែល អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈរបស់ខ្លួន ដែលផ្ទុយនឹងគោលបំណងរបស់ខ្លួន ដោយសារមានការភ័យខ្លាចភាគីម្ខាងទៀត ឬតតិយជន។

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែង ពីសំណាក់ភាគីម្ខាងទៀត ពីសំណាក់តតិយជន អាលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

❖ លក្ខណៈខុសគ្នារបស់ ការភាន់ច្រឡំ ការឆបោក និងការគម្រាមកំហែង ៖

- ការភាន់ច្រឡំ ៖ អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈ ដោយមានការភាន់ច្រឡំ។

[14] មាត្រា ៣៤៨ (១) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[15] មាត្រា ៣៤៨ (៣) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- ការឆបោក ៖ អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈ ដោយមានការភាន់ច្រឡំ ដែលបង្ក ឡើងដោយភាគីម្ខាងទៀត ឬតតិយជន។
- ការគម្រាមកំហែង ៖ អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈ ដោយគ្មានការភាន់ច្រឡំ ប៉ុន្តែ វាផ្ទុយនឹងគោលបំណង់របស់ខ្លួន ដោយសារមានការភ័យខ្លាច ដែលបង្កលើងដោយ ភាគីម្ខាងទៀត ឬតតិយជន។

<u>**ឧទាហរណ៍ ៖**</u> **ក** ចង់ទិញដីរបស់ **ខ** ប៉ុន្តែ **ខ** ដែលជាម្ចាស់ដីមិនព្រមលក់ដីនោះទៅឱ្យ **ក** ទេ ដោយហេតុថា **ខ** ចង់ទុកដីនេះដើម្បីប្រកបរបរ។ ដោយហេតុតែ **ក** ស្រលាញ់ដីនោះពេក ក៏បានគម្រាម **ខ** ថាបើមិនលក់ដីនេះឱ្យទៅខ្លួនទេនឹងបាញ់សំលាប់ **ខ** ដែលជាម្ចាស់ដី បន្ទាប់មក **ខ** ក៏មានការភ័យខ្លាចយ៉ាងខ្លាំងក៏សម្រេចចិត្តលក់ដីនោះនៅ ឱ្យ **ក**។

#### ១.១.៥.២ ការការពារតតិយជន

មិនមានបញ្ញត្តិច្បាប់ សម្រាប់ការពារតតិយជននោះទេ ទោះបីតតិយជនបានបង្កើតទំនាក់ទំនងក្នុងកិច្ចសន្យាដោយផ្អែកលើកិច្ចសន្យា ដែលអាចត្រូវបានគេលុបចោលនោះ។ ក្នុងករណីនេះអ្នកបង្ហាញឆន្ទៈ អាចប៉ះអាលពីអនុភាពនៃការលុបចោលចំពោះតតិយជនបានទោះបីជាតតិយជននោះគឺជាជនសុចរិតក៏ដោយ។

មូលហេតុដែលមិនមានបញ្ញត្តិ សម្រាប់ការការពារតតិយជនទាក់ទងនឹងការគំរាមកំហែង គឺថាអ្នកបង្ហាញ ឆន្ទះ បានបង្ហាញឆន្ទៈរបស់ខ្លួនដោយគ្មានការភ័ន្តច្រឡំ ដែលមានលក្ខណៈខុសពីការភាន់ច្រឡំ ឬការឆបោក ដូច្នេះ អ្នកបង្ហាញឆន្ទៈ ត្រូវបានគេការពារច្រើនជាង នៅក្នុងករណីដៃរនៃការឆបោក ឬភាន់ច្រឡំ។

### ១.១.៦ ការគេចចំណេញហួសហេតុ

#### ១.១.៦.១ គោលគំនិត

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតយកឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះនូវការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬល្ងង់ខ្លៅ ឬការខ្វះខាតបទពិសោធន៍ ហើយបានគេយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[16]។

[16] មាត្រា ៣៤៩ (១) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

គោលបំបងក្នុងចំណុចនេះ ចង់ការពារភាគីម្ខាងនៃកិច្ចសន្យា ដូចជាអ្នកប្រើប្រាស់ ពីអ្នកផលិតផលិតផលយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលប៉ុនប៉ងកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ ដោយឆ្លៀតឱកាសនៅនូវភាពល្ងង់ខ្លៅ ឬខ្វះបទពិសោធរបស់អ្នកប្រើប្រាស់។

**<u>ឧទាហរណ៍ ៖</u> ក** បានទិញម៉ូតូថ្មីមួយគ្រឿងក្នុងតម្លៃ ២000 ដុល្លាសហរដ្ឋអាមេរិក ប៉ុន្តែបន្ទាប់មកប្រពន្ធរបស់ **ក** មានជំងឺឈឺជាទំងន់ដែលធ្វើឲ្យ **ក** ត្រូវការលុយដើម្បីព្យាបាលជំងឺ។ ដោយមើលឃើញដូច្នេះ**ខ**ចង់ទិញម៉ូតូរបស់ **ក** ក្នុងតម្លៃទាបត្រឹមតែ ១000 ដុល្លាសហរដ្ឋអាមេរិក តែប៉ុណ្ណោះដោយសារតែក៏ **ក មា**មិនលុយគ្រប់គ្រាន់គ្រប់ សំរាប់ព្យាបាលជម្ងឺរបស់ប្រពន្ធគាត់ ហើយក៏ត្រូវការលុយជាប្រញាប់ទៀតនោះ ក៏បានយល់ព្រមលក់ម៉ូតូទៅឱ្យ **ខ** តម្លៃ ១000 ដុល្លាសហរដ្ឋអាមេរិកទៅ។

### ១.១.៦.២ ការការពារតតិយជន

មិនមានបញ្ញត្តិច្បាប់ សម្រាប់ការពារតតិយជននោះទេ ព្រោះនៅក្នុងបញ្ញត្តិនេះសន្មតថា អ្នកបង្ហាញឆន្ទៈ គឺជាសាធារណៈជនដែលប្រើប្រាស់ផលិតផល និងភាគីម្ខាងទៀតជាផលិតករ ដែលផលិតផលក្នុងទ្រង់ទ្រាយធំ។ ដូចនេះវាមិនមានបញ្ហាដើម្បីការពារជនជាងការការពារសាធារណៈជនដែលប្រើប្រាស់ផលិតផលនោះទេ។

### ១.១.៧ ឋបនីយផ្លូវចិត្ត

### ១.១.៧.១គោលគំនិត

បានបង្ហាញនោះ មិនមែនជាឆន្ទៈពិតប្រាកដរបស់ខ្លួនឡើយ ហើយខ្លួននៅតែសម្រេចចិត្តធ្វើការបង្ហាញទៀត។ ឋបនីយផ្លូវចិត្ត គឺជាអ្នកបង្ហាញឆន្ទៈបានដឹងថា ការបង្ហាញឆន្ទៈតាមការជាក់ស្តែងរបស់ខ្លួនមានលក្ខណៈខុសគ្នាទៅនឹងឆន្ទៈពិតប្រាកដរបស់ខ្លួន។ មានន័យថា ភាគីដែលបង្ហាញឆន្ទៈ បានដឹងយ៉ាងពិតប្រាកដថាការបង្ហាញឆន្ទៈដែល។

**<u>ឧទាហរណ៍ ៖</u> ក** បានប្រាប់ទៅ **ខ** ថាគាត់ចង់ទិញដីមួយហិតារបស់ **ខ** នៅខេត្តព្រះវិហារ ក្នុង តម្លៃ ១ ម៉ឺនដុល្លារ តែតាមការពិតទៅ **ក** មិនចង់ទិញដីរបស់ **ខ** ឡើយ។ ក្នុងករណីនេះប្រសិនបើ **ខ** យល់ព្រមលក់ដីទៅឱ្យ **ក** នោះ **ក** នឹងបានបង្កើតកិច្ចសន្យាដែលមានសុពលភាពមួយជាមួយ **ខ** ហើយ **ក** ក៏ត្រូវតែបង់ប្រាក់ឱ្យទៅ **ខ**។

### ១.១.៧.២ ការការពារតតិយជនលើស្ថានភាព

ប្រសិនបើ កិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ។ ព្រោះភាគីម្ខាងទៀតមិនបានដឹងថាតើអ្នកបង្ហាញឆន្ទៈ

បានបង្ហាញឆន្ទៈពិតប្រាកដដែរឬទេ។ ដូចនេះគេមិនចាំបាច់ការពារអ្នកបង្ហាញឆន្ទៈដោយដឹងថាការបង្ហាញឆន្ទៈនោះមិនមែនជាឆន្ទៈពិតប្រាកដរបស់ខ្លួនឡើយ។

ទោះបីជាមិនមានបញ្ញត្តិច្បាប់ សម្រាប់ការពារតតិយជនក្នុងចំណុចនេះក៏ដោយ ក៏ត្រូវតែការពារតតិយជនដែរ ព្រោះថាកិច្ចសន្យាមានអានុភាពទៅហើយដូចនេះត្រូវតែការពារតតិយជនដែលមានផលប្រយោជន៍ទាក់ទងនឹងកិច្ចសន្យានេះ។

<u>**ឧទាហរណ៍ ៖**</u> **ក** បានប្រាប់ទៅ **ខ** ថាគាត់ចង់ទិញផ្ទះរបស់ **ខ** ដែលស្ថិតនៅជិតផ្សារតាខ្មៅ ក្នុងតម្លៃ ១០០,០០០ ដុល្លាសហរដ្ឋអាមេរិក តែតាមការពិតទៅ **ក** មិនចង់ទិញផ្ទះរបស់ **ខ** ឡើយ។ បន្ទាប់ **ក** ក៏បានទិញផ្ទះនោះ ហើយ **ក** បានលក់ផ្ទះនោះទៅឱ្យ **គ**។ ដូច្នេះ **ក** មិនអាលុបចោល ឬក៏ទាមទាផ្ទះពី **គ** វិញបានទេ ដោយហេតុថា កិច្ចសន្យារវាង **ក** និង **ខ** គឺជាកិច្ចសន្យាដែលមានសុពលភាព ដូច្នេះ កិច្ចសន្យាដែល **ក** បានធ្វើជាមួយ **គ** ក៏ជាកិច្ចសន្យាមានសុពលភាពដែរ។

ក្នុងករណីដែល ភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យានោះបាទ។ ក្នុងករណីនេះ កិច្ចសន្យាត្រូវបានបង្កើតឡើងដោយមានសុពលភាព ប៉ុន្តែការដែលភាគីម្ខាងទៀតបានដឹងថា ការបង្ហាញឆន្ទៈខុសពីឆន្ទៈរបស់អ្នកបង្ហាញនោះត្រូវចាត់ទុកថាជាការតវ៉ា ដូច្នេះ អ្នកបង្ហាញឆន្ទៈដែលចង់បដិសេធការអនុវត្ត កាតព្វកិច្ចរបស់ខ្លួន ចាំបាច់ត្រូវបង្ហាញពីភាពទុច្ចរិតរបស់ភាគីម្ខាងទៀត។

### ១.១.៨ ការបង្ហាញឆន្ទៈមិនពិត

#### ១.១.៨.១ គោលគំនិត

គោលគំនិតៈការបង្ហាញឆន្ទៈមិនពិត គឺជាការបង្ហាញឆន្ទៈខុសពីការពិត ដែលបានធ្វើឡើងដល់ការឃុបឃិតជាមួយភាគីម្ខាងទៀត។

កិច្ចសន្យាដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិត ត្រូវបានធ្វើឡើងដោយការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ[17]។

<u>**ឧទាហរណ៍**</u> **៖ ក** ជំពាក់ប្រាក់ **ខ** ចំនួន ១០,០០០ ដុល្លាអាមេរិក ហើយ **ខ** មានផ្ទះមួយកន្លែង ។ ដោយ **ក** ខ្លាច **ខ** ប្ដឹងទៅតុលាការដោយហេតុថាខ្លួនមិនមានប្រាប់សងទៅឱ្យ **ខ** បន្ទាប់មក **ខ** ក៏បានអនុវត្តដោយបង្ខំនូវផ្ទះរបស់ **ក**។ ប៉ុន្តែ **ក** គាត់បានឃុមឃិតជាមួយ **គ** ដើម្បីបង្កើតរូបភាពខាងក្រៅដែល **ក** បានលក់ដីទៅឱ្យ **គ**

[17] មាត្រា ៣៥៣ (១) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ហើយ **ក** នឹង **គ** បានធ្វើលិខិតយថាភូត ហើយ **ក** បានចុះបញ្ជីផ្ទេរផ្ទះនោះទៅឱ្យ **គ**។ ដូច្នេះ កិច្ចសន្យានោះត្រូវទុកជាមោឃៈ ដូចនេះ **ខ** អាចអនុវត្តដោយបង្ខំផ្ទះនោះបាន។

ក្នុងករណី ឋបនីផ្លូវចិត្ត មានតែអ្នកបង្ហាញឆន្ទៈទេដែលបង្ហាញនូវឆន្ទៈមិនពិតប្រាកដ ប៉ុន្តែនៅក្នុងករណីការបង្ហាញឆន្ទៈមិនពិត មិនត្រឹមតែអ្នកបង្ហាញឆន្ទៈទេ ថែមទាំងភាគីម្ខាងទៀតបានដឹងថា ការបង្ហាញឆន្ទៈរបស់ខ្លួនគឺមិនពិត។ ដូចនេះមានន័យថា ភាគីទាំងពីរនៃកិច្ចសន្យាបានបង្ហាញឆន្ទៈមិនពិតដូចគ្នា។

#### ១.១.៨.២ ការការពារតតិយជន

មោឃភាពនៃកិច្ចសន្យា ដែលបានកំណត់ក្នុងការបង្ហាញឆន្ទៈមិនពិតនេះមិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដោយផ្អែកទៅលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិតឬមិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ[18]។

## ១.២ សមត្ថភាព

### ១.២.១ សមត្ថភាពខាងឆន្ទៈ

#### ១.២.១.១ គោលគំនិត

សមត្ថភាពខាងឆន្ទៈ គឺជាសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ សកម្មភាពនៅទីនេះ ចង់សំដៅទៅលើកិច្ចសន្យា និងសកម្មភាពឯកតោភាគី។

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមទាំងបង្កើតកែប្រែ ឬរំលត់នូវកាតព្វកិច្ច។

សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច ដែលបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬដោយអនុវត្តសិទ្ធិដែលបានទទួលតាមរយៈកិច្ចសន្យា ឬតាមបញ្ញត្តិនៃច្បាប់។

#### ១.២.១.២ អានុភាព

សកម្មភាពដែលភាគីបានធ្វើ នៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន។ មានន័យថា ទោះបីមិនមែនជាជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព ក៏អាចលុបចោលបាន នូវសកម្មភាពដែលបានធ្វើឡើងក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងការវិនិច្ឆ័យអំពី លទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។

[18] មាត្រា ៣៥៣ (២) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឧទាហរណ៍ ៖** ការលុចកិច្ចសន្យាដែលខ្លួនបានចុះហត្ថលេខា ក្នុងស្ថានភាពគ្មានសមត្ថភាពខាងឆន្ទៈ ដោយសារការបរិភោគគ្រឿងស្រវឹងច្រើន ឬការប្រើប្រាស់ថ្នាំដែលធ្វើឱ្យមានការចុះថយខ្លាំងនូវសមត្ថភាពក្នុងការវិនិច្ឆ័យ។

### ១.២.២ សមត្ថភាពក្នុងការធ្វើសកម្មភាព

របបសមត្ថភាពក្នុងការធ្វើសកម្មភាព គឺជារបបការពារកុំឱ្យមានការទទួលរងនូវការខូចខាត ដែលកើតឡើងដោយសារកិច្ចការជួញដូរ របស់ជនដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុង ការវិនិច្ឆ័យ ដោយមិនឲ្យជននៅក្នុងប្រភេទមួយចំនួនបង្កើតកិច្ចសន្យាដែលមានសុពលភាពពេញលេញ។

ជនដែលត្រូវបានកម្រិតសមត្ថភាព ត្រូវទទួលការអនុញ្ញាតពី អ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈរបស់ជននោះ ប្រសិនបើមិនបានទទួលការអនុញ្ញាតទេ នោះសកម្មភាពរបស់ជននោះអាចលុបចោលបាន។ ក៏ប៉ុន្តែប្រសិនបើចេះតែឲ្យ ភាគីខាងជនអសមត្ថភាពអាចលុបចោល សកម្មភាពដោយសារការអសមត្ថភាពដោយមិនមានកម្រិត វាអាចធ្វើឱ្យបាត់បង់ដល់ស្ថិរភាពក្នុងការប្រកបកិច្ចការ។ ដូចនេះ បានជាក្រមរដ្ឋប្បវេណី បានចាត់ថ្នាក់ជនទាំងនោះជាបីប្រភេទ ដើម្បីរក្សាតុល្យភាពរវាងការការពារជនដែលត្រូវបានកម្រិតសមត្ថភាព និងរក្សានូវស្ថិរភាពក្នុងការប្រកបកិច្ចការ។

ជនដែលត្រូវកម្រិត សមត្ថភាព ត្រូវបានបែងចែកជា ៣ ប្រភេទគឺ៖

- អនីតិជន
- ជននៅក្រោមអាណាព្យាបាលទូទៅ
- ជននៅក្រោមហិតូបត្ថម្ភ។

#### ១.២.២.១ អនីតិជន

- **គោលគំនិត**

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ឆ្នាំ[19]។

- **សិទ្ធិលុបចោលសកម្មភាព**

សកម្មភាពដែលអនីតិជនបានធ្វើ ដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបាឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោលបាន។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬឲ្យរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃ។ ដោយសារតែរយៈ

---

[19] មាត្រា ១៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សកម្មភាពទាំងនេះ អនីតិជនពុំមានបាត់បង់នូវផលប្រយោជន៍របស់ខ្លួនទេហេតុនេះហើយមិនចាំបាច់ទទួលស្គាល់នូវការលុបចោលទេ។

- សកម្មភាពទទួលសិទ្ធិ
- សកម្មភាពឱ្យរួចផុតពីកាតព្វកិច្ច
- សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។

- **ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់ អនីតិជនអនុញ្ញាតឲ្យចាត់ចែង**

ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់ អនីតិជនអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណងក្នុងទំហំនៃគោលបំណងនេះបាន។ ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែង ទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឲ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ[20]។

ក្នុងករណីនេះ អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានផ្តល់ទ្រព្យសម្បត្តិដូចជា ប្រាក់ដល់អនីតិជន ដោយបានកំណត់គោលដៅប្រើប្រាស់ ឬសម្រាប់ចាយវាយកំប៉ិកកំប៉ុក ដោយមិនបានកំណត់គោលដៅប្រើប្រាស់ ទោះបីជាអនីតិជនក៏ដោយ ក៏អាចធ្វើកិច្ចសន្យាសុពលពេញលេញបានដែរ ប្រសិនបើកិច្ចសន្យានោះ ស្ថិតក្នុងទំហំដែលអាចបងតម្លៃបានដោយប្រាក់ដែលបានផ្តល់ឲ្យនោះ។

- **អនីតិជនដែលត្រូវបានអនុញ្ញាតឲ្យប្រកបអាជីវកម្ម**

អនីតិជន ដែលត្រូវបានអនុញ្ញាតឲ្យប្រកបអាជីវកម្មមួយប្រភេទ ឬច្រើនប្រភេទពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចអនីតិជនចំពោះមុខជំនួញនោះ[21]។

**<u>ឧទាហរណ៍</u> ៖ ក** មានហាងលក់សំលៀកបំពាក់មួយកន្លែង ហើយបានឱ្យ **ខ** ដែលជាកូនរបស់គាត់ជួលលក់សំលៀកបំពាក់ក្នុងហាងនៅពេលដែល **ក** មិននៅ ។ ដូច្នេះ **ខ** អាចបង្កើតកិច្ចសន្យាដែលមានសុពលភាពមួយ ដោយខ្លួនឯងបាន ព្រោះថា **ខ** អាចលក់សំលៀកបំពាក់ឱ្យទៅអតិថិជនបាន ដែលមកទិញសំលៀកបំពាក់កនៅក្នុងហាងរបស់ **ក** បាន។

[20] មាត្រា ១៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[21] មាត្រា ២០ (១) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ប្រសិនបើដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬកម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន។

- **អត្តាធីនភាព**

អនីតិជនដែលទទួលអត្តាធីនភាពត្រូវ បានចាត់ទុកថាបានដល់នីតិភាព[22]។ អនីតិជន អាចទទួលបាននូវអត្តាធីនភាព តាមវិធី២យ៉ាងគឺ ការសុំទៅតុលាការ និងការរៀបអាពាហ៍ពិពាហ៍។

ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ១៦ឆ្នាំ ទ្រទ្រង់ជីវភាពរបស់ខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះ បានតាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថាអត្តាធីនភាពស្រប និងផលប្រយោជន៍របស់អនីតិជននោះ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានអំណាចមេបា។

អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាពដោយមិនចាំបាច់ការមានសាលក្រមពីតុលាការទេ។ ប៉ុន្តែទោះបីជាភាគីលែងលះគ្នាក៏ដោយក៏អានុភាពនៃអត្តាធីនភាពមិនត្រូវបានរលត់ឡើយ[23]។

- **កិច្ចសន្យាការងាររបស់អនីតិជន**

អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានឡើយ លើកលែងតែអនីតិជននោះបានផ្តល់សច្ចានុមតិលើកិច្ចសន្យានោះ។ ក្នុងករណីដែលយល់ឃើញថា កិច្ចសន្យាការងាររបស់អនីតិជនអាចធ្វើឲ្យខូចផលប្រយោជន៍ដល់អនីតិជននោះ អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬស្ថាប័នរដ្ឋបាលអាចរំលាយកិច្ចសន្យានោះឆ្ពោះទៅអនាគតបាន[24]។

អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានឡើយ ពីព្រោះដើម្បីការពារកុំឱ្យឪពុកម្តាយ កេងប្រវ័ញ្ចកំលាំងពលកម្មលើអនីតិជន ។ ដូចនេះ

[22] មាត្រា ២២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[23] មាត្រា ២១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[24] មាត្រា ២៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អនីតិជនត្រូវបង្កើតកិច្ចសន្យាដោយខ្លួនឯង ដោយមានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។

### ១.២.២.២ ជននៅក្រោមអាណាព្យាបាលទូទៅ

- **គោលគំនិត**

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាព ជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។

ដើម្បីក្លាយជាជនក្រោមអាណាព្យាបាលទូទៅពេញច្បាប់ ត្រូវមានលក្ខខណ្ឌ២យ៉ាងគឺ ការខ្វះសមត្ថភាពជានិរន្ត និងការប្រកាសអំពីការចាប់ផ្តើមពីតុលាការ។

<u>**ឧទាហរណ៍ ៖**</u> ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលមិនស្គាល់ឈ្មោះខ្លួនឯង គ្រួសារ សាច់ញាតិរបស់ខ្លួន ឬទីកន្លែងដែលខ្លួនរស់នៅ ឬជនដែលស្ថិតនៅក្នុងស្ថានភាពមនុស្សរុក្ខជាតិជាដើម។

- **ការចាប់ផ្តើមអាណាព្យាបាលទូទៅ**

ចំពោះជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យ អំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតីតុលាការអាចប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅបានតាមពាក្យសុំរបស់សាមីខ្លួន សហព័ន្ធញាតិដែលស្ថិតក្នុង៤ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅដ្ឋានរបស់ជននោះ ឬតំណាងអយ្យការ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ១៥ឆ្នាំនៅពេលដែលមានពាក្យសុំ។

ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមហិតូបត្ថម្ភ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្តើម ហិតូបត្ថម្ភចំពោះជននោះ។

- **សិទ្ធិលុបចោលសកម្មភាព**

សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។

សកម្មភាពដែលបានធ្វើឡើង ដោយជននៅក្រោមអាណាព្យាបាលទូទៅ ដោយមានការយល់ព្រមពីអាណាព្យាបាលទូទៅ ក៏អាចលុបចោលបានដែរ។ ដោយសារតែអ្នកនៅក្រោមអាណាព្យាបាលទូទៅ ជាជនដែលខ្វះសមត្ថភាពខាងឆន្ទៈហេតុនេះហើយ ទោះបីជាអ្នកអាណាព្យាបាលទូទៅ បានយកព្រមដោយវិនិច្ឆ័យថា

អ្នកនៅក្រោមអាណាព្យាបាលទូទៅនោះ មានសមត្ថភាពខាងឆន្ទៈឡើងវិញក៏ដោយក៏ប៉ុន្តែអាចបាត់បង់ម្តងទៀតនូវ សមត្ថភាពខាងឆន្ទៈនោះពេលធ្វើសកម្មភាព។

- **ការលុបចោលអាណាព្យាបាលទូទៅ**

បើមូលហេតុដែលបានកំណត់ក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះបានរលាយ តុលាការត្រូវលុបចោលនូវការប្រកាស ចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួនសហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង៤ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ[25]។

### ១.២.២.៣ ជននៅក្រោមហិតូបត្ថម្ភ

- **គោលគំនិត**

ជននៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិនៃបញ្ញាស្មារតី ។ ដើម្បីក្លាយជាជននៅក្រោមហិតូបត្ថម្ភពេញច្បាប់ត្រូវមានលក្ខខណ្ឌពីរយ៉ាង គឺមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី និងការប្រកាសពីតុលាការ។

**ឧទាហរណ៍ ៖** ជនដែលស្ថិតនៅក្រោមហិតូត្ថបត្ថម្ភមានដូចជា ជនដែលមានសតិទន់ខ្សោយ មនុស្សជរាជាដើម។

ជននៅក្រោមហិតូបត្ថម្ភ មានលក្ខណៈខុសគ្នានឹងជននៅក្រោមអាណាព្យាបាលទូទៅគឺជននៅ ក្រោមហិតូបត្ថម្ភ មានស្មារតី និងសមត្ថភាពតិចតួចក្នុងការយល់ដឹង ក៏ប៉ុន្តែជននៅក្រោមអាណាព្យាបាលទូទៅខ្វះសមត្ថភាពខាងឆន្ទៈជានិរន្តរ៍។

- **ការចាប់ផ្តើមហិតូបត្ថម្ភ**

ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតីតុលាការអាចប្រកាស ការចាប់ផ្តើមហិតូបត្ថម្ភលើកជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ដែលស្ថិតនៅក្នុង៤ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។

[25] មាត្រា ២៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅចំពោះជននោះ[26]។

- **សិទ្ធិលុបចោលសកម្មភាព**

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពដែលបានធ្វើឡើងដោយជននៅក្រោមហិតូបត្ថម្ភ ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ ដូចខាងក្រោមនេះ អាចលុបចោលបាន[27]៖

- ការទទួលឬការប្រើប្រាស់ទុន។
- ការខ្ចីទ្រព្យឬការធានា។
- ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុឬទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត។
- ការធ្វើសកម្មភាពបណ្ដឹង។
- ការធ្វើប្រទានកម្មឬធ្វើកិច្ចសន្យាស្រុះស្រួលឬកិច្ចសន្យាមជ្ឈត្តកម្ម។
- ការទទួលស្គាល់នូវសន្តកម្មឬការបោះបង់ចោលនូវសិទ្ធិសន្តតិកម្មឬការចែកនូវមត៌ក។
- ការប្រកែកមិនព្រមទទួលប្រទានកម្មឬអច្ច័យទានឬការយល់ព្រមទទួលនូវប្រទានកម្ម ឬអច្ច័-យទានដែលភ្ជាប់នឹងបន្ទុក។
- ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែមឬការជួសជុលធំ។
- ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី៣ឆ្នាំចំពោះដីធ្លី លើសពី២ឆ្នាំចំពោះអគារ លើសពី៦ខែចំពោះចលនវត្ថុ។
- សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថ-ម្ភកៈតាមពាក្យសុំ របស់ជនដែលអាចសុំតុលាការក្នុងការចាប់ផ្ដើមហិតូបត្ថម្ភ។

- **ការលុបចោលហិតូបត្ថម្ភ**

បើមូលហេតុដែលបានកំណត់ក្នុងមាត្រា ២៨ នៃក្រមរដ្ឋប្បវេណី បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភតាមពាក្យសុំរបស់សាមីខ្លួន សហព័ន្ធ ញាតិដែលស្ថិតក្នុង៤ថ្នាក់ អ្នកអាណា

[26] មាត្រា ២៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[27] មាត្រា ៣០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ[28]។

### ១.២.២.៤ ការការពារភាគីម្ខាងទៀត

- **សិទ្ធិដាស់តឿន**

កិច្ចសន្យាដែលធ្វើឡើងដោយជនដែលត្រូវបានកម្រិតសមត្ថភាពតែឯង មានសុពលភាពដែរ ប៉ុន្តែអាចលុបចោលបាន ហេតុនេះហើយ ចំពោះភាគីម្ខាងទៀតទំនាក់ទំនងគតិយុត្ត និងមានភាពខុសគ្នាទៅតាមការដែលថា តើភាគីខាងជនដែលត្រូវកម្រិតនូវសមត្ថភាពលុបចោល ឬមិនលុបចោលនូវកិច្ចសន្យានោះ ដូច្នេះនេះគឺជាស្ថានភាពដែលពុំមានស្ថិរភាពសោះ។ ហេតុនេះហើយ បានជា មាត្រា ៣២ នៃក្រមរដ្ឋប្បវេណី បានចែងពីសិទ្ធិដាស់តឿនដល់ភាគីម្ខាងទៀតនៃជនដែលត្រូវកម្រិតនូវសមត្ថភាព ដើម្បីធ្វើអោយមានការកំណត់ ឲ្យបានច្បាស់ពីទំនាក់ទំនងគតិយុត្តនោះអោយបានឆាប់រហ័ស។

យោងតាមមាត្រា ៣២ នៃក្រមរដ្ឋប្បវេណី សិទ្ធិដាស់តឿនមាន៣ប្រភេទ ៖

- ភាគីម្ខាងទៀត អាចធ្វើការដាស់តឿន ចំពោះអ្នកដែលការពារជន ដែលត្រូវបានកម្រិតនូវសមត្ថភាព ដោយមានរយៈពេល១ខែ សម្រាប់ពិចារណា ដើម្បីធ្វើការផ្តល់ ឬមិនផ្តល់នូវសច្ចានុមតិ ហើយប្រសិនបើមិនមានចម្លើយទេ ត្រូវចាត់ទុកថាបានផ្តល់សច្ចានុមតិ។
- ភាគីម្ខាងទៀតអាចធ្វើការដាស់តឿន អោយជននៅក្រោមហិតូបត្ថម្ភទទួលយក សច្ចានុមតិពីហិតូបត្ថម្ភក្នុងរយៈពេល១ខែ ដើម្បីធ្វើការផ្តល់ ឬមិនផ្តល់នូវសច្ចានុមតិ ប្រសិនបើមិនមានចម្លើយទេ ត្រូវចាត់ទុកថាជននោះបានលុបចោលសកម្មភាពនោះ។
- ក្នុងករណីដែលជនដែល ត្រូវបានកម្រិតនូវសមត្ថភាពបានក្លាយជាសមត្ថជនវិញភាគី ម្ខាងទៀតត្រូវដាស់តឿនចំពោះជននោះតែម្តង ដើម្បីធ្វើការផ្តល់ ឬមិនផ្តល់នូវសច្ចានុមតិ ហើយប្រសិនបើមិនមានចម្លើយទេ ត្រូវចាត់ទុកថាបានផ្តល់សច្ចានុមតិ។

- **ការឆបោករបស់ជនដែលត្រូវបានកម្រិតសមត្ថភាព**

---
[28] មាត្រា ៣១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ប្រសិនបើជនត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោកដើម្បីឲ្យគេជឿជាក់ ថាខ្លួនជាសមត្ថជន ជននោះមិនអាចលុបចោលសកម្មភាពបានទេ[29]។ មធ្យោបាយឆបោក ត្រូវបានប្រើ ដោយទាក់ទងនឹងសមត្ថភាពក្នុងការធ្វើកិច្ចសន្យា។

**ឧទាហរណ៍ ៖** អនីតិជនបាននិយាយថា ខ្លួនមានអាយុ២០ឆ្នាំ ដោយបង្ហាញនូវអត្តសញ្ញាណបណ្ណ័ក្លែងក្លាយ នៅពេលដែលធ្វើកិច្ចសន្យា។

### ១.៣ កម្មវត្ថុ

#### ១.៣.១ ភាពខុសច្បាប់

យោងតាមមាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណី ទោះបីជាភាគីនៃកិច្ចសន្យា បានធ្វើការបង្ហាញឆន្ទះដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវចាត់ទុកជាមោឃៈប្រសិនបើអត្ថន័យនៃកិច្ចសន្យានោះផ្ទុយ នឹងបញ្ញត្តិដែលត្រូវអនុវត្តដោយបង្ខំណាមួយ។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីជាធម្មតា គឺជាបញ្ញត្តិដែលមិនអនុញ្ញាតដោយបង្ខំ ហេតុនេះហើយ ទើបភាគីនៃកិច្ចសន្យាអាចយកព្រមពីអ្វីដែលខុសពីបញ្ញត្តិនេះបាន។

#### ១.៣.២ ភាពផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ

យោងតាមមាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណី ទោះបីជាភាគីនៃកិច្ចសន្យា បានធ្វើការបង្ហាញឆន្ទះដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវចាត់ទុកជាមោឃៈប្រសិនបើអត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ។ ខ្លឹមសារនៃសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ មិនអាចបញ្ជាក់អោយបានច្បាស់លាស់នៅក្នុងច្បាប់ទេ តែវាគួរត្រូវសម្រេចដោយយុត្តិសាស្ត្រ។

ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយ នឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងទៀត ក៏មិនអោយខូចសេចក្ដីសង្ឃឹមសមហេតុសមផលរបស់គូភាគីទេនោះ មានតែចំណុចដែលផ្ទុយនឹង បញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ តែប៉ុណ្ណោះទេដែលត្រូវទុកជាមោឃៈ[30]។

មោឃៈភាពនៃកិច្ចសន្យាធ្វើឲ្យផលប៉ះពាល់ បុគ្គលជាច្រើនដែលមានផលប្រយោជន៍ ដែលធ្វើសកម្មភាពដោយគិតថា កិច្ចសន្យានោះមានសុពលភាព ដើម្បីកាត់បន្ថយការប៉ះពាល់ នៃបញ្ហាមោឃភាពឱ្យបានច្រើន វាជាការសមរម្យដែលត្រូវទុកមោឃភាពតែផ្នែកដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ប៉ុណ្ណោះ។ មោឃភាពនេះត្រូវបានគេហៅថាមោឃភាពមួយផ្នែក។

---

[29] មាត្រា ៣៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[30] មាត្រា ៣៥៤ (២) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ១.៣.៣ អលទ្ធភាពតាំងពីដំបូង

ទោះបីជាអត្ថន័យនៃកិច្ចសន្យា មិនអាចសម្រេចបាន តាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះមិនត្រូវបានចាត់ទុកថាជាមោឃៈ ដោយយកមូលហេតុ អលទ្ធភាពនោះដែរ។ ប៉ុន្តែ បញ្ហានេះមិនរារាំងភាគីក្នុងការលុបចោលនូវកិច្ចសន្យា ដោយយកមូលហេតុនៃការភាន់ច្រឡំឡើយ ក្នុងករណីដែលលក្ខខណ្ឌនៃការភាន់ច្រឡំត្រូវបានបំពេញ[31]។ អលទ្ធភាពតាំងពីដំបូងមានន័យថា នៅពេលកិច្ចសន្យាត្រូវបានបង្កើតមានភាពច្បាស់លាស់ជាស្ថាពរថា ការអនុវត្តកិច្ចសន្យានោះ មិនអាចធ្វើបានទេ។

ក្នុងករណីដែលភាគីគួរតែអាចដឹងថា អត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចតាំងពីដំបូងបាន នាំឲ្យមានការខូចខាតដល់ ភាគីម្ខាងទៀតដោយសារការបង្កើតកិច្ចសន្យាភាគីនោះ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់ភាគីម្ខាងទៀត[32]។

**<u>ឧទាហរណ៍ ៖</u> ក** មានបំណង់ចុះកិច្ចសន្យាទិញលក់រថយន្តជាមួយ **ខ** តែមុនពេលចុះកិច្ចសន្យាមួយថ្ងៃរថយន្តត្រូវបានចោលលួចយកទៅបាត់។ ក្នុងករណីនេះ **ក** ដែលជាអ្នកលក់រថយន្តមិនចាំបាច់ទទួលខុសត្រូវពីអលទ្ធភាពក្នុងការអនុវត្តទេ តែ **ក** គួរតែដឹងអំពីការលួចរថយន្តនេះ និងបានផ្តល់ដំណឹងទៅការភាគីម្ខាងទៀតនោះមិនចាំបាច់ឱ្យ **គ** ធ្វើកិច្ចសន្យាដែលគ្មានប្រយោជន៍នោះទេ ។

### ១.៤ តម្លៃតបស្នង

តម្លៃតបស្នង[33] គឺជាការចរចាដើម្បីដោះដូរនូវអ្វីដែលមានតម្លៃតាមច្បាប់។ មានន័យថា តម្លៃតបស្នងគឺជាការលះបង់ផលប្រយោជន៍ តាមផ្លូវច្បាប់របស់ភាគីនីមួយៗចំពោះកិច្ចសន្យា។ ដូច្នេះត្រូវតែមានការដូរ តែអំណោយមិនមែនជាការចរចាដើម្បីដោះដូរទេ ហើយក៏មិនមែនជាតម្លៃតបស្នងដែរ។ ជាទូទៅវត្ថុខ្លះមានតម្លៃតបស្នងតាមច្បាប់ បើវាតម្រូវអោយភាគីដែលផ្តល់តម្លៃតបស្នងដើម្បី ៖

- ធ្វើអ្វីដែលខ្លួនគ្មានកាតព្វកិច្ចតាមច្បាប់និងធ្វើ។
- មិនធ្វើអ្វីដែលខ្លួនមានសិទ្ធិស្របច្បាប់និងធ្វើ។

ដូចនេះ តម្លៃតបស្នងអាចត្រូវបានដោះដូរក្នុងរូបភាពជាប្រាក់ ទំនិញសេវាកម្ម ឬជាទ្រព្យផ្សេងៗទៀត។

សរុបសេចក្តីមក ដើម្បីអោយមានតម្លៃតបស្នងស្របច្បាប់ ភាគីម្ខាងៗនៃកិច្ចសន្យា ត្រូវមានការខាតបង់ផលប្រយោជន៍ស្របច្បាប់មួយ ហើយត្រូវទទួលបានផលប្រយោជន៍ស្របច្បាប់ មួយវិញទៀត។

[31] មាត្រា ៣៥៥ (១) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[32] មាត្រា ៣៥៥ (២) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[33] ឯកសារបណ្ណះបណ្តាលរបស់ ADB មូលដ្ឋានគ្រឹះនៃច្បាប់ពាណិជ្ជកម្ម

ជាទូទៅ តុលាការមិនសាកសួរពីភាពសមរម្យនៃតម្លៃតបស្នងទេ ដោយហេតុថា តុលាការមិនចង់ពិនិត្យឲ្យល្អិតល្អន់លើតាវកាលិកតបនោះទេ ពីព្រោះតុលាការមិនចង់រំខានដល់សិទ្ធិរបស់ភាគីក្នុងការចុះកិច្ចសន្យាដោយសេរីនោះទេ។ ច្បាប់កម្ពុជាយើងក៏មាននិយាយពីតម្លៃតបស្នងផងដែរដូចជា ៖ ក្នុងករណីដែលភាគីម្ខាងថាបានធ្វើកិច្ចសន្យា ឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ ឬការខ្វះការពិសោធន៍ហើយបានកេងយកចំណេញ យ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ[34]។

នៅពេលចុះកិច្ចសន្យា កាលណាមានភាពខុសគ្នាមិនសមស្របរវាងតម្លៃនៃតាវកាលិក និងតម្លៃតាវកាលិកតបវិញ ភាគីរងគ្រោះអាចប្ដឹងបដិសេធកិច្ចសន្យាបានក្នុងលក្ខណៈដែលខ្លួនពុំដែលមានបំណងធ្វើអំណោយទេនោះ[35]។

តាមរយៈអត្ថបទទាំងពីរខាងលើនេះ អាចបញ្ជាក់យ៉ាងច្បាស់ថា តម្លៃតបស្នង គឺជាធាតុផ្សំមួយដែលធ្វើឲ្យកិច្ចសន្យាមានសុពលភាព។

## ផ្នែកទី២ ៖ លក្ខខណ្ឌទម្រង់

កិច្ចសន្យា អាចត្រូវបានធ្វើដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ប៉ុន្តែកិច្ចសន្យាមួយចំនួន ដែលច្បាប់បានតម្រូវឲ្យធ្វើជាទម្រង់លាយលក្ខណ៍អក្សរ ទើបមានសុពលភាពគតិយុត្ត។

### ២.១ កិច្ចសន្យាធ្វើដោយផ្ទាល់មាត់

#### ២.១.១ និយមន័យ

កិច្ចសន្យាធ្វើឡើងដោយផ្ទាល់មាត់ គឺជាកិច្ចសន្យាដែលធ្វើឡើងដោយការនិយាយ រវាងគូភាគីនៃកិច្ចសន្យាដោយមិនធ្វើជាលាយលក្ខណ៍អក្សរទេ ហើយក៏មានសុពលភាពដែរ។

**ឧទាហរណ៍ ៖** កិច្ចសន្យាទិញសៀវភៅ កិច្ចសន្យាទិញទឹក កិច្ចសន្យាទិញនំ ជាដើម។

#### ២.១.២ គុណសម្បត្តិមាន

- លក្ខណៈសាមញ្ញងាយយល់
- មានភាពងាយស្រួលក្នុងការបង្កើតនិងចំណាយពេលខ្លី។

#### ២.១.៣ គុណវិបត្តិ

- ចំណងគតិយុត្តមិនសូវច្បាស់លាស់។

[34] មាត្រា ៣៥១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[35] មាត្រា ១២ ក្រឹត្យច្បាប់លេខ៣៨ ក្រ.ច ស្ដីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា

- ពិបាកក្នុងការបង្ហាញនូវភស្តុតាង នៅក្នុងករណីដែលមានវិវាទក្រោយពេលកិច្ចសន្យាត្រូវបានបង្កើត។

## ២.២ កិច្ចសន្យាធ្វើឡើងដោយលាយលក្ខណ៍អក្សរ

### ២.២.១ និយមន័យ

កិច្ចសន្យាធ្វើឡើងដោយលាយលក្ខណ៍អក្សរ គឺជាកិច្ចសន្យាដែល ត្រូវបានសរសេរជាលាយលក្ខណ៍អក្សរដោយគូភាគីនៃកិច្ចសន្យា។ ជាទូទៅត្រូវមាន ចុះកាលបរិច្ឆេទព្រមទាំងស្នាមមេដៃរបស់ភាគីទាំងពីរនាក់ និងស្នាមមេដៃរបស់សាក្សីផងដែរ។

ការធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ភាគីប្រើចំពោះកិច្ចសន្យាដែលមានកម្មវត្ថុមានតម្លៃខ្ពស់ ហើយមានប្រភេទកិច្ចសន្យាមួយចំនួន ច្បាប់តម្រូវឲ្យធ្វើជាលាយលក្ខណ៍អក្សរ។

**ឧទាហរណ៍៖** កិច្ចសន្យាគ្រប់ប្រភេទស្តីពីប្រាក់ ឬវត្ថុដែលមានចំនួន ឬមានតម្លៃលើសពី ៥,០០០ រៀល ត្រូវធ្វើជាលាយលក្ខណ៍អក្សរ[36]។

កិច្ចសន្យាជាលាយលក្ខណ៍អក្សរ ត្រូវបានចែកជាពីរប្រភេទដូចជា៖ **លិខិតយថាភូត និងលិខិតឯកជន** ។

- លិខិតយថាភូត គឺជាលិខិតធ្វើឡើងតាមរូបមន្តច្បាប់ដោយ មន្ត្រីសាធារណៈ ដែលត្រូវបានប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀត គឺជាលិខិតទាំងឡាយណាដែលរៀបចំឡើងដោយសារការី ។
- លិខិតឯកជន គឺជាលិខិតទាំងឡាយណា ដែលបង្កើតឡើងដោយបុគ្គលឯកជន ដោយមានហត្ថលេខា ឬស្នាមមេដៃ។

### ២.២.២ គុណសម្បត្តិ

កិច្ចសន្យាធ្វើដោយលាយលក្ខណ៍អក្សរ មានគុណសម្បត្តិមួយចំនួនដូចជា ៖

- អត្ថិភាពរបស់វា មិនអាចត្រូវបានបដិសេធដោយងាយស្រួលពីភាគីណាមួយទេ ពីព្រោះកិច្ចសន្យាត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ ខ្មែរដែលយើងអាចយកមកធ្វើជាភស្តុតាងបាន នៅពេលមានវិវាទកើតឡើង។

[36]មាត្រា ៤ ក្រឹត្យច្បាប់លេខ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា

- កាតព្វកិច្ចទាំងឡាយរបស់ភាគី ត្រូវបានកំណត់យ៉ាងច្បាស់លាស់ ។ នេះជាកត្តាមួយដែល មិនធ្វើឱ្យភាគីនៃកិច្ចសន្យាមានការច្រឡំ ឬក៏ភ្លេចអត្ថន័យ នៃកិច្ចសន្យាឡើយហើយ នឹងធ្វើឱ្យ ភាគីដឹងយ៉ាងច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់គេ ។
- ការធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ បានធ្វើអោយភាគីកិច្ចសន្យាធ្វើការពិចារណា យ៉ាង យកចិត្តទុកដាក់ក្នុងការបង្កើតកិច្ចសន្យា។

**២.២.២ គុណវិបត្តិ**

កិច្ចសន្យាធ្វើដោយលាយលក្ខណ៍អក្សរ មានគុណវិបត្តិ ដោយហេតុថា ភាគីនៃកិច្ចសន្យា ត្រូវចំណាយពេលវេលាច្រើន និងចំណាយថវិកាច្រើន ដោយហេតុថាជាទូទៅបុគ្គលដែលមានសមត្ថភាពក្នុងការតាក់តែងកិច្ចសន្យា គឺមានតែមេធាវី សារការីនិង បុគ្គលដែលមានចំណេះដឹងផ្នែកច្បាប់ដទៃទៀតទេ។

# ជំពូកទី ៣ ៖ ការអនុវត្តកិច្ចសន្យា

## កថាខណ្ឌទី ១ ៖ ការអនុវត្តកិច្ចសន្យា

### ១.១.ករណីកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច

កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនអោយស្របទៅតាម ខ្លឹមសារនៃកិច្ចសន្យា និងគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់[37]។ ការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ត្រូវចាត់ទុកជាការសង ដែលនាំអោយកាតព្វកិច្ចរលត់។

**<u>ឧទាហរណ៍ ៖</u> ក** ជំពាក់ ខ ១០០$ (មួយរយដុល្លាអាមេរិក) ដែលត្រូវកំណត់សងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ ដូច្នេះពេលថ្ងៃកំណត់សងមកដល់ **ក** ត្រូវសង **ខ** ដោយសុចរិត និងភាព ស្មោះត្រង់។

### ១.២. សិទ្ធិទាមទាររបស់ម្ចាស់បំណុលអោយអនុវត្តកាតព្វកិច្ច

ម្ចាស់បំណុលអាចទាមទារអោយកូនបំណុល អនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ[38] ប៉ុន្តែជាទូទៅ ភាគីទាំងសងខាងមិនចង់ទៅតុលាការនោះទេ ដោយហេតុថា នៅតុលាការត្រូវការចំណាយថវិកាច្រើន ពេលវេលាយូជាពិសេស នីតិវិធីស្មុគស្មាញ ដូច្នេះភាគីតែងតែចង់ដោះស្រាយវិវាទ របស់ពួកគេអោយអស់លទ្ធភាពទើបពួកគេទៅតុលាការ។

[37] មាត្រា ៣៨៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[38] មាត្រា ៣៨៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឧទាហរណ៍ ៖ ក** ជំពាក់លុយ **ខ** ចំនួន ៥០០០$ (ប្រាំពាក់ដុល្លាអាមេរិក) ថ្ងៃដែលត្រូវសងលុយ បានកន្លងផុតទៅច្រើនថ្ងៃហើយ តែ **ក** នៅតែមិនសងលុយនោះទៀត ទោះបីជា **ខ** ព្យាយាមលួងលោមដើម្បីអោយ **ក** សងលុយក៏ដោយ ក៏ **ក** នៅតែមិនសង។ ដូច្នេះ **ខ** អាចដាក់ពាក្យបណ្ដឹងទៅតុលាការ ដើម្បីបង្ខំអោយ **ខ** សងលុយ។

**១.៣. ការតវ៉ាអោយអនុវត្តព្រមគ្នា**ភាគីនីមួយៗនៃកិច្ចសន្យាអញ្ញមញ្ញ អាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនរហូតដល់ពេល ដែលភាគីម្ខាងទៀតផ្ដល់នូវការអនុវត្តកាតព្វកិច្ច។ ប៉ុន្តែបញ្ញាត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់ភាគីម្ខាងទៀតមិនទាន់ដល់ពេលកំណត់ដើម្បីអនុវត្ត[39]។

ការតវ៉ាអោយអនុវត្តព្រមគ្នារវាងកូនបំណុល និងម្ចាស់បំណុល មានសារៈសំខាន់ណាស់ ដោយសារជំរុញអោយមានការអនុវត្តកាតព្វកិច្ច និងជៀសវាងនូវការខូចខាត ក្នុងករណីមិនកាតព្វកិច្ច ប្រសិនបើមិនមានការតវ៉ាអោយអនុវត្តព្រមគ្នាក្នុងកិច្ចសន្យា អញ្ញមញ្ញនោះទេ គឺធ្វើអោយមានភាពមិនស្មើគ្នាក្នុងការអនុវត្តកាតព្វកិច្ចកើតឡើង ពីព្រោះភាគីម្ខាង មិនមានសិទ្ធិតវ៉ា ក្នុងករណីដែល ភាគីម្ខាងទៀត មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

**ឧទាហរណ៍ ៖ ក** ទិញម៉ូតូពី **ខ** ក្នុងតំលៃ ២០០០$ (ពីរពាន់ដុល្លាអាមេរិក) នៅពេលដែលថ្ងៃប្រគល់ម៉ូតូបានមកដល់ **ក** អាចបដិសេធមិនប្រគល់លុយបាន ប្រសិនបើ **ខ** មិនបានប្រគល់ម៉ូតូ ឬក៏ **ខ** អាចបដិសេធមិនប្រគល់ម៉ូតូបាន ប្រសិនបើ **ក** មិនបានប្រគល់លុយ ។ លើកលែងតែ ភាគី បានកំណត់អំពីការអនុវត្តកាតព្វកិច្ចនៅថ្ងៃខុសគ្នា។

**ឧទាហរណ៍៖** ប្រគល់លុយមុន ប្រគល់ម៉ូតូ ដូចនេះ ត្រូវតែប្រគល់លុយមុននឹងប្រគល់ម៉ូតូតាមក្រោយដោយមោនមានការតវ៉ាអោយអនុវត្តព្រមគ្នាបានទេ។

**១.៤. ការតវ៉ាដោយមានការបារម្ភ**

ភាគីដែលត្រូវអនុវត្តកាតព្វកិច្ចជាមុន នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ អាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន ក្នុងករណីដែលមានការបារម្ភដែលគួរអោយកត់សម្គាល់ថា ភាគីម្ខាងទៀតនឹងមិនអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច ។ ប៉ុន្តែ បញ្ញាត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដាក់ប្រាតិភោគ ឬចាត់ចែងវិធានការផ្សេងទៀត ដើម្បីរំលត់ការបារម្ភនោះ[40]។

---

[39] មាត្រា ៣៨៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[40] មាត្រា ៣៨៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្នុងករណីដែលភាគីមានការបារម្ភថា ភាគីម្ខាងទៀតនឹងមិនអនុវត្តកាតព្វកិច្ចតប ប្រសិនបើភាគីដែលត្រូវអនុវត្តកាតព្វកិច្ចមុន អនុវត្តកាតព្វកិច្ច ភាគីនោះនឹងអាចទទួលនូវការខូចខាត នៅពេលដែលភាគីម្ខាងទៀតមិនអនុវត្តកាតព្វកិច្ចតប។ ម៉្យាងវិញទៀត ភាគីដែលត្រូវអនុវត្តកាតព្វកិច្ចមុន មិនអាចទាមទារ ការតវ៉ាអោយអនុវត្តព្រមគ្នាទេ។ ដូច្នេះចាំបាច់ត្រូវតែមាន ការតវ៉ាដោយមានការបារម្ភ ដើម្បីការពារភាគីដែលមានកាតព្វកិច្ចត្រូវអនុវត្តមុននោះ ខ្លាចក្រែងថា ភាគីម្ខាងទៀតមិនព្រមអនុវត្តកាតព្វកិច្ចតប។

<u>**ឧទាហរណ៍ ៖**</u> **ក** បានលក់រថយន្ត អោយទៅ **ខ** នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ ហើយពួកគាត់បានព្រមព្រៀងគ្នាថា **ក** ត្រូវប្រគល់រថយន្តនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៥ ហើយ **ខ** ត្រូវបង់ប្រាក់នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ក៏ប៉ុន្តែនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ ខ បានក្ស័យធន ។ ក្នុងករណីនេះ **ក** អាចអះអាងអំពីការតវ៉ាដោយមានការបារម្ភ ហើយបដិសេធការប្រគល់រថយន្តរបស់ខ្លួនទៅអោយ ខ ដោយសារការក្ស័យធនរបស់ **ខ** ដោយខ្លាច **ខ** មិនមានលុយដើម្បីប្រគល់អោយខ្លួននៅពេលដល់កំណត់តម្រូវប្រគល់។ ក៏ប៉ុន្តែប្រសិនបើ **ខ** បានដាក់ប្រាតិភោគ ដូចជា ផ្ទះ ដើម្បីធានាកាតព្វកិច្ច ដូចនេះ **ក** មិនអាចបដិសេធការអនុវត្តកាតព្វរបស់ខ្លួនឡើយ។

## កថាខណ្ឌទី២ ៖ មោឃភាព និងការលុបចោល

### ១. មោឃភាព

#### ១.១ គោលគំនិត

ប្រសិនបើអត្ថន័យនៃសម្មភាព ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹង សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អជនណាក៏ដោយក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបក្នុងករណីដែលសកម្មភាពត្រូវបានចាត់ទុកជាមោឃភាពដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារអោយមានដោយក្រមនេះ ឬច្បាប់ផ្សេង ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន[41]។

<u>**ឧទាហរណ៍ ៖**</u> នៅក្នុងករណីកិច្ចសន្យាលក់ទិញមនុស្ស ត្រូវចាត់ទុកជាមោឃៈ ព្រោះវាផ្ទុយនឹងច្បាប់ដែលហាមឃាត់ការជួញដូរមនុស្ស។

<u>**ឧទាហរណ៍ ៖**</u> មតកសាសន៍ ដែលមិនស្របទៅនឹងទំរង់ដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ត្រូវចាត់ទុកជាមោឃៈ (មាត្រា១១៧០នៃក្រមរដ្ឋប្បវេណី)។

[41] មាត្រា ៣៥៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ម្យ៉ាងវិញទៀត កិច្ចសន្យាដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ[42]។

### ១.២ អានុភាព

សកម្មភាពដែលទុកជាមោឃៈ មិនមានអានុភាពតាំងពីដំបូង ចាប់តាំងពីពេលធ្វើសកម្មភាព ។ ប្រសិនបើភាគីបានអនុវត្តកាតព្វកិច្ច ដោយផ្អែកលើកិច្ចសន្យា ដែលត្រូវទុកជាមោឃៈ ជាទូទៅភាគីម្ខាងទៀតត្រូវសងតាវកាលិកនោះវិញ ដោយផ្អែកសេចក្តីចម្រើនឥតហេតុ។ ក៏ប៉ុន្តែ ក្នុងករណីដែលការទាមទាររបស់បុគ្គល ដែលត្រូវខូចខាតផលប្រយោជន៍ ចំពោះបុគ្គល ដែលបានទទួលផលប្រយោជន៍នោះ ផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬទំនៀមទម្លាប់ល្អ ឬច្បាប់ដែលទាក់ទងនឹងសណ្តាប់ធ្នាប់សាធារណៈ ការទាមទារឱ្យសងនោះពុំត្រូវបានអនុញ្ញាតឡើយ (មាត្រា៧៤១នៃក្រមរដ្ឋប្បវេណី)។

ផ្ទុយទៅវិញ មោភាពដោយសារការបង្ហាញឆន្ទៈមិនពិត ជាទូទៅគឺមិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះ ជាជនទុច្ចរិត ឬមិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសឆ្គងធ្ងន់ធ្ងរ[43]។ នេះជាករណីលើកលែងដ៏សំខាន់មួយ។

ម្យ៉ាងវិញទៀត គេអាចផ្តល់សច្ចសន្ទមតទៅលើសកម្មភាពដែលចាត់ទុកជាមោឃៈបាន។ ប៉ុន្តែ ប្រសិនបើបញ្ញត្តិដែលអនុវត្តដោយបង្ខំ ជាមូលហេតុនៃមោឃភាពនៃសកម្មភាពនោះនៅតែមានអានុភាព នៅពេលផ្តល់សច្ចានុម័ត ឬការវាយតម្លៃអំពីភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អនោះ គឺនៅតែមិនមានការផ្លាស់ប្តូរនៅពេលផ្តល់សច្ចានុម័ត ទោះបីជាសកម្មភាពនោះត្រូវបានផ្តល់សច្ចានុម័តក៏ដោយ ក៏ត្រូវបានចាត់ទុកជាមោឃៈដែរ។

### ១.៣ មោឃភាពដោយផ្នែក

ប្រសិនបើអត្ថន័យន័យកិច្ចសន្យា មានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិ ដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងៗទៀតក៏មិនធ្វើឱ្យខូចសេចក្តីសង្ឃឹមសមហេតុផលរបស់ភាគីទេនោះ មានតែចំណុចដែលផ្ទុយនឹង បញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹង

[42] មាត្រា ៣៥៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[43] មាត្រា ៣៥៣(២) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ប៉ុណ្ណោះដែលត្រូវទុកជាមោឃៈ ដែលហៅថាជាមោឃភាពមួយផ្នែក[44]។

**ឧទាហរណ៏ ៖** មាត្រា៥៨៥ កថាខណ្ឌទី៣ បានចែងថា ប្រសិនបើអត្រាការប្រាក់ដែលព្រមព្រៀង លើសពីអត្រាការប្រាក់ដែលបានកម្រិត ការព្រមព្រៀងនោះត្រូវទុកជាមោឃៈ ប៉ុន្តែ អ្នកខ្ចី មានករណីកិច្ចសង ចំពោះតែការប្រាក់ដែលត្រូវបានគណនា តាមអត្រាការប្រាក់ដែលត្រូវបានកម្រិតនោះតែប៉ុណ្ណោះ។

### ១.៤ បុគ្គលដែលអាចអះអាងលើមោឃភាព

យោងតាមមាត្រា៣៥៧ នៃក្រមរដ្ឋប្រវេណី គោលបំណងនៃមោឃភាពគឺដើម្បីកុំឱ្យមានកិច្ចសន្យា ឬសកម្មភាពឯកតោភាគី (អច្ច័យទាន) ដែលផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ ឬសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ និងមោឃភាព ក្នុងករណីដែលផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារដោយច្បាប់។ ដូច្នេះហើយ ជនណាក៏អាចអះអាងពីមោឃភាពនៃសកម្មភាពនោះបានគ្រប់ពេលដោយមិនមានអាជ្ញាយុកាលរំលត់ឡើយ។

## ២.ការលុបចោល

### ២.១. គោលគំនិត

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[45]។ ការបង្ហាញឆន្ទៈដោយមានវិការៈមានដូចជា ការភាន់ច្រឡំ ការឆបោក ពត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព ការគម្រាមកំហែង និងអំពើកេងយកចំណេញហួសហេតុ។

### ២.២. អានុភាព

សកម្មភាពដែលអាចលុបចោលបាន មានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ។ ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង[46]។ យើងអាចនិយាយបានថា សកម្មភាពដែលអាចលុបចោលបានមានសុពលភាព ហើយការលុបចោល គឺជាការបង្ហាញឆន្ទៈក្នុងការបដិសេធនូវអានុភាពនោះ ។ អានុភាពនៃការលុបចោល គឺជាការបង្ហាញឆន្ទៈក្នុងការបដិសេធនូវអានុភាពនោះ។អានុភាពនៃការលុបចោល ត្រូវកើតឡើងនៅពេលដែលដំណឹងនោះ បានដល់ភាគីម្ខាងទៀត (មាត្រា៣៦០ ក្រមរដ្ឋប្បវេណី)។

[44] មាត្រា ៣៥៤(២) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[45] មាត្រា ៣៤៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[46] មាត្រា ៣៥៨(១)(២) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឧទាហរណ៍ ៖ ក** បានលក់ម៉ូតូ និងប្រគល់ឲ្យ **ខ** រួចហើយ ដោយសារតែ **ខ** បានឆបោកទៅលើ **ក** ប៉ុន្តែ **ក** មិនទាន់បានទទួលប្រាក់ទេ។ ក្រោយមក **ក** បានដឹងពីការឆបោកនេះ ហើយក៏លុបចោលកិច្ចសន្យានោះចោល។ ហេតុដូចនេះ កិច្ចសន្យាត្រូវចាត់ទុកថា មោឃៈតាំងពីដំបូង ដែលជាហេតុធ្វើឲ្យ **ខ** មិនមានមូលហេតុស្របច្បាប់ ក្នុងការកាន់កាប់ម៉ូតូនោះទៀតទេ ដូច្នេះ **ខ** ត្រូវប្រគល់ម៉ូតូមកឲ្យ **ក** វិញដោយសេចក្តីចម្រើនដោយឥតហេតុ។

### ២.៣. ជនដែលអាចលុបចោលបាន

#### ២.៣.១. ករណីវិការៈក្នុងការបង្ហាញឆន្ទៈ

ចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈដែលបានកំណត់ ចាប់ពីមាត្រា ៣៤៦ (ការភាន់ច្រឡំ) ដល់មាត្រា ៣៥១ (អំពើកេងយកចំណេញហួសហេតុ) នៃក្រមរដ្ឋប្បវេណីនេះ អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ អាចលុបចោលនូវសកម្មភាពនោះបាន។ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬអ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ[47]។

#### ២.៣.២. ករណីសមត្ថភាពក្នុងការបង្ហាញឆន្ទៈ

ចំពោះការលុបចោល ដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាព ឬការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផ្សេងទៀត សាមីខ្លួន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈនៃជននោះ អាចលុបចោលនូវសកម្មភាពបាន។ សន្តតិជន ឬអច្ច័យលាភិសកលរបស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

### ២.៤. ការផ្តល់សច្ចានុមតិ

#### ២.៤.១. គោលគំនិត

ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានផ្តល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវមានអានុភាពជាស្ថាពរ[48]។

#### ២.៤.២. អានុភាព

អានុភាពនៃសច្ចានុមតិ ត្រូវកើតឡើងនៅពេលដែលដំណឹងនោះបានដល់ភាគីម្ខាងទៀត (មាត្រា ៣៦០ ក្រមរដ្ឋប្បវេណី)។ ការផ្តល់សច្ចានុមតិនេះគឺជាសកម្មភាពឯកតោភាគី។

---

47 មាត្រា ៣៥៩(១) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

48 មាត្រា ៣៥៨(៣) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ២.៤.៣. ជនដែលអាចធ្វើសច្ចានុមតិ

អ្នកមានសិទ្ធិលុបចោល អាចផ្ដល់សច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន។ ប៉ុន្តែ ក្នុងករណីដែលលុបចោលសកម្មភាព ដោយយកការបង្ហាញឆន្ទៈដោយមានវិការៈជាមូលហេតុ អ្នកមានសិទ្ធិលុបចោល អាចផ្ដល់សច្ចានុមតិបានចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោលនោះ បានដឹងអំពីមូលហេតុនៃការលុបចោល។ រីឯសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពវិញ អ្នកមានសិទ្ធិលុបចោល អាចផ្ដល់សច្ចានុមតិបាន នៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវបានរលត់[49]។

**<u>ឧទាហរណ៍ ៖</u> ក** ជាអនីតិជន បានទិញកង់មួយតម្លៃ ១០០$ (មួយរយដុល្លាអាមេរិក) ពី **ខ** ដែលជានីតិជន។ ករណីនេះ ឪពុកម្ដាយរបស់ **ក** ជាអ្នកមានសិទ្ធិផ្ដល់សច្ចានុមតិ។ ក៏ប៉ុន្តែប្រសិនបើ **ក** បានក្លាយជានីតិជនវិញ គាត់ក៏អាចផ្ដល់សច្ចានុមតិបានដែរ។

### ២.៤.៤. សច្ចានុមតិដែលច្បាប់បានកំណត់

នៅក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានធ្វើនូវសកម្មភាពមួយចំនួនដែលច្បាប់បានកំណត់ គេអាចចាត់ទុកថាជាការផ្ដល់សច្ចានុមតិបាន (មាត្រា៣៦២ ក្រមរដ្ឋប្បវេណី)។

#### ២.៤.៤.១. ការអនុវត្តកាតព្វកិច្ច ឬការផ្ដល់នូវប្រាតិភោគ

ប្រសិនបើជន ដែលមានសិទ្ធិលុបចោល បានអនុវត្តកាតព្វកិច្ចទាំងមូល ឬមួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬបានដាក់ ប្រាតិភោគ ដើម្បីធានាកាតព្វកិច្ចនោះ នោះគាត់មិនអាចលុបចោលនូវសកម្មភាពដែលអាចលុបចោលបានទេ។

**<u>ឧទាហរណ៍ ៖</u> ក** បានបង្កើតកិច្ចសន្យាលក់ទិញម៉ូតូមួយគ្រឿង ដោយមានការភាន់ច្រឡំជាមួយ **ខ** ក្រោយពីបានដឹងអំពីការភាន់ច្រឡំហើយ **ក** នៅតែប្រគល់ម៉ូតូនោះឲ្យ **ខ** ទៀត។ក្នុងករណិនេះសកម្មភាពដែលអាចលុបចោលបានរបស់ **ក** ត្រូវចាត់ទុកថាបានផ្ដល់នូវសច្ចានុមតិ។

#### ២.៤.៤.២. ការអនុវត្តសិទ្ធិ ឬការទាមទារឲ្យអនុវត្តកាតព្វកិច្ច

នៅក្នុងករណីខាងលើ ទោះបីជា ក បានដឹងអំពីការភាន់ច្រឡំរបស់ខ្លួនក៏ដោយ ក បានទាមទារឲ្យ ខ បង់នូវប្រាក់ថ្លៃទិញ នៅមុនពេលប្រគល់ម៉ូតូ។នៅក្នុងករណីនេះ សកម្មភាពដែលអាចលុបចោលរបស់ ក ត្រូវចាត់ទុកថាបានផ្ដល់នូវសច្ចានុមតិ។

#### ២.៤.៤.៣. អនុប្បទាន ឬចាត់ចែងសិទ្ធិ

[49] មាត្រា ៣៦១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

នៅពេលបុគ្គលដែលមានសិទ្ធិលុបចោលការធ្វើអនុប្បទាន ឬចាត់ចែងសិទ្ធិដែលទទួលបានតាមរយៈសកម្មភាពដែលអាចលុបចោលបាន នោះគាត់មិនអាចលុបចោលសកម្មភាពនោះទៀតទេ។

**ឧទាហរណ៍ ៖** នៅក្នុងករណីខាងលើ ប្រសិនបើ **ក** បានផ្ទេរនូវសិទ្ធិទាមទារឲ្យបង់ប្រាក់ថ្លៃទិញទៅឲ្យតតិយជន នោះគាត់មិនអាចលុបចោលកិច្ចសន្យានោះបានទេ។

### ២.៥. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល

យោងតាមមាត្រា ៣៦៣ ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុង រយៈពេល៣ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ នោះសិទ្ធិលុបចោល និងសិទ្ធិទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារ ការលុបចោលនោះត្រូវរលត់។បញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាលមិនត្រូវយកមកអនុវត្តឡើងចំពោះអំឡុងពេលនេះ។ ប៉ុន្តែសិទ្ធិលុបចោលត្រូវរលត់ដោយអំឡុងពេល១០ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃសកម្មភាពនោះ។ ក្រោយពេលអាជ្ញាយុកាលរំលត់ ត្រូវបានបញ្ចប់ នោះជនដែលមានសិទ្ធិលុបចោល មិនអាចលុបចោលសកម្មភាព ដែលអាចលុបចោលនោះទៀតទេ ដូច្នេះសកម្មភាពនោះត្រូវចាត់ទុកថាមានសុពលភាពជាស្ថាពរ។

**ឧទាហរណ៍ ៖** **ក** បានលក់ផ្ទះឲ្យ **ខ** ដោយសារការឆបោករបស់ **ខ** បន្ទាប់ពីបានដឹងការឆបោកនេះក្នុងរយៈពេល៤ឆ្នាំក្រោយ ក បានអនុវត្តសិទ្ធិលុបចោល។ក្នុងករណីនេះសិទ្ធិលុបចោលរបស់ **ក** បានរលត់ទៅហើយ ដូច្នេះ **ក** មិនអាចលុបចោលសកម្មភាពនេះបានទេ។ ក្នុងករណីនេះដដែលប្រសិនបើ គាត់បានដឹងអំពីការឆបោកនេះក្នុងរយៈពេល១១ឆ្នាំ ក្រោយពីការឆបោក ហើយគាត់អនុវត្តសិទ្ធិលុបចោលភ្លាមក្នុងអំឡុងពេល៣ឆ្នាំក៏ដោយ ក៏សិទ្ធិលុបចោលរបស់គាត់ត្រូវរលត់ដែរ។

### ២.៦. ការប្រៀបធៀបរវាង មោឃភាព និងការលុបចោល

ជាសរុបមក មោឃភាព និងការលុបចោល មានភាពខុសគ្នាដូចតារាងទាញសេចក្តីសង្ខេបខាងក្រោម៖

| មោឃភាព | ការលុបចោល |
|---|---|
| ▪ មិនមានអានុភាពតាំងពីដំបូង | ▪ មានសុពលភាពរហូតដល់អ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ |
| ▪ ជនណាក៏អាចអះអាងពីមោឃភាពនោះបានដែរ | ▪ មានតែជនដែលមានសិទ្ធិលុបចោលទើបអាចលុបចោលឬផ្តល់សច្ចានុមតិលើសកម្មភាពនោះ |

| | |
|---|---|
| ▪ គ្មានអាជ្ញាយុកាល | ▪ ៣ ឆ្នាំ |
| ▪ ការពារសណ្តាប់ធ្នាប់សាធារណៈ | ▪ ការពារប្រយោជន៍របស់គូភាគី |

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់ការស្រាវជ្រាវយ៉ាងលំអិតទៅលើកិច្ចសន្យានៅប្រទេសកម្ពុជាក្នុងតំណើរវិវត្តន៍យ៉ាងច្រើនតំណាក់កាលបានបង្ហាញអោយយើងឃើញថា កិច្ចសន្យាមិនមែនជាសញ្ញាណថ្មីដែរទបនឹងកើតមានឡើងនៅលើរទឹកដីប្រទេសកម្ពុជានោះទេ។ កិច្ចសន្យាបានកើតមានឡើងតាំងពីយ៉ូណាស់មកហើយ ប៉ុន្តែគ្រាន់តែមិនមានទម្រង់ច្បាស់លាស់ដូចបច្ចុប្បន្នមិនតែប៉ុណ្ណោះយើងឃើញការលេចចេញជារូបរាងនភទម្រង់ និងការប្រតិបត្តិទៅកិច្ចសន្យា គឺត្រូវបានអនុវត្តន៍តាមការចែងនៅក្នុងក្រមរដ្ឋប្បវេណី។ មិនតែប៉ុណ្ណោះកិច្ចសន្យាដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍនប្រទេស និងការអនុវត្តស្ទើរគ្រប់វិស័យ ហើយការបង្កើតកិច្ចសន្យាមិនមែនអាចធ្វើឡើងតែរាជរដ្ឋាភិបាលនោះទេសូមបីតែការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនទូទាំងពិភពលោកក៏ត្រូវការការបង្កើតកិច្ចសន្យាដូចគ្នា។

សរុបជារួមមកដើម្បីអោយការរស់នៅប្រកបដោយភាពយុត្តិធម៌ សមធម៌ មនុស្សទូទប្ញំងពិភពលោកគួរណាស់ត្រូវតែបង្កើតកិច្ចសន្យាព្រោះកិច្ចសន្យាពិតជាមានសារសំខាន់។

ជាចុងក្រោយ ឆ្លងកាត់តាមខ្លឹមសារសារណានេះ ខ្ញុំសង្ឃឹមថាបានចូលរួមយ៉ាងសំខាន់ក្នុងវិស័យច្បាប់។ មួយវិញទៀតខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណាមួយនេះនឹងជួយជាយោលបល់ ឬជាឯកសារ បានមួយផ្នែកតូចចំពោះអ្នកដែលចង់សិក្សាក្នុងវិស័យច្បាប់ក៏ដូចជាប្រជាពលរដ្ឋសាមញ្ញ ដែលមានបំណងចង់ស្វែងរកបារក់ចំណេញដោយការប្រកបរបរសម្រាប់ជីវភាពដូចជា ទិញផ្ទះ លក់ផ្ទះ ជួលផ្ទះ ទិញលក់ដី កំចីប្រាក់ ផ្ញើរឡានឬម៉ូតូ ការបញ្ចាំវត្ថុ និងការទិញលក់ជាច្រើនទៀតគឺសុទ្ធតែត្រូវការកិច្ចសន្យាជាចាំបាច់។ ជាថ្មីម្តងទៀត ថ្វីត្បិតតែសារណាមួយនេះមិនទាន់មានលក្ខណៈ សុក្រឹត្យមួយរយភាគរយក៏ពិតមែនខ្ញុំសង្ឃឹមយ៉ាងមុតមាំថាវានិងជួយ ជាគំនិតមួយផ្នែកក្នុងការពង្រឹងលើវិស័យយុតិធម៌ និងជួយសម្រួលដល់ប្រជាពលរដ្ឋ និងសង្គមជាតិមួយចំណែកដែរ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីយើងខ្ញុំទាំងពីរ បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះមក យើងខ្ញុំទទួលបានបទពិសោធន៍ និងចំណេះដឹងថ្មីៗជាច្រើនពាក់ព័ន្ធនឹងការរៀបចំតាក់តែងកិច្ចសន្យា ជាពិសេសបានយល់ដឹងពីអត្ថប្រយោជន៍នៃកិច្ចសន្យាផងដែល។ ទន្ទឹមនកាតស្រាវជ្រាវរបស់យើងខ្ញុំ ក៏បានជួបឧបសគ្គមួយចំនួនដូចជាការស្វែងរកឯកសារដែលពាក់ព័ន្ធនិងប្រធានបទ ព្រមទាំមទាំងមានភាពស្មុកស្មាញមួយចំនួនផងដែរ ប៉ុន្តែយើងខ្ញុំនៅតែព្យាយាមខិតខំប្រមូលឯកសារពាក់ព័ន្ធទាំងឡាយអស់ពីសម្ថភាពដែលអាចទៅរួច ដើម្បីចងក្រងជាសារណានេះឡើងឱ្យខានតែបាន។

ដើម្បីជាការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងខាងលើ យើងខ្ញុំទាំងពីរនាក់សូមសំណូមពរដល់អ្នកដែលពាក់ព័ន្ធដូចជា៖

**១ រដ្ឋាភិបាល** : ជាពិសេសក្រសួងពាក់ព័ន្ធនានាបន្តពង្រឹង លើកកម្ពស់ ផ្សព្វផ្សាយ ចំណេះដឹងផ្នែកច្បាប់ឱ្យបានទូលំទូលាយបន្ថែមទៀត តាមរយៈការដាក់បញ្ចូលនូវកម្មវិធីសិក្សាថ្នាក់ក្រោមឧត្តមសិក្សានូវចំណេះដឹងមូលដ្ឋានផ្នែកច្បាប់ ក៏ដូចជាការបង្កើតកម្មវិធីផ្សព្វផ្សាយផ្សេងៗតាមរយៈការចុះទៅដល់សហគមន៍ផ្ទាល់ និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានាដោយសារប្រជាពលរដ្ឋភាគច្រើនជាពិសេសអ្នកដែលរស់នៅតំបន់ដាច់ស្រយាលពិតជាមិនសូវបានចាប់អារម្មណ៍ ឬទទួលបាននូវចំណេះដឹងផ្នែកច្បាប់ទេ ខណៈដែលច្បាប់ថ្មីៗបានបង្កើតឡើងជាបន្តបន្ទាប់។

**២ ស្ថាប័នតុលាការ** : ពន្លឿនការដោះស្រាយវិវាទដែលប្រជាពលរដ្ឋបានដាក់បណ្តឹងទៅឲ្យលឿននិងមានប្រសិទ្ធភាពជាងនេះទៀត ព្រោះកាលណានីតិវិធីបណ្តឹងមានរយៈពេលយូរប្រជាពលរដ្ឋគាត់មិនចង់ទៅតុលាការទេ ដោយសារគាត់ត្រូវចំណាយច្រើនទោះបីជារឿងខ្លះគាត់ជាអ្នកបាត់បង់ប្រយោជន៍ក៏ដោយ។

**៣ មន្ត្រីរាជការ សិស្ស និស្សិត**: បុគ្គលទាំងនេះត្រូវបានចាត់ទុកជាអ្នកដែលមានចំណេះដឹងនិងការយល់ដឹងអំពីច្បាប់ក៏ដូចជាព័ត៌មានផ្សេងៗ ច្បាស់ជាងប្រជាពលរដ្ឋ។ ដូចនេះ សិស្ស ន្ត្រីរាជការគួរតែធ្វើខ្លួនជាគំរូដោយគោរពច្បាប់និង មិនប្រព្រឹត្តអ្វីដែលល្មើសច្បាប់ ហើយជាពិសេសត្រូវមានស្មារតីចេះចែករំលែកក្នុងនាមជាខ្មែរដូចគ្នា។

**៤ ប្រជាពលរដ្ឋ** : ប្រជាពលរដ្ឋគួរតែចូលរួមក្នុងការអនុវត្តច្បាប់ឲ្យបានខ្ជាប់ខ្ជួន ស្របតាមភាពសុចរិតនិងស្មោះត្រង់ ព្រោះទាល់តែគាត់គោរពតាមច្បាប់ ទើបគេអាចប្រើប្រាស់ច្បាប់ការពារគាត់បាន។ ពួកគាត់ក៏គួរតែស្វះស្វែង យល់ពីច្បាប់នានាតាមដែលអាចធ្វើទៅបាន ព្រោះយើងទាំងអស់គ្នារស់នៅក្នុងសង្គមនីតិរដ្ឋ ការយល់ដឹងពីច្បាប់គឺជារឿងសំខាន់។

# ឯកសារយោង

# ឯកសារយោង

## ➢ បទដ្ឋានគតិយុត្តិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី  ខែ  ឆ្នាំ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី  ខែ  ឆ្នាំ ២០០៦
- សេចក្តីកំណត់មាត្រានីមួយនៃរដ្ឋបវេណី ឆ្នាំ ២០១០

## ➢ សៀវភៅ និងស្នាដៃអ្នកនិពន្ធ

- សៀវភៅ ច្បាប់កិច្ចសន្យា របស់សាស្ត្រាចារ្យ **អៀង សំណាង** បោះពុម្ព ឆ្នាំ ២០១៨
- សៀវភៅ ច្បាប់កិច្ចសន្យា របស់មេធាវី **ចាន់ សុជីវៈ** បោះពុម្ព ខែ មករា ឆ្នាំ ២០១៣
- សៀវភៅ ច្បាប់កិច្ចសន្យា រៀបរាងដោយ មេធាវី ជ្រា ឈុនឡេង និង កែសម្រួលដោយ មេធាវី ស៊ុយ វុឌ្ឍី ឆ្នាំ២០១៨

## ➢ គេហទំព័រ

១. មេរៀនស្តីពី ក្រមរដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី សមិទ្ធិផលរបស់គម្រោងអភិវឌ្ឍច្បាប់ និងតិលាការ
https://www.jica.go.jp/project/english/cambodia/014/materials/c8h0vm00009678s9-att/accomplishment_1st.pdf

២. ការរំលាយកិច្ចសន្យា-JICA
https://www.jica.go.jp/project/english/cambodia/025/materials/c8h0vm0000c54sbn-att/seminar01_02.pdf

៣. ច្បាប់ស្តីពីកិច្ចសន្យា
https://docs.google.com/viewer?a=v&pid=sites&srcid=ZGVmYXVsdGRvbWFpbnxjYW1ib2RpYWxhd3NvbmxpbmV8Z3g6ZTU3NTNjODAwYWYwOTgw

# ឧបសម្ព័ន្ធ

# ក្រឹត្យច្បាប់

# ស្ដីពី

# កិច្ចសន្យា និងការទទួល
# ខុសត្រូវក្រៅកិច្ចសន្យា

**សាធារណរដ្ឋប្រជាមានិតកម្ពុជា**
**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**
********

ក្រុមប្រឹក្សារដ្ឋ
---------
លេខ ៣៨ ក្រ.ច

ក្រឹត្យ - ច្បាប់

ស្តីអំពី

កិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា

ក្រុមប្រឹក្សារដ្ឋ

នៃ

សាធារណរដ្ឋមានិតកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់នៃការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃសាធារដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២.
- បានឃើញច្បាប់នៃអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២.
- បានឃើញច្បាប់ស្តីពីការចាត់តាំងតុលាការ និងអយ្យការ ដលប្រកាសឱ្យប្រើតាមក្រិត្យលេខ ០២ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២ ។
- បានឃើញច្បាប់ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និង មហាអយ្យការអមតុលាការប្រជាជនកំពូល ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ ២៨ ក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៨៥
- បានឃើញក្រិត្យ-ច្បាប់ លេខ ៣៤ ក្រ ច ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៨៧ ស្តីពីការចាត់តាំង និងសកម្មភាពរបស់តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល
- បានឃើញក្រិត្យ-ច្បាប់ លេខ ០៧ ក្រ ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា
- តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

**សំរេច**

.......

# ជំពូកទី១

## ស្តីអំពីកិច្ចសន្យា

### ផ្នែកទី១ បទបញ្ញត្តិទូទៅ

**មាត្រា១-** កិច្ចសន្យា គឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គល២នាក់ ឬ ច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬ ច្រើនដែលទាក់ទិននិងខ្លួន ។

ក្នុងអត្ថន័យខាងលើ បុគ្គលអាចជារូបវន្តបុគ្គល ជានីតិបុគ្គល ។

នីតិបុគ្គល អាចធ្វើកិច្ចសន្យាតាមរយៈបុគ្គលដែលជាតំណាងរបស់ខ្លួន ។

**មាត្រា២-** កិច្ចសន្យាទាំងឡាយ ត្រូវរួមចំណែកក្នុងការផ្សារភ្ជាប់ផលប្រយោជន៍បុគ្គល និងផលប្រយោជន៍សង្គម ។

ភាគីនៃកិច្ចសន្យា ត្រូវសហការនិងគ្នាក្នុងបរិយាកាសទុកចិត្ត ស្មោះត្រង់និងគ្នា អនុវត្តសមស្របនិងគោល-ការណ៍សីលធម៌សង្គម ហើយជាពិសេស កំចាត់នូវគំនិត មនុស្សជិះជាន់មនុស្ស ។

### ផ្នែកទី២ សុពលភាព និងទំរង់នៃកិច្ចសន្យា

**មាត្រា៣-** កិច្ចសន្យាទាំងឡាយនិងយកជាការបាន លុះណាតែការតព្វកិច្ចដែលកើតពីកិច្ចសន្យានោះ :

១. កើតចេញពីការព្រមព្រៀងដោយពិតប្រាកដ និង ដោយសេរី

២. កើតចេញពីជនដែលមានសមត្ថភាពចុះកិច្ចសន្យា

៣. មានវត្ថុមួយដែលជាក់លាក់ ដែលអាចធ្វើកើត និងដែលស្របច្បាប់របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ ។

**មាត្រា៤-** កិច្ចសន្យាអាចធ្វើដោយផ្ទាល់មាត់ ឬ ជាលាយល័ក្ខអក្សរ ។ ច្បាប់អាចកំណត់ឱ្យមានទំរង់មួយជាក់លាក់ក្នុងការធ្វើកិច្ចសន្យា ។ កិច្ចសន្យាទាំងឡាយណា ដែលមិនបានធ្វើតាមទំរង់ដែលច្បាប់បានកំណត់ត្រូវទុកជាមោឃៈ លើកលែងតែមានបទបញ្ញត្តិនៃវិធានច្បាប់ណាមួយកំនត់ផ្ទុយពីនេះ ។

កិច្ចសន្យាគ្រប់ប្រភេទ ស្តីពីប្រាក់ ឬវត្ថុដែលមានចំនួន ឬមានតំលៃលើសពីប្រាំពាន់រៀល ត្រូវធ្វើជាលាយ-លក្ខអក្សរ ។

### ផ្នែកទី៣ មោឃៈភាពនៃកិច្ចសន្យា

**មាត្រា៥-** ត្រូវទុកជាមោឃៈដាច់ខាត :

- កិច្ចសន្យាទាំងឡាយណាដែលមិនស្របនិងច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ល្អប្រពៃ ។

- កិច្ចសន្យាទាំងឡាយណាដែលមិនស្របនិងផលប្រយោជន៍សង្គម ឬមិនស្របនិងគោលការណ៍សីលធម៌សង្គម ។

- កិច្ចសន្យាទាំងឡាយណាដែលមានតាវកាលិក កម្មវត្ថុនៃកិច្ចសន្យា មិនអាចធ្វើកើត ។

**មាត្រា៦ -** អាចទុកជាមោឃៈបាន :

- កិច្ចសន្យាទាំងឡាយណាដែលមិនកើតចេញពីការព្រមព្រៀងដោយពិតប្រាកដ ឬដោយសេរី ។

- កិច្ចសន្យាទាំងឡាយណាដែលមិនកើតចេញពីបុគ្គលគ្មានសមត្ថភាព ចុះកិច្ចសន្យា ។

**មាត្រា៧ -** មិនអាចចាត់ទុកថា មានការព្រមព្រៀងត្រឹមត្រូវទេ កាលណាការព្រមព្រៀងនោះមិនធ្វើដោយការភ័ន្តច្រឡំ ដោយមានហិង្សា ឬដោយការបន្លំបោកប្រាស់ ។

**មាត្រា៨** -ការភ័ន្តច្រឡំនិងជាមូលហេតុមោឃៈភាពនៃកិច្ចសន្យាបាន បើមានការភ័ន្តច្រឡំទៅលើសារជាតិនៃរបស់ដែលជាកម្មវត្ថុនៃកិច្ចសន្យា ។

ការភ័ន្តច្រឡំទៅលើបុគ្គល មិនអាចចាត់ទុកជាមូលហេតុមោឃៈភាពនៃកិច្ចសន្យាបានឡើយ លើកលែងតែបុគ្គលនោះ ជាមូលហេតុនៃកិច្ចចំបងនៃកិច្ចសន្យា ។

**មាត្រា៩ -** ហិង្សានិងទៅជាមូលហេតុនិងទៅជាមោឃៈភាពនៃកិច្ចសន្យាបាន កាលណាហិង្សានោះជាការគំរាមកំហែង បង្ខិតបង្ខំតាមផ្លូវកាយ ឬផ្លូវចិត្ត ប្រព្រឹត្តទៅលើភាគីណាមួយ ឬទៅលើប្តី ប្រពន្ធ បុព្វញ្ញាតិ ឬបច្ឆាញ្ញាតិណាមួយរបស់ភាគីនោះ ។

**មាត្រា១០ -** ការបន្លំបោកប្រាស់ ជាមោឃៈភាពនៃកិច្ចសន្យា កាលណាមានឧបាយកល អំពើបញ្ឆោត អំពើបន្លំភូតភរប្រព្រឹត្តដោយភាគីណាមួយ ដែលជាហេតុបញ្ជាក់ច្បាស់ថា បើគ្មានកិច្ចកលទាំងនោះទេ ភាគីម្ខាងទៀតប្រាកដជាមិនធ្វើកិច្ចសន្យានោះឡើយ ។

**មាត្រា១១ -** កាលណានៅពេលចុះកិច្ចសន្យា ភាគីណាមួយឆ្លៀតទាញយកប្រយោជន៍ពីស្ថានភាពភាគីម្ខាងទៀត ធ្វើកិច្ចសន្យាដោយមានចំណេញច្រើនមិនសមស្របមកលើខ្លួន ភាគីរងគ្រោះអាចប្តឹងបដិសេធកិច្ចសន្យានោះបានជានិច្ច ។

**មាត្រា១២-** នៅពេលធ្វើកិច្ចសន្យា កាលណាមានភាពខុសគ្នាមិនសមស្របរវាងតំលៃនៃតាវកាលិក និង តំលៃតាវកាលិកតបវិញ ភាគីរងគ្រោះអាចប្តឹងបដិសេធកិច្ចសន្យាបាន ក្នុងលក្ខណះដែលខ្លួនពុំដែលមានបំណងធ្វើអំណោយទេនោះ ។

**មាត្រា១៣-** ភាគីដែលដោះសាស់អាងថា ខ្លួនបានចុះកិច្ចសន្យាដោយមានការភ័ន្តច្រឡំ ដោយមានហឹង្សា ឬដោយមានការបន្លំបោកប្រាស់ ដើម្បីមិនអនុវត្តកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យានោះ ត្រូវជូនភស្តុតាងអំពីរឿងនោះ ។

**មាត្រា១៤-** ជនទាំងឡាយដែលមានអាយុគ្រប់ ១៨ឆ្នាំ អាចធ្វើកិច្ចសន្យាបានគ្រប់ពេលវេលា លើកលែងតែជនគំហាត់ដែលមានចែងក្នុងច្បាប់ ។

**មាត្រា១៥-** អនីតិជនអាយុតិចជាង ១៨ឆ្នាំ មិនអាចធ្វើឱ្យកើតសិទ្ធិ ឬករណីកិច្ចនានា ជាពិសេសមិនអាចចុះកិច្ចសន្យាដោយគ្មានការយល់ព្រមពីអ្នកអាណាព្យាបាលស្របច្បាប់របស់ខ្លួនបានឡើយ ។

កិច្ចសន្យាដែលធ្វើឱ្យអនីតិជន គ្មានការយល់ព្រមជាបឋមពីអ្នកអាណាព្យាបាលស្របច្បាប់របស់ខ្លួន និងអាចយកទៅអនុវត្តបាន លុះត្រាតែអ្នកអាណាព្យាបាលស្របច្បាប់ឯកភាពលើកិច្ចសន្យានោះ ក្រោយពេលដែលអនីតិជនបានចុះកិច្ចសន្យានោះរួច ។

ប៉ុន្តែចំពោះកិច្ចសន្យាទាំងឡាយណា ធ្វើដោយអនីតិជនសំរាប់បំពេញការរស់នៅប្រចាំថ្ងៃនោះ មិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលស្របច្បាប់នៃអនីតិជននោះឡើយ ។

**មាត្រា១៦-** គូសន្យានៃអសមត្ថជន មិនអាចដោះសាដើម្បីគេចកែពីកាតព្វកិច្ចនៃកិច្ចសន្យា ដោយសំអាងថារូបជនដែលចុះកិច្ចសន្យាជាមួយនិងខ្លួននោះ ជាអសមត្ថជនបានឡើយ ។

**មាត្រា១៧-** កិច្ចសន្យាទាំងឡាយត្រូវមានវត្ថុស្ថិតក្នុងពាណិជ្ជកម្ម ។ វត្ថុទាំងនេះត្រូវចែងឱ្យប្រាកដដោយឡែកពីគ្នា តាមប្រភេទ តាមបរិមាណ និងតាមគុណភាព ។

វត្ថុដែលនឹងមានក្នុងអនាគតកាល ក៏អាចជាវត្ថុនៃកិច្ចសន្យាបានដែល ។ ប៉ុន្តែកិច្ចសន្យាលក់មរតក ដែលមានម្ចាស់នៅរស់ពុំអាចធ្វើបានឡើយ ទោះបីម្ចាស់មរតកនោះយល់ព្រមផងក៏ដោយ ។

**មាត្រា១៨-** ជនគ្រប់រូបអាចនឹងសុំមោឃភាពដាច់ខាតនៃកិច្ចសន្យាដែលមានចែងក្នុងមាត្រា ៥ បានគ្រប់ពេលវេលា ។

**មាត្រា១៩-** ក្នុងករណីមោឃភាពនៃកិច្ចសន្យា បណ្តាលមកពីមូលហេតុអសមត្ថភាព ការភ័ន្តច្រលំ ហិង្សា ឬការការបន្លំបោកប្រាស់ ការសុំមោឃភាពនៃកិច្ចសន្យានេះអាចនឹងធ្វើឡើងបានដោយភាគីរងគ្រោះ ឬដោយជនទាំងឡាយណាដែលមានប្រយោជន៍ស្របច្បាប់ ក្នុងការសុំមោឃភាពនោះ ។

ភាគីរងគ្រោះ ឬជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការសុំមោឃភាព ត្រូវឱ្យដំណឹងទៅភាគីម្ខាងទៀត ។ ភាគីដែលទទួលដំណឹងត្រូវឆ្លើយតបជាបន្ទាន់ ។ ក្រោយពេលឱ្យដំណឹងភាគីរងគ្រោះ ឬជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការសុំមោឃភាព អាចសុំប្តឹងមោឃភាពនៃកិច្ចសន្យានោះ ក្នុងរយៈពេល ១២ ខែ យ៉ាងយូរ ។

**មាត្រា២០-** សិទ្ធិប្តឹងមោឃភាពនៃកិច្ចសន្យាដែលមានចែងក្នុងមាត្រាទី ១៩ ត្រូវរលត់ប្រសិនបើក្រោយពីពេលប្តឹងសុំឱ្យមានមោឃភាពនោះមក ជនដែលមានសិទ្ធិប្តឹងនេះយល់ព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឬសុំឈប់ប្តឹងវិញដោយលាយល័ក្ខអក្សរ អំពីមោឃភាពនៃកិច្ចសន្យានោះ ។

**មាត្រា២១-** ក្នុងករណីមានមោឃភាពនៃកិច្ចសន្យា ស្ថានភាពដែលមាននៅពេលមុនចុះកិច្ចសន្យា ត្រូវមានឡើងវិញ ។

## ផ្នែកទី ៤ អានុភាព និង ការបកស្រាយនៃកិច្ចសន្យា

**មាត្រា២២-** កិច្ចសន្យាទុកជាច្បាប់របស់គូភាគី ។

កិច្ចសន្យានឹងអាចកែប្រែបាន លុះត្រាតែមានការយល់ព្រមពីគូភាគី ។ កិច្ចសន្យាត្រូវយកទៅអនុវត្តដោយសុច្ចរិត និងតាមបំណងនៃគូភាគី ។

កិច្ចសន្យាមានអនុភាពតែទៅលើភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ ។

**មាត្រា២៣-** កាលបើកិច្ចសន្យាធ្វើឡើងដោយមានន័យមិនច្បាស់ កិច្ចសន្យានោះត្រូវបកស្រាយតាមទំលាប់ប្រើ ឬតាមទំនៀមទំលាប់នៃកន្លែងដែលកិច្ចសន្យានោះបានធ្វើ កុំឱ្យតែការបកស្រាយនោះផ្ទុយនឹងបទបញ្ញត្តិនៃក្រិត្យច្បាប់នោះ ។

ក្នុងករណីសង្ស័យ កិច្ចសន្យាត្រូវបានបកស្រាយជាប្រយោជន៍នៃភាគីកូនបំណុល ។

**មាត្រា២៤-** ភាគីកូនបំណុលនៃកិច្ចសន្យា មានកាតព្វកិច្ចសងដោយទ្រព្យសម្បត្តិ ជាចលនវត្ថុ និងអចលនវត្ថុបច្ចុប្បន្ន និង អនាគត ។

## ផ្នែកទី ៥ អាជ្ញាយុកាលនៃកិច្ចសន្យា

**មាត្រា២៥-** លើកលែងតែច្បាប់ចែងផ្សេងពីនេះ កាតព្វកិច្ចទាំងឡាយដែលកើតចេញពីកិច្ចសន្យាត្រូវផុតអាជ្ញាយុកាល កាលបើភាគីដើមបំណុលមិនប្តឹងទាមទារឱ្យអនុវត្តក្នុងអំឡុង ៥ ឆ្នាំ គិតពីថ្ងៃកំណត់កិច្ចសន្យា ឬបើគ្មានកំណត់ថ្ងៃទេ ត្រូវគិតពីថ្ងៃចុះកិច្ចសន្យា ។

**មាត្រា២៦ -** អាជ្ញាយុកាលត្រូវបានផ្អាកសិន កាលបើភាគីកូនបំណុលអវត្តមានពីលំនៅស្ថាន ហើយអវត្តមាននេះត្រូវបានរដ្ឋអំណាចមូលដ្ឋានបញ្ជាក់ត្រឹមត្រូវបានច្បាប់ ។

បណ្តឹងរបស់ភាគីកូនបំណុល ក៏ត្រូវផ្អាកអាជ្ញាយុកាលនៃកិច្ចសន្យាដែរ ។

**មាត្រា២៧ -** កូនបំណុល ឬអ្នកធានា អាចនឹងលើកយកអាជ្ញាយុកាលមកតវ៉ាបាន ។ បើកូនបំណុល ឬអ្នកធានាមិនបានលើកយកអាជ្ញាយុកាលមកតវ៉ាទេ តុលាការប្រជាជនត្រូវលើកជូនសាម៉ីខ្លួន ។

**មាត្រា២៨ -** ភាគីកូនបំណុល ឬអ្នកធានាដែលបានបំពេញកាតព្វកិច្ចដែលផុតអាជ្ញាយុកាលរួចទៅហើយ ពុំអាចទាមទារយកចំនួនទឹកប្រាក់ ឬតំលៃនោះមកវិញបានឡើយ ។

## ផ្នែកទី៦. ការអនុវត្តកិច្ចសន្យា

**មាត្រា២៩ -** កាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងកិច្ចសន្យា ត្រូវតែអនុវត្តយ៉ាងទៀងទាត់ និងត្រឹមត្រូវជាពិសេសអំពីបរិមាណ គុណភាព ទីកន្លែង និងរយៈពេលកំណត់ ។

**មាត្រា៣០ -** ភាគីនីមួយនៃកិច្ចសន្យាគឺ :

- កូនបំណុល ចំពោះកាតព្វកិច្ចដែលខ្លួនត្រូវធ្វើ
- ដើមបំណុល ចំពោះកាតព្វកិច្ចដែលខ្លួនត្រូវទារ

**មាត្រា៣១ -** ភាគីដើមបំណុលមិនអាចត្រូវបានបង្ខំ :

- ឱ្យទទួលយកវត្ថុផ្សេងពីវត្ថុដែលខ្លួនត្រូវបាននោះឡើយ ថ្វីត្បិតតែតំលៃនៃវត្ថុដែលបង្ខំឱ្យយកនោះស្មើ ឬលើសពីតំលៃនៃវត្ថុដែលខ្លួនត្រូវបាន ។
- ឱ្យព្រមទទួលយកការអនុវត្តមួយផ្នែកនៃកិច្ចសន្យា ។ ប៉ុន្តែដោយយោលទៅលើស្មារតីសុច្ចរិត និងស្ថានភាពក្រលំបាករបស់ភាគីកូនបំណុល តុលាការប្រជាជនអាចឱ្យបន្ថយរយៈពេលអនុវត្ត និងបង្គាប់ឱ្យបង្គង់សិន ។ ក្នុងករណីពិសេសនេះ សេចក្តីសំរេចត្រូវតែដាក់មូលហេតុឱ្យបានច្បាស់លាស់ ហើយតុលាការប្រជាជនត្រូវប្រើអំណាចនេះដោយប្រុងប្រយ័ត្នបំផុត ។

**មាត្រា៣២ -** ការអនុវត្តកិច្ចសន្យា ត្រូវប្រព្រឹត្តិទៅនៅលំនៅស្ថានរបស់កូនបំណុលក្នុងករណីដែលកិច្ចសន្យាពុំបានកំណត់កន្លែងផ្សេងទៀត ។

**មាត្រា៣៣ -** ក្នុងករណីគ្មានកំណត់រយៈពេលដើម្បីអនុវត្តកិច្ចសន្យា កូនបំណុលអាចតាង ឬផ្តល់នៅពេលណាក៏បាន ។

## ជំពូកទី ២

### អំពីកិច្ចសន្យាមួយចំនួន ដែលប្រើញឹកញាប់

### ផ្នែកទី ១.ការលក់ដូរ

**មាត្រា៣៤-** ការលក់ ជាកិច្ចសន្យាមួយដែលបុគ្គលម្នាក់មានកាតព្វកិច្ចផ្ទេរកម្មសិទ្ធិនៃវត្ថុមួយ ឬសិទ្ធិណាមួយឱ្យទៅបុគ្គលម្នាក់ទៀតដែលមានកាតព្វកិច្ចត្រូវប្រគល់ប្រាក់ថ្លៃវត្ថុ ឬសិទ្ធិនោះមកវិញ ។

**មាត្រា៣៥-** ត្រូវទុកជាមោឃៈ

- ការលក់វត្ថុរបស់អ្នកដទៃ
- ការលក់វត្ថុពីប្ដីទៅឱ្យប្រពន្ធ ឬពីប្រពន្ធទៅឱ្យប្ដី
- ការលក់វត្ថុអវិភាគ " ដែលបំបែកពីគ្នាមិនបាន " ដោយសហកម្មសិទ្ធិករម្នាក់ដោយគ្មានបានទទួលការព្រមព្រៀងពីសហកម្មសិទ្ធិករឯទៀត ។

### ១. កាតព្វកិច្ចរបស់អ្នកលក់

**មាត្រា៣៦-** អ្នកលក់ត្រូវរក្សាវត្ថុឱ្យបានល្អរហូតដល់ថ្ងៃកំណត់ ដើម្បីអាចបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែលត្រូវប្រគល់វត្ថុនោះ ។

**មាត្រា៣៧-** អ្នកលក់ត្រូវជៀសវាងកុំផ្លាស់ប្ដូរ កែប្រែវត្ថុតាមរបៀបណាក៏ដោយ ចាប់តាំងពីថ្ងៃលក់រហូតដល់ថ្ងៃប្រគល់វត្ថុ ។

**មាត្រា៣៨-** អ្នកលក់ត្រូវទទួលខុសត្រូវអំពីការអន្តរាយដែលបណ្ដាលឡើងដល់វត្ថុនោះ រហូតដល់ថ្ងៃដែលត្រូវប្រគល់ ។ ការលក់អាចរំលាយចោលបាន ប្រសិនបើវត្ថុដែលលក់នោះបាត់ ឬខូចខាតច្រើនមុនពេលប្រគល់ ឬក្នុងករណីដែលអ្នកលក់រកវត្ថុដូចគ្នាមកជំនួសពុំបាន ។ ប្រសិនបើការលក់ត្រូវរំលាយចោល អ្នកលក់ត្រូវបង់ជំងឺចិត្តឱ្យអ្នកទិញចំពោះការបាត់វត្ថុ ឬការខូចខាតវត្ថុបណ្ដាលមកពីកំហុសរបស់អ្នកលក់ ។

**មាត្រា៣៩-** អ្នកលក់ត្រូវប្រាប់អ្នកទិញនូវគុណភាពជាសារវន្តនៃវត្ថុ ព្រមទាំងស្ថានភាពទាំងឡាយសំខាន់ៗទាក់ទងទៅនឹងវត្ថុនោះ ជាពិសេសប្រាប់អំពីសិទ្ធិនោះឬអំពីបន្ទុកដែលមានលើវត្ថុនោះ។ ម្យ៉ាងទៀតអ្នកលក់ក៏ត្រូវប្រគល់ដល់ដៃអ្នកទិញនូវឯកសារទាំងឡាយដែលទាក់ទងនឹងស្ថានភាពទាំងនោះ ។

**មាត្រា៤០-** អ្នកលក់ត្រូវប្រគល់ពុំមែនតែវត្ថុដើមប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រគល់ផល ឬវត្ថុរាយរងទាក់ទងទៅនឹងវត្ថុដើមទៀតផង ។

ក្នុងរឿងលក់ចលនវត្ថុ ការប្រគល់ប័ណ្ណនៃចលនវត្ថុ ទុកជាការប្រគល់ចលនវត្ថុដោយត្រឹមត្រូវ ។ ប្រាក់ចំណាយក្នុងការប្រគល់ត្រូវធ្លាក់មកលើអ្នកលក់ ប្រសិនបើគ្មានចែងផ្សេងពីនេះ នៅក្នុងកិច្ចសន្យាលក់ទេនោះ ។

**មាត្រា៩១-** ចំពោះចលនវត្ថុ ការផ្ទេរសិទ្ធិរបស់អ្នកលក់ឱ្យទៅអ្នកទិញទុកជាត្រឹមត្រូវបាន លុះត្រាតែសំបុត្រលក់នោះមានសេចក្តីបញ្ជាក់ និងប្រថាប់ត្រា ។ ចាប់តាំងពីថ្ងៃដែលសំបុត្រនោះមានសេចក្តីបញ្ជាក់ និងប្រថាប់ត្រា តតិយជនជំទាស់លែងបាន ។

ចំពោះចលនវត្ថុ ការផ្ទេរកម្មសិទ្ធិទុកជាត្រឹមត្រូវបាន ហើយតតិយជនក៏ជំទាស់លែងបាន ចាប់តាំងពីពេលដែលប្រគល់វត្ថុនោះដល់អ្នកទិញ លើកលែងតែការលក់ត្រូវធ្វើសំបុត្រមានសេចក្តីបញ្ជាក់ ។ ក្នុងករណីខាងក្រោយនេះ តតិយជនជំទាស់លែងបានចាប់តាំងពីថ្ងៃដែលសំបុត្រនោះមានសេចក្តីបញ្ជាក់ ។

**មាត្រា៩២-** អ្នកលក់ពុំទទួលខុសត្រូវចំពោះវិការៈដែលមើលឃើញពីក្រៅទេ ប៉ុន្តែត្រូវទទួលខុសត្រូវចំពោះវិការៈដ៏កំបាំងដែលមានមុខពេលលក់ ។

បើអ្នកទិញមានភស្តុតាងថា វិការៈនោះមានមុខពេលលក់ អ្នកទិញអាចទាមទារឱ្យរំលាយការលក់នោះចោល ឬក៏បន្ថយថ្លៃបាន ។ ទោះនិងលែងទិញក្តី ទោះនិងទាមទារឱ្យបន្ថយថ្លៃក្តី អ្នកទិញត្រូវតវ៉ាក្នុងរយៈពេលមួយឆ្នាំចាប់ពីថ្ងៃប្រគល់វត្ថុ ។ បើមិនតវ៉ាក្នុងរយៈមួយឆ្នាំនោះទេ ការនៅស្ងៀមរបស់ខ្លួនទុកដូចជាការយល់ព្រម ។

**មាត្រា៩៣-** អ្នកលក់ត្រូវធានាដល់អ្នកទិញ ចំពោះការរំខានណាដែលតតិយជន គំរាមថានិងប្តឹងឱ្យដកហូតវត្ថុពីអ្នកទិញ ។ សេចក្តីគំរាមថា ប្តឹងឱ្យដកហូតនោះកើតឡើងក្នុងគ្រាដែលតតិយជនទាមទារឱ្យអ្នកទិញទទួលស្គាល់សិទ្ធិរបស់ខ្លួនលើវត្ថុនោះ ។

**មាត្រា៩៤-** ខណៈណាដែលមានតតិយជនគំរាមថា និងប្តឹងឱ្យដកហូត អ្នកទិញអាចទៅហៅអ្នកលក់ឱ្យមកធានារ៉ាប់រងភ្លាមបាន ។ ខណៈអ្នកលក់ត្រូវបញ្ចេញប័ណ្ណរបស់ខ្លួន ប្រើគ្រប់មធ្យោបាយដើម្បីឱ្យតតិយជនលែងប្តឹងទៅ ឬក៏ឱ្យបានឈ្នះតតិយជននោះតាមអំណាចសាលក្រមរបស់តុលាការ ។

**មាត្រា៩៥-** បើអ្នកលក់ដែលអ្នកទិញបានហៅឱ្យធានារ៉ាប់រងជួសខ្លួនរំងាប់សេចក្តី ដែលតតិយជនប្រកាន់នោះបាន អ្នកទិញមិនត្រូវបានជំងឺចិត្តអ្វីឡើយ ។

បើអ្នកលក់រំងាប់សេចក្តីរំខាននោះមិនបានទេ ការប្តឹងផ្តល់ក៏ត្រូវប្រព្រឹត្តទៅតាមតំណើរ ។

**មាត្រា៩៦-** បើតុលាការកាត់សេចក្តីឱ្យដកហូតវត្ថុ អ្នកលក់ត្រូវបង្វិលថ្លៃទាំងអស់ដែលខ្លួនបានទទួលឱ្យអ្នកទិញវិញ ម្យ៉ាងទៀតអ្នកលក់ត្រូវចេញជំងឺចិត្តផង នៅក្នុងជំងឺចិត្តនោះត្រូវគិតប្រាកបង់ខាតក្នុងការធ្វើកិច្ចសន្យា និងប្រាក់ចំណាយផ្សេងៗ ដែលអ្នកទិញគិតបញ្ចូលទៅក្នុងវត្ថុនោះ តាំងពីថ្ងៃលក់មក ។

**មាត្រា៤៧-** បើអ្នកលក់ស្លាប់ កាតព្វកិច្ចនៃការទទួលរ៉ាប់រងត្រូវធ្លាក់ទៅលើទាយាទទាំងអស់នៃអ្នកលក់ ។

**មាត្រា៤៨-** បើវត្ថុដែលលក់នោះបានមកដោយអំពើល្មើសជាបទឧក្រិដ្ឋ ឬជាបទល្មើសមធ្យមអ្នកទិញកាលបើដឹងហើយ អាចប្តឹងទាមទារឱ្យរំលាយការលក់នោះវិញបាន ទោះបីគ្មានតតិយជនណាត់វាមកហែងដកហូតវត្ថុនោះវិញក៏ដោយ ។

កិច្ចសន្យាដែលផ្ទុយពីសេចក្តីនេះ ត្រូវទុកជាមោឃៈ ។

**មាត្រា៤៩-** ប្រសិនបើវត្ថុដដែលហើយលក់ឱ្យច្រើននាក់ត១គ្នា អ្នកទិញក្រោយបង្អស់ត្រូវហៅអ្នកដែលលក់ឱ្យខ្លួនមកធានារ៉ាប់រង ។ អ្នកលក់នេះនិងប្រកាន់អ្នកដែលលក់ឱ្យខ្លួនត១គ្នាទៅទៀតតាមត្រូវការ ។

## ១_ភាតព្វកិច្ចនៃអ្នកទិញ

**មាត្រា៥០-** អ្នកទិញត្រូវប្រគល់ប្រាក់នៅថ្ងៃ និងទីកន្លែងដែលបានកំណត់ ។ ប្រសិនបើកិច្ចសន្យាពុំមានកំណត់ទីកន្លែង និងថ្ងៃដែលត្រូវទទួលប្រាក់ទេ ត្រូវសន្មត់ថា ការប្រគល់ប្រាក់ត្រូវធ្វើនៅទីកន្លែង និងនៅពេលដែលប្រគល់វត្ថុ ។

**មាត្រា៥១-** កិច្ចសន្យាអាចតំរូវឱ្យអ្នកទិញបង់ការប្រាក់និងតំលៃវត្ថុ ក្នុងករណីមានការប្រគល់យឺតយ៉ាវ ។ អត្រានៃការប្រាក់នោះ មិនអាចគិតឱ្យលើសពី ៥ ភាគរយក្នុងមួយឆ្នាំ ។

ប្រសិនបើកិច្ចសន្យាមិនកំណត់អំពីការប្រាក់ទេ អ្នកទិញត្រូវចេញតែថ្លៃវត្ថុដែលចុះក្នុងកិច្ចសន្យា ប៉ុន្តែក្នុងករណីដែលវត្ថុនោះបង្កើតជាផល ឬជាផលទុន ការប្រាក់ត្រូវគិតតាមអត្រាដែលច្បាប់កំនត់ ។

**មាត្រា៥២-** បើអ្នកទិញបានទទួលវត្ថុហើយ ហើយមានគេប្រកាន់ថា និងប្តឹងឱ្យដកហូតវត្ថុនោះវិញ អ្នកទិញអាចមិនទាន់បង់ថ្លៃវត្ថុនោះបាន ។ អ្នកទិញត្រូវប្រគល់ថ្លៃនោះទៅឱ្យអ្នកលក់ កាលណាការរំខានបានត្រូវរំងាប់វិញហើយ ។

**មាត្រា៥៣-** ដរាបណាអ្នកទិញមិនទាន់ចេញថ្លៃឱ្យ ដរាបនោះអ្នកលក់មានសិទ្ធិផ្អាកវត្ថុនោះទុកដែរ ។

**មាត្រា៥៤-** បើដល់ថ្ងៃសន្មត់ហើយ អ្នកទិញមិនទាន់បានបង់ថ្លៃ អ្នកលក់អាចសុំរំលាយការលក់នោះវិញបាន ប្រសិនបើអ្នកលក់មិនចង់ប្តឹងទារថ្លៃនោះទេ ។

ដរាបណាភាគខ្លះនៃថ្លៃមិនទាន់សងអស់ ដរាបនោះអ្នកលក់អាចសុំរំលាយការលក់បាន ។

**មាត្រា៥៥-** ការរំលាយការលក់ តំរូវឱ្យភាគីទាំងសងខាងនៃកាតព្វកិច្ច បង្វិលរបស់ដែលខ្លួនបានទទួលឱ្យគ្នាវិញ ។

អ្នកទិញត្រូវបង្វិលវត្ថុព្រមទាំងផល ឬផលទុនដែលខ្លួនបានយក ។

អ្នកលក់ត្រូវសងទៅអ្នកទិញវិញនូវប្រាក់ដែលអ្នកទិញបានចេញក្នុងថ្លៃវត្ថុ ហើយត្រូវគិតការប្រាក់តាមអត្រាដែលច្បាប់កំណត់ គាំងពីថ្ងៃដែលបានសងថ្លៃមួយលើក១ ។

**ផ្នែកទី២. ការខ្ចីមានការប្រាក់**

**មាត្រា៥៦-** ការខ្ចីមានការប្រាក់ ជាកិច្ចសន្យាដែលបុគ្គលម្នាក់ប្រគល់ប្រាក់ឱ្យទៅបុគ្គលម្នាក់ទៀត ហើយបុគ្គលក្រោយម្នាក់នេះមានកាតព្វកិច្ចសងវិញដោយមានតំឡើងទឹកប្រាក់ទៅតាមពេលវេលានៃកិច្ចសន្យា ។

**មាត្រា៥៧-** កិច្ចសន្យាត្រូវធ្វើជាលាយល័ក្ខអក្សរ ។ កិច្ចសន្យាត្រូវកំណត់ឱ្យច្បាស់អំពីឈ្មោះ ទីលំនៅរបស់គូភាគី ចំនួនទឹកប្រាក់ដែលខ្ចី ចំនួនការប្រាក់ រយះពេលខ្ចី និងថ្ងៃសងវិញ ។ កូនបំណុលត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ ។

**មាត្រា៥៨-** បើកិច្ចសន្យាមិនកំណត់ថ្ងៃសង និងមិនកំណត់ការប្រាក់ទេនោះ សន្មត់ថាគូភាគីព្រមព្រៀងចុះកិច្ចសន្យាសំរាប់រយះពេលមួយឆ្នាំ ដោលគ្មានការប្រាក់ ។

**មាត្រា៥៩-** និងអាចឱ្យយកការប្រាក់ខ្ចីបាន លុះត្រាតែមានការព្រមព្រៀងនៃគូភាគីក្នុងកិច្ចសន្យា ។ អត្រានៃការប្រាក់មិនត្រូវឱ្យលើសពី ៥ ភាគរយក្នុងមួយឆ្នាំ លើកលែងតែមានបទបញ្ញត្តិចែងផ្ទុយពីនេះ ។

**មាត្រា៦០-** ការប្រាក់ដែលអ្នកឱ្យខ្ចីបានយកលើសរហូតមកក្នុងពេលដែលជំពាក់ ត្រូវកាត់ដាច់ជាសំណងប្រាក់ដើម ។

បើអ្នកខ្ចីបានសងលើសពីប្រាក់ដើម និងការប្រាក់តាមច្បាប់កំណត់ អ្នកឱ្យខ្ចីនិងត្រូវបង្ខំឱ្យសងប្រាក់ដែលខ្លួនបានយកលើសខុសច្បាប់នោះទៅអ្នកខ្ចីវិញ ព្រមទាំងតំរូវឱ្យបង់ការប្រាក់ផង គិតពីថ្ងៃដែលបានសង ។ ក្នុងករណីនេះ អ្នកឱ្យខ្ចីត្រូវជាប់ចោទតាមបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌជាធរមានថែមទៀត ។

**មាត្រា៦១-** ការប្តឹងទារប្រាក់មុនពេលផុតកំណត់នៃកិច្ចសន្យា មិនអាចធ្វើបានទេ ។ ប៉ុន្តែបើអ្នកជំពាក់បំណុលស្លាប់ ប្រាក់ដែលជំពាក់នោះតំរូវឱ្យទារភ្លាមបាន ហើយទាយាទនៃអ្នកស្លាប់ត្រូវកាត់មរតកសងជាមុនសិនរួចសឹមចែកមរតកជាក្រោយ ។

**មាត្រា៦២-**ដើមបំណុលត្រូវប្រគល់សំបុត្រជំពាក់ រឺសំបុត្របញ្ជាក់អំពីការសងប្រាក់ឱ្យកូនបំណុលនៅពេលកូនបំណុលសងប្រាក់ទៅខ្លួន។

**មាត្រា៦៣-**ការខ្ចីប្រាក់លើទ្រព្យសម្បត្តិចលនវត្ថុឯទៀត ត្រូវគ្រិបត្តិតាមបទបញ្ញត្តិកំណត់សំរាប់ការខ្ចីប្រាក់ដែរ។

## ផ្នែកទី៣ ការបញ្ចាំចលនវត្ថុ

**មាត្រា៦៤-** ការបញ្ចាំចលនវត្ថុជាកិច្ចសន្យាដែលកូនបំណុលយកទ្រព្យសម្បត្តិចលនវត្ថុរបស់ខ្លួនទៅទុកដៃដើមបំណុល ដើម្បីធានាសំណងបំណុល ។

ដើមបំណុលដែលមានចលនវត្ថុនៅក្នុងដៃ មានសិទ្ធិយកប្រាក់សំណងដែលបានមកពីការលក់ចលនវត្ថុបញ្ចាំ មុនដើមបំណុលឯទៀត ។

**មាត្រា៦៥-** កិច្ចសន្យាបញ្ចាំចលនវត្ថុត្រូវធ្វើជាលាយល័ក្ខអក្សរ ។ ទ្រព្យដាក់ធានា ត្រូវបានប្រគល់ដល់ដៃនៃដើមបំណុល ទើបកិច្ចសន្យានោះទុកជាបានការ ។

កិច្ចសន្យាត្រូវកំណត់ចំនួនទឹកប្រាក់ដែលជំពាក់ និងវត្ថុដែលបញ្ចាំ ឱ្យច្បាស់លាស់ ។

បើកិច្ចសន្យាមិនកំណត់ថាត្រូវមានការប្រាក់ទេ មិនកំណត់ពេលវេលាដែលត្រូវសងទេ បំណុលនោះត្រូវទុកជាឱ្យខ្ចីដោយឥតយកការប្រាក់ក្នុងកំណត់មួយឆ្នាំ គិតពីថ្ងៃចុះកិច្ចសន្យានោះ ។

**មាត្រា៦៦-** ដើមបំណុលគ្មានសិទ្ធិចាត់ចែងវត្ថុបញ្ចាំតាមទំនើងចិត្តរបស់ខ្លួនបានទេ ។ ដើមបំណុលមានករណីកិច្ចទុកវត្ថុនោះឱ្យគង់វង់ និងថែរក្សាឱ្យបានល្អ ។ ក្នុងករណីដែលវត្ថុបញ្ចាំនោះត្រូវខូចខាត ឬបាត់បង់បណ្ដាលមកពីកំហុសរបស់ខ្លួន ដើមបំណុលត្រូវជួសជុលសំណងវត្ថុបញ្ចាំនោះ ។

**មាត្រា៦៧-** ប្រសិនបើគ្មានកំណត់ក្នុងកិច្ចសន្យាជាលាយល័ក្ខអក្សរច្បាស់លាស់ទេ ដើមបំណុលមិនត្រូវបានអនុញ្ញាតឱ្យយកវត្ថុបញ្ចាំនោះទៅប្រើប្រាស់ ឬទាញយកផលប្រយោជន៍ពីវត្ថុបញ្ចាំនោះបានទេ ។ ប៉ុន្តែដើមបំណុលត្រូវបានអនុញ្ញាតិឱ្យទទួលយកផលធម្មជាតិ នៃវត្ថុបញ្ចាំនោះបាន ។ ផលនោះទុកជាអាទិសំរាប់ចំណាយចាំបាច់ទាំងឡាយ ។

ប្រសិនបើដើមបំណុលប្រើវត្ថុបញ្ចាំនោះដោយរំលោភលើកិច្ចសន្យា កូនបំណុលអាចសុំប្ដឹងដកវត្ថុបញ្ចាំមកវិញបាន ។

**មាត្រា៦៨-** ប្រសិនបើដើមបំណុលចាត់ចែងចំណាយវត្ថុបញ្ចាំដោយគ្មានបានទទួលការព្រមព្រៀងជាមុនពីកូនបំណុល នោះដើមបំណុលនឹងត្រូវជាប់ចោទ តាមបទបញ្ញតិនៃច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា៦៩-** កាលណាដល់ថ្ងៃកំណត់ហើយសំណងក៏ត្រូវបានប្រគល់ឱ្យគ្រប់ចំនួនរួចស្រេចនោះ ដើមបំណុលត្រូវប្រគល់វត្ថុបញ្ចាំទៅម្ចាស់ដើមវិញ ។ បើកូនបំណុលមិនទាន់សងគ្រប់ចំនួនទេ ដើមបំណុលនឹងរក្សាទុកវត្ថុដែលបញ្ចាំនោះបាន ។

**មាត្រា៧០-** ប្រសិនបើដល់ថ្ងៃកំណត់ ហើយកូនបំណុលមិនលោះ ដើមបំណុលអាចទាមទារតាមរយៈតុលាការប្រជាជនឱ្យលក់វត្ថុបញ្ចាំ ។ ប្រាក់ដែលបានមកពីការលក់ ត្រូវសងទៅដើមបំណុលដែលបានទទួលបញ្ចាំវត្ថុនោះ ។ ប្រាក់សល់ពីនោះ ត្រូវប្រគល់ឱ្យកូនបំណុល ឬដើមបំណុលឯទៀតដែលមានបំណុលដល់កំណត់ត្រូវសង ។

បើប្រាក់ថ្លៃលក់វត្ថុនោះមិនគ្រប់គ្រាន់នឹងសងបំណុលដែលបញ្ចាំវត្ថុនោះ កូនបំណុលត្រូវនៅជំពាក់បំណុលដែលនៅសល់ទៅទៀត ។

**មាត្រា៧១-** ត្រូវទុកជាមោឃៈកិច្ចសន្យាទាំងឡាយណាដែលកំណត់ឱ្យដើមបំណុលទៅម្ចាស់កម្មសិទ្ធិនៃវត្ថុបញ្ចាំ ក្នុងករណីដែលកូនបំណុលមិនបានបំពេញកាតព្វកិច្ច ។

## ផ្នែកទី ៤. កិច្ចសន្យាសហគ្រាស

**មាត្រា៧២-** កិច្ចសន្យាសហគ្រាស ជាកិច្ចសន្យាដែលបុគ្គលមួយទទួលបន្ទុកធ្វើការងារអ្វីមួយឱ្យបុគ្គលមួយទៀត ដោយថ្លៃសមស្របនឹងទំហំនៃការងារនោះ ។

**មាត្រា៧៣-** ប្រសិនបើថ្លៃការងារមិនបានកំណត់ក្នុងកិច្ចសន្យា តុលាការត្រូវវិនិច្ឆ័យកំណត់ថ្លៃទៅតាមទំលាប់នៃកន្លែងធ្វើការនោះ ។

**មាត្រា៧៤-** ការងារត្រូវធ្វើឱ្យត្រឹមត្រូវតាមកិច្ចសន្យា ។ បើការងារដែលបានធ្វើនោះ មិនត្រូវតាមកំណត់ដែលមានចែងក្នុងកិច្ចសន្យាទេ អ្នកជួលអាច :

ក- ឬមួយមិនព្រមទទួលយកការងារនោះ ហើយក្នុងករណីនេះកិច្ចសន្យាអាចរំលាយបានដោយតំរូវឱ្យអ្នកទទួលធ្វើបង់ជំងឺចិត្ត និងសងសំណងបង់ខាតផ្សេងៗ ប្រសិនបើមានទៅឱ្យអ្នកជួល ។

ខ- ឬមួយតំរូវឱ្យធ្វើការកែប្រែចាំបាច់ក្នុងរយះពេលកំណត់តាមការព្រមព្រៀងនៃគូភាគី ដោយអ្នកទទួលធ្វើចេញប្រាក់ផ្ទាល់ខ្លួន ដើម្បីសំរួលតាមការកំនត់នៃកិច្ចសន្យាវិញ ។

គ- ឬមួយព្រមទទួលយកការនោះ ដោយបញ្ចុះថ្លៃ ។

**មាត្រា៧៥-** ប្រសិនបើកិច្ចសន្យាកំណត់រយះពេល ដែលការងារត្រូវតែធ្វើឱ្យហើយក្នុងពេលណាមួយហើយបើការនោះធ្វើមិនហើយតាមពេលកំណត់ កិច្ចសន្យាអាចលប់ចោលវិញដោយពុំទាន់គិតដល់ជំងឺចិត្តដែលអ្នកជួលអាចទាមទារបាន ។

ប៉ុន្តែប្រសិនបើការយឺតយ៉ាវបណ្តាលមកពីប្រធានសក្តិ នោះជួលពុំអាចទាមទារជំងឺចិត្តបានឡើយ ។

**មាត្រា៧៦-** ស្រិនបើអ្នកជួលបានសន្យាថានឹងបើកប្រាក់ឱ្យមុនខ្លះ ឬវត្ថុធាតុដើមខ្លះឱ្យទាន់ពេលវេលាហើយមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យា នោះអ្នកជួលពុំអាចលើកយកការយឺតយ៉ាវក្នុងការអនុវត្តការងារ

មកសំអាងដើម្បីបញ្ឈប់កិច្ចសន្យានោះបានឡើយ ។

អ្នកទទួលធ្វើអាចសំអាងលើការខូចខាតពេលវេលារង់ចាំសំភារះយូរ ដើម្បីលប់កិច្ចសន្យា ។ ក្នុងករណីនេះ អ្នកទទួលធ្វើត្រូវបានទទួលឈ្នួលសមស្របតាមការងារដែលខ្លួនបានធ្វើហើយ ។

**មាត្រា៧៧-** អ្នកជួលអាចលប់ចោលកិច្ចសន្យាបានជានិច្ច នៅមុនពេលការងារធ្វើហើយជាស្ថាពរ ប៉ុន្តែត្រូវគិតថ្លៃការងារដែលបានធ្វើ គិតចំណាយផ្សេងៗ និងជំងឺចិត្តទៅឱ្យអ្នកទទួលធ្វើ ។

**មាត្រា៧៨-** បើការងាត្រូវអន្តរាយមុនពេលធ្វើរួច ដោយកំហុសនៃអ្នកទទួលធ្វើ ហើយអ្នកជួលបានបើកប្រាក់ឱ្យមុន និងផ្តល់វត្ថុធាតុដើមឱ្យទៀត នោះអ្នកជួលមានសិទ្ធិទារសំណងស្មើនឹងការ ជួសជុលអន្តរាយបណ្តាលមកពីការបាត់វត្ថុ និងចំណាយផ្សេងៗដែលខ្លួនបានចាយក្នុងការធ្វើនោះ ។ ប៉ុន្តែបើការខូចខាតបណ្តាលមកពីករណីប្រធានសក្តិ ភាគីនៃកិច្ចសន្យាត្រូវទទួលផលវិបាក ដោយពុំអាចប្តឹងទាមទារពីគ្នាបានឡើយ ។

**មាត្រា៧៩-** អ្នកទទួលធ្វើការងារនោះ ត្រូវទទួលខុសត្រូវខាងរដ្ឋប្បវេណី ចំពោះជនដែលខ្លួនប្រើធ្វើការងារនោះ ។

**មាត្រា៨០-** កាលបើការងារសំរេចបានហើយ អ្នកទទួលធ្វើការអាចទារថ្លៃនៅពេលប្រគល់ការងារបាន ។

ការប្រគល់ថ្លៃការងារ ទុកជាការព្រមទទួលយកការងារដែលធ្វើរួច ។

**មាត្រា៨១-** កាលបើក្រោយពីបានប្រគល់ការងារមក គុណវិបត្តិ និងវិការះដ៏កំបាំងណាមួយបានផុសឡើងបណ្តាលមកពីកំហុសអ្នកទទួលធ្វើក្នុងពេលដែលធ្វើការងារនោះ កិច្ចសន្យាត្រូវតែរំលាយចោល ឬត្រូវបង្វិលថ្លៃឈ្នួលខ្លះមកឱ្យអ្នកជួលវិញ ឬក៏ការងារនោះត្រូវជួលជុលដោយបង់ខាតនៃអ្នកទទួលធ្វើ ។

អ្នកជួសអាចប្តឹងបានតែក្នុងករណីដែលវិការះនោះ លេចឡើងក្នុងរយះពេលដែលអ្នកទទួលធ្វើរ៉ាប់រងទទួលខុសត្រូវដូចមានចែងក្នុងកិច្ចសន្យា ។ បើគ្មានចែងអំពីរយះពេលរ៉ាប់រងទទួលខុសត្រូវក្នុងកិច្ចសន្យាទេ អ្នកជួលអាចប្តឹងបានក្នុងរយះពេល ៣ ឆ្នាំ គិតពីថ្ងៃដែលបានទទួលការងារនោះមក ។

**មាត្រា៨២-** ចំពោះរូបវន្តបុគ្គល បើអ្នកទទួលធ្វើស្លាប់ កិច្ចសន្យានោះត្រូវរលាយ ។

## ផ្នែកទី ៥~ កិច្ចសន្យាដឹកជញ្ជូន

**មាត្រា៨៣-** កិច្ចសន្យាដឹកជញ្ជូន ជាកិច្ចសន្យាដែលអ្នកដឹកជញ្ជូនសន្យាដឹកអ្នកដំណើរ ភារះវត្ថុ ឬទំនិញពីកន្លែងមួយទៅកន្លែងមួយទៀត ដោយយកថ្លៃតាមការព្រមព្រៀង ឬតាមថ្លៃកំណត់របស់រដ្ឋ ។

**មាត្រា៨៤-** កាលណាអ្នកដឹកជញ្ជូនយឺតយ៉ាវក្នុងការប្រគល់យានដឹកជញ្ជូន អ្នកបញ្ជូនមានសិទ្ធិបញ្ឈប់កិច្ចសន្យាហើយតំរូវ :

- ឱ្យសងប្រាក់ចំណាយក្នុងការលើកដាក់ និងប្រាក់ដែលបានបង់រួចហើយទៅឱ្យអ្នកដឹកជញ្ជូនផ្សេងទៀត ។

- ឱ្យសងជួសជុលអន្តរាយ បណ្តាលមកពីការយឺតយ៉ាវ ករណីបាត់ ឬខូចសំភារៈវត្ថុ ឬទំនិញដែលត្រូវដឹកជញ្ជូន ឬការចុះតំលៃ បណ្តាលមកពីការយឺតយ៉ាវ ។

**មាត្រា៨៥-** កាលណាអ្នកបញ្ជូនយឺតយ៉ាវក្នុងការលើកដាក់ភារៈវត្ថុ ឬទំនិញ អ្នកដឹកជញ្ជូនមានសិទ្ធិតំរូវឱ្យជួសជុលការខាតបង់ និងបញ្ឈប់កិច្ចសន្យា ។

**មាត្រា៨៦-** អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវអំពីការបាត់បង់ ឬការខូចខាតលើវត្ថុដឹកជញ្ជូន ។ អ្នកដឹកជញ្ជូនក៏ត្រូវទទួលខុសត្រូវអំពីគ្រោះថ្នាក់ដែលបណ្តាលឡើងដល់អ្នកដំណើរ ក្នុងពេលដែលខ្លួនដឹកជញ្ជូនដែរ ។

អ្នកដឹកជញ្ជូនត្រូវបានរួចខ្លួនពីការទទួលខុសត្រូវខាងលើ ក្នុងករណីប្រធានសក្តិ ឬក្នុងករណីអ្នកដំណើរត្រូវរងគ្រោះ ដោយមកពីការធ្វេសប្រហែសរបស់ខ្លួន ។

បើភារៈវត្ថុ ឬទំនិញដែលត្រូវគេប្រគល់ឱ្យដឹកជញ្ជូនអន្តរាយដោយចោរកម្ម អ្នកដឹកជញ្ជូនត្រូវជួសជុលសំណងនៃភារៈវត្ថុ ឬទំនិញនោះ ។

**មាត្រា៨៧-** អ្នកដឹកជញ្ជូនត្រូវធានាអំពីការខូចខាតលើវត្ថុ ប្រសិនបើការខូចខាតនោះមិនមែនបណ្តាលមកពីករណីប្រធានសក្តិ ឬវិបត្តិផ្ទាល់នៃវត្ថុនោះ ។ អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវជាពិសេសចំពោះការបាត់បង់ ឬការខូចខាត បណ្តាលមកពីការយឺតយ៉ាវដោយគ្មានមូលហេតុសមស្របនៅពេលដឹកជញ្ជូន ។

**មាត្រា៨៨-** បណ្តឹងសុំជួសជុលការខូចខាត ត្រូវធ្វើក្នុងរយៈពេល ១ ឆ្នាំ គិតពីថ្ងៃដែលម្ចាស់របស់បានដឹងថា បាត់ ឬខូចខាត ឬគិតពីថ្ងៃដែលអ្នកដំណើរបានទទួលរងគ្រោះ ។

## ផ្នែកទី ៦_ កិច្ចសន្យានៃការផ្ញើទុក

**មាត្រា៨៩-** កិច្ចសន្យានៃការផ្ញើទុក ជាកិច្ចសន្យាដែលជនម្នាក់ផ្ញើចលនវត្ថុណាមួយនឹងជនម្នាក់ទៀតឱ្យរក្សាទុក ដោយឥតយកឈ្នួល ឬយកឈ្នួល ហើយឱ្យប្រគល់វត្ថុនោះទៅជនដែលយកមកផ្ញើនោះវិញ ឬប្រគល់ឱ្យជនណាដែលអ្នកផ្ញើប្រាប់ឈ្មោះមកយ៉ាងច្បាស់ តាមពេលដែលសម្មត់ ឬនៅពេលដែលទារយកវត្ថុនោះវិញ ។

**មាត្រា៩០-** តាមគោលការណ៍ បើកិច្ចសន្យាមិនបានចែងអំពីឈ្នួលទេ អ្នកទទួលបញ្ញើមិនត្រូវបានឈ្នួលឡើយ ។

**មាត្រា៩១-** អ្នកទទួលបញ្ញើ ត្រូវរក្សាបញ្ញើឱ្យគង់វង់ ហើយត្រូវប្រគល់ឱ្យវិញនៅពេលដែលបានសន្មត់ ឬនៅពេលដែលអ្នកផ្ញើមកយក ។

អ្នកទទួលបញ្ញើ គ្មានសិទ្ធិយកបញ្ញើទៅប្រើប្រាស់ទេ បើគ្មានការអនុញ្ញាតពីអ្នកផ្ញើ ។

**មាត្រា៩២-** អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវលើការខូចខាត ឬការបាត់បង់នៃបញ្ញើដែលបានកើតឡើងដោយកំហុសរបស់ខ្លួន ។

បើបញ្ញើអន្តរាយ ឬបាត់ដោយករណីប្រធានសក្តិ អ្នកទទួលខុសត្រូវមិនត្រូវសងទេ ។

**មាត្រា៩៣-** បើផ្ញើមានឈ្នួល ហើយបញ្ញើនោះត្រូវអន្តរាយដោយចោរកម្ម អ្នកទទួលបញ្ញើត្រូវសង ។

បើផ្ញើឥតឈ្នួល ហើយបញ្ញើនោះត្រូវអន្តរាយដោយចោរកម្ម អ្នកទទួលបញ្ញើមិនត្រូវសងទេ ប្រសិនបើអ្នកទទួលបញ្ញើមានភស្តុតាងបញ្ជាក់ថា ខ្លួនមានការប្រុងប្រយ័ត្នដែរក្នុងការរក្សាបញ្ញើនោះ ។

ប៉ុន្តែម្ចាស់សណ្ឋាគារ ម្ចាស់ទៀម ម្ចាស់ភោជនាគារ ត្រូវទទួលសងទ្រព្យរបស់ជនទាំងឡាយ ដែលមកស្នាក់អាស្រ័យក្នុងគ្រឹះស្ថានរបស់ខ្លួន បានផ្ញើទ្រព្យនោះក្នុងគ្រឹះស្ថានរបស់ខ្លួន ហើយអន្តរាយដោយចោរកម្ម ។

## ផ្នែកទី ៧_ កិច្ចសន្យានៃការឱ្យខ្ចីប្រើ

**មាត្រា៩៤-** ការឱ្យខ្ចីប្រើ គឺគ្មានយកការប្រាក់ ឬការយកឈ្នួលអ្វីទេ ។ អ្នកដែលឱ្យវត្ថុណាមួយទៅគេខ្ចីប្រើនៅតែជាកម្មសិទ្ធិករនៃវត្ថុនោះដដែល ។

**មាត្រា៩៥-** អ្នកខ្ចីមិនអាចលក់ ឬដូរវត្ថុ ឬឱ្យវត្ថុនោះទៅតតិយជនខ្ចីប្រើដោយគ្មានការព្រមព្រៀងពីអ្នកឱ្យខ្ចីបានឡើយ ។

**មាត្រា៩៦-** អ្នកខ្ចីត្រូវប្រើប្រាស់វត្ថុនោះឱ្យល្អ ថែទាំបីដូចខ្លួនជាម្ចាស់វត្ថុ និងប្រើឱ្យសមស្របនឹងមុខការរបស់វា ។

**មាត្រា៩៧-** បើវត្ថុនោះខូចខាត ឬបាត់ដោយករណីប្រធានសក្តិ អ្នកខ្ចីមិនត្រូវទទួលសងឡើយ ប៉ុន្តែបើការខូចខាត ឬការបាត់បណ្តាលមកពីកំហុសរបស់ខ្លួន អ្នកខ្ចីត្រូវទទួលសងតំលៃវត្ថុទៅឱ្យអ្នកឱ្យខ្ចី ។

**មាត្រា៩៨-** អ្នកខ្ចីត្រូវប្រគល់វត្ថុទៅឱ្យម្ចាស់វត្ថុវិញ នៅពេលដែលបានកំណត់ ។ បើកិច្ចសន្យាគ្មានបានកំណត់យ៉ាងណាទេ អ្នកឱ្យខ្ចីអាចទារយកវត្ថុរបស់ខ្លួនវិញក្នុងពេលណាក៏បាន ។

**មាត្រា៩៩-** បើអ្នកខ្ចីយកវត្ថុទៅប្រើការក្រៅពីមុខការរបស់វា អ្នកឱ្យខ្ចីអាចទារវត្ថុរបស់ខ្លួនភ្លាមវិញបានថ្វីបើមិនទាន់ដល់រយៈពេលកំណត់ ។

## ផ្នែកទី ៨_ កិច្ចសន្យានៃការជួល

**មាត្រា១០០-** ការជួលជាកិច្ចសន្យាដែលអ្នកជួលសន្យាថា និងផ្តល់ទៅឱ្យអ្នកទទួលជួលនៅវត្ថុណាមួយដើម្បីប្រើប្រាស់ជាបណ្តោះអាសន្ន ដោយតំរូវឱ្យគិតថ្លៃនៃការជួលវត្ថុនោះឱ្យអ្នកជួល ។

វត្ថុដែលអាចជួលបាននោះ គឺវត្ថុ ជាអចលនវត្ថុ ឬជាចលនវត្ថុ ។

**មាត្រា១០១-** កិច្ចសន្យានៃការជួល អាចកំណត់ ឬមិនកំណត់ក៏បាននូវរយៈពេលនៃការជួល ក្នុងករណីដែលគ្មានកំណត់រយៈពេលនៃការជួល ចិរវេលានៃកិច្ចសន្យាមានកំណត់ ១២ ឆ្នាំ យ៉ាងយូរ ។

កិច្ចសន្យានៃការជួលដែលមានកំណត់លើសពី ១ ឆ្នាំ ត្រូវធ្វើជាលាយល័ក្ខអក្សរ ។

**មាត្រា១០២-** កាលបើកិច្ចសន្យានៃការជួលបានធ្វើដោយគ្មានសំបុត្រស្នាម ហើយប្រសិនបើភាគីម្ខាងប្រកែកបន្ទាល់នៃការជួលនេះនឹងសំអាងសាក្សីមកបញ្ជាក់បាន លុះណាតែកិច្ចសន្យានៃការជួលនោះ មានកំណត់ត្រឹមតែ ១ ឆ្នាំ ប៉ុណ្ណោះ ។

**មាត្រា១០៣-** អ្នកជួលត្រូវប្រគល់វត្ថុដែលមានភាពនៅល្អឱ្យទៅអ្នកទទួលជួល ត្រូវជៀសវាងនូវអំពើទាំងពួងដែលនាំឱ្យរំខានដល់អ្នកទទួលជួល ហើយត្រូវរ៉ាប់រងដល់អ្នកទទួលជួលអំពីការរំខានទាំងឡាយដែលបណ្ដាលមកពីតតិយជនដែលទាមទារសិទ្ធិណាមួយលើវត្ថុជួលនោះ ដូចជាកម្មសិទ្ធិ ការបញ្ចាំជាដើម ។

**មាត្រា១០៤-** អ្នកជួល ត្រូវទទួលបន្ទុកនូវការជួសជុលធំៗចំពោះវត្ថុជួល លើកលែងតែច្បាប់ ឬកិច្ចសន្យាចែងផ្សេងពីនេះ ។

**មាត្រា១០៥-** អ្នកទទួលត្រូវបង់ប្រាក់ថ្លៃឈ្នួលតាមការកំណត់ ត្រូវប្រើប្រាស់វត្ថុជួលឱ្យសមស្របនឹងមុខការនៃវត្ថុជួល និងតាមការកំណត់នៃកច្ចសន្យា ត្រូវថែទាំវត្ថុនោះឱ្យបានគង់វង់ល្អ ត្រូវទទួលបន្ទុកនូវការជួសជួលបន្តិចបន្តួចដែលជាការជួសជុលជាធម្មតា លើកលែងតែច្បាប់ ឬកិច្ចសន្យាចែងផ្សេងពីនេះ ។

**មាត្រា១០៦-** នៅពេលចប់កិច្ចសន្យា អ្នកទទួលជួលត្រូវប្រគល់ទៅឱ្យអ្នកជួលវិញនូវវត្ថុជួលដែលត្រូវនៅមានសភាពល្អ គឺគ្មានការបាក់បែក គ្មានការខូចខាត ឬគ្មានការកែប្រែនៃវត្ថុនោះដែលបណ្ដាលមកពីអំពើនៃអ្នកទទួលជួល ។

**មាត្រា១០៧-** អ្នកជួលអាចរំលាយកិច្ចសន្យានៃការជួលបាន ប្រសិនបើអ្នកទទួលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឬក៏យកវត្ថុជួលនោះទៅប្រើប្រាស់ខុសអំពីការដែលត្រូវប្រើ ឬក៏ប្រើក្នុងការដែលនាំឱ្យអន្តរាយដល់វត្ថុនោះ ។

**មាត្រា១០៨-** អ្នកទទួលជួលមិនអាចជួលវត្ថុបន្តឱ្យទៅអ្នកដទៃ ដោយគ្មានការអនុញ្ញាតិពីអ្នកជួលឡើយ លើកលែងតែកិច្ចសន្យាចែងផ្ទុយពីនេះ ។

**មាត្រា១០៩-** អ្នកទទួលជួលដែលបានជួលវត្ថុបន្ត ត្រូវនៅជាប់កាតព្វកិច្ចជាមួយនឹងអ្នកជួលដដែល ជាអាទិ៍អ្នកទទួលជួលត្រូវទទួលខុសត្រូវលើអ្នកទទួលជួលពីខ្លួន ចំពោះការមិនបង់ប្រាក់ថ្លៃឈ្នួល ការបែកបាក់ការខូចខាតទាំងឡាយនៃវត្ថុជួល ដែលបណ្ដាលមកពីអំពើរបស់អ្នកទទួលជួលបន្ត ។

**មាត្រា១១០-** ចំពោះកិច្ចសន្យានៃការជួលសំរាប់ថិរវេលាគ្មានកំណត់ គូភាគីអាចនឹងរំលាយបាន លុះណាតែមានការឱ្យដំណឹងមុន ១ ខែ យ៉ាងតិច ឬ ២ ខែ យ៉ាងយូរ ។

**មាត្រា១១១-** ទោះអ្នកជួលស្លាប់ក្តី ក៏កិច្ចសន្យានៃការជួល ត្រូវតែអនុវត្តតទៅទៀត ។

បើអ្នកទទួលជួលស្លាប់វិញ កិច្ចសន្យានៃការជួលនឹងលែងយកមកអនុវត្តបាន លុះណាតែទាយាទលែងចង់ជួលតទៅទៀត ។

## ផ្នែកទី ៩. កិច្ចធានាដោយបុគ្គល

**មាត្រា១១២-** កិច្ចធានាដោយបុគ្គល ជាកិច្ចសន្យាមួយដែលតតីយជនម្នាក់ហៅថា អ្នកធានាសន្យានឹងដើមបំណុលថា ខ្លួនទទួលបំពេញកាតព្វកិច្ចរបស់កូនបំណុលជំនួសកូនបំណុល ប្រសិនបើកូនបំណុលនេះមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះដើមបំណុល ។ កិច្ចសន្យានេះ ត្រូវធ្វើជាលាយល័ក្ខអក្សរ ។

**មាត្រា១១៣-** បំណុលតែមួយ អាចមានអ្នកធានាច្រើនបាន ។

**មាត្រា១១៤-** កិច្ចធានាណាមួយថែងអំពីកាតព្វកិច្ចដែលច្បាប់ទុកជាមោឃៈ កិច្ចធានានោះទុកជាអសាបង់ ។ ប៉ុន្តែបើមោឃភាពនោះមានមូលហេតុមកពី កូនបំណុលជាអនិតិជន កិច្ចធាននោះនៅទុកជាបានការដដែល ។

**មាត្រា១១៥-** ដើមបំណុលអាចប្តឹងពីអ្នកធានាដំណាលគ្នានឹងប្តឹងកូនបំណុលក៏បាន ឬប្តឹងក្រោយក៏បាន ។

**មាត្រា១១៦-** ក្រោយពីមានសាលក្រមរបស់តុលាការប្រជាជន អ្នកធានាអាចទាមទារឱ្យដើមបំណុលអូសទ្រព្យរបស់កូនបំណុលលក់មុនសិន រួចសឹមសំរេចអូសទ្រព្យរបស់ខ្លួនជាក្រោយបាន ។

**មាត្រា១១៧-** បើលក់ទ្រព្យរបស់នៃកូនបំណុលទៅហើយ បានប្រាក់មិនគ្រាន់នឹងសងបំណុលទាំងអស់ទេ អ្នកធានាត្រូវនៅជំពាក់ប្រាក់ដែលនៅខ្វះ ។

**មាត្រា១១៨-** ក្នុងករណីដែលមានអ្នកធានាច្រើននាក់ នោះអ្នកធានាម្នាក់ៗត្រូវជាប់ធានាបំណុលទាំងមូលហាក់ដូចជាអ្នកធានាមានតែម្នាក់ ។ អ្នកធានាទាំងអស់ត្រូវរួបរួមគ្នាសងបំណុលនោះ ។

**មាត្រា១១៩-** បើអ្នកធានាបានសងប្រាក់ជួសកូនបំណុលដែលខ្លួនធានាហើយ សិទ្ធិទាំងប៉ុន្មាននៃដើមបំណុលត្រូវបានទៅអ្នកធានាទាំងអស់ ។ អ្នកធានាមានសិទ្ធិទារឱ្យកូនបំណុលសងប្រាក់ដែលខ្លួនបានសងជួសមកវិញ ព្រមទាំងការប្រាក់ និងសោហ៊ុយបង់ខាតតាំងពីថ្ងៃដែលខ្លួនបានសងជំនួស ។

**មាត្រា១២០-** កាលបើមានអ្នកធានាម្នាក់បានចេញប្រាក់សងជំនួលកូនបំណុល អ្នកធានានោះអាចប្តឹងទារសំណងបានពីអ្នកធានាដទៃទៀតដែលត្រូវសងតាមចំណែករៀង១ខ្លួន ក្នុងករណីកូនបំណុលស្ថិតនៅក្នុងអសាធនភាព ។

## ជំពូកទី៣

## អំពីការទទួលខុសត្រូវក្រៅកិច្ចសន្យា

**មាត្រា១២១-** ជនណាបានធ្វើឱ្យមានការខូចខាតដល់អ្នកដទៃដោយកំហុសរបស់ខ្លួន ជននោះត្រូវជួសជុលការខូចខាតនោះ ។

ទោះបីការខូចខាតកើតមកអំពីអំពើប្រព្រឹត្តិដោយចេតនា ដូចជាការធ្វេសប្រហែស ឬការខ្វះការប្រុងប្រយ័ត្នក្នុងការត្រួតមើល ថែទាំក៏ដោយ ក៏ជនល្មើសត្រូវតែជួសជុលការខូចខាតនោះដែរ ។

**មាត្រា១២២-** ជនវិកលចរិក និងអនីតិជនអាយុតិចជាង ១៤ ឆ្នាំ ជាអសមត្ថជន ។ ជនទាំងនោះមិនត្រូវទទួលខុសត្រូវចំពោះការខូចខាត ដែលខ្លួនបានធ្វើឱ្យកើតឡើងដល់អ្នកដទៃឡើយ ។

**មាត្រា១២៣-** ឪពុក ម្តាយ ឬអ្នកអាណាព្យាបាល ព្រមទាំងជនផ្សេងៗទៀតដែលទទួលបន្ទុកត្រួវមើលថែទាំអសមត្ថជន ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះការខូចខាត ដែលអសមត្ថជននោះបានធ្វើឱ្យកើតឡើង ។

**មាត្រា១២៤-** អនីតិជនអាយុច្រើនជាង ១៤ ឆ្នាំ ប៉ុន្តែមិនទាន់គ្រប់អាយុ ១៨ ឆ្នាំ ត្រូវទទួលការខុសត្រូវចំពោះការខូចខាតដែលខ្លួនបានធ្វើដល់អ្នកដទៃ ។ ការជួសជុលការខូចខាត ត្រូវអនីតិជននោះ និងឪពុកម្តាយ ឬអ្នកអណាព្យាបាលនៃអនីតិជននោះទទួលខុសត្រូវរួម ។ ក្នុងករណីដែលអនីតិជននេះគ្មានប្រាក់ ឬទ្រព្យសម្បត្តិដើម្បីជួសជុលការខូចខាតនោះឪពុកម្តាយ ឬអ្នកអាណាព្យាបាល ត្រូវសងជួស ។

**មាត្រា១២៥-** អង្គការរដ្ឋ អង្គការសង្គម អង្គការសមូហភាព សហគ្រាស ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកម្មាភិបាល បុគ្គលិក កម្មកររបស់ខ្លួន បានធ្វើឱ្យកើតឡើងក្នុងពេល ឬពេលបំពេញភារកិច្ច របស់ជនទាំងនោះ ។

**មាត្រា១២៦-** និយោជក ត្រូវទទួលការខុសត្រូវចំពោះការខូចខាតដល់អ្នកដទៃ បណ្តាលមកពីនិយោជករបស់ខ្លួនក្នុងពេល ឬនៅពេលអនុវត្តការងារដែលនិយោជកបានប្រគល់ឱ្យធ្វើ ។

មាត្រា១២៧- កម្មសិទ្ធិករនៃសត្វ ឬជនដែលប្រើសត្វ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដល់អ្នកដទៃ ដោយសារសត្វដែលនៅក្នុងការគ្រប់គ្រងរបស់ខ្លួន ទោះអន្តរាយនោះកើតឡើងនៅពេលសត្វរត់រួចក្តី ឬនៅពេលសត្វវង្វេងខ្ចាត់ភ្លាត់ក្តី ។

**មាត្រា១២៨-** កម្មសិទ្ធិករ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដល់អ្នកដទៃដោយសារទ្រព្យរបស់ខ្លួន ប្រសិនបើការខូចខាតនោះបណ្តាលមកពីការខ្វះខាតថែទាំ ខ្វះការត្រួតពិនិត្យ ឬក៏ដោយសារសំណង់របស់ខ្លួនសង់មិនបានត្រឹមត្រូវល្អ ។

**មាត្រា១២៩-** ប្រសិនបើការខូចខាតបណ្ដាលមកពីជនប្រព្រឹត្តិបទល្មើសច្រើននាក់ ជនទាំងនោះត្រូវទទួលខុសត្រូវរួមចំពោះជនរងគ្រោះ ។ ក្នុងករណីខ្លះតុលាការប្រជាជនអាចសំរេចសេចក្ដីឱ្យបុគ្គលម្នាក់ៗដែលបានធ្វើឱ្យមានការខូចខាត សងទៅជនរងគ្រោះតាមសមាមាត្រនៃការចូលរួម ប្រព្រឹត្តរបស់ខ្លួន ។

**មាត្រា១៣០-** ជនដែលទទួលខុសត្រូវរួមជាមួយអ្នកទទួលខុសត្រូវឯទៀត ហើយបានសងជំនួសជនទាំងនេះ ជននោះដែលមានសិទ្ធិទាមទារឱ្យជនដែលទទួលខុសត្រូវឯទៀតសងមកខ្លួនវិញ ដោយគិតទៅតាមកំរិតនៃអំពើប្រព្រឹត្តដែលម្នាក់ៗបានប្រព្រឹត្ត ។

**មាត្រា១៣១-** អង្គការ ឬជនដែលបានទទួលខុសត្រូវចំពោះការខូចខាតដែលបណ្ដាលមកពីកំហុសរបស់ជនម្នាក់ទៀត អង្គការ ឬជននោះមានសិទ្ធិប្ដឹងទារសំណងពីជនខាងក្រោយនេះវិញ ។

**មាត្រា១៣២-** ក្នុងករណីដែលការខូចខាត បណ្ដាលមកពីកំហុសរបស់ជនរងគ្រោះផងដែលនោះ ជនរងគ្រោះត្រូវទទួលខុសត្រូវចំពោះចំណែកនៃការខូចខាតនោះ ។

**មាត្រា១៣៣-** ជនដែលធ្វើឱ្យមានការខូចខាតដល់អ្នកដទៃ និងអាចឱ្យរួចខ្លួនពីការទទួលខុសត្រូវបានប្រសិនបើ :

១. ការខូចខាតបានកើតឡើងក្នុងករណីប្រធានសក្តិ ។

២. ការខូចខាតបណ្ដាលមកពីកំហុសទាំងស្រុងរបស់ជនរងគ្រោះ ។

**មាត្រា១៣៤-** ប្រសិនបើការខូចខាតបានកើតឡើងដោយមានការព្រមព្រៀងពីជនរងគ្រោះ ហើយអំពើនោះគ្មានប៉ះពាល់ ឬគំរាមកំហែងដល់ប្រយោជន៍សង្គមទេ នោះមិនត្រូវឱ្យមានការជួសជុលសំណងនៃការខូចខាត ឡើយ ។

**មាត្រា១៣៥-** បណ្ដឹងសុំជួសជុលសំណងនៃការខូចខាត មានអាជ្ញាយុកាលកំណត់ ៣ ឆ្នាំ ។

## ជំពូកទី៤

## អំពីបទបញ្ញត្តិអវសាន

**មាត្រា១៣៦-** កិច្ចសន្យាទាំងឡាយណាដែលកើតឡើងមិនក្រិត្យ-ច្បាប់ ហើយមិនអាចដោះស្រាយតាមក្រិត្យ-ច្បាប់នេះបាន នោះត្រូវដោះស្រាយតាមគោលនយោបាយរបស់បក្ស និងរដ្ឋតាមសមធម៌ ឬតាមទំនៀមទំលាប់និងប្រពៃណី ។

ដំណោះស្រាយនៃកិច្ចសន្យាខាងលើនេះមានកំនត់ ៥ ឆ្នាំ គិតពីថ្ងៃដែលក្រិត្យ-ច្បាប់នេះចូលជាធរមាន ។

**មាត្រា១៣៧-** ក្រុមប្រឹក្សារដ្ឋមន្ត្រី តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល ត្រូវទទួលបន្ទុកអនុវត្តក្រិត្យ-ច្បាប់នេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា១៣៨-** ក្រឹត្យ-ច្បាប់នេះមានអនុភាពតតិយុត្តិចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និងត្រា : ហេង សំរិន

ទទួលបន្ទុកអនុវត្ត

ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា : ហ៊ុន សែន

ដើម្បីចំលងចែក

អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋ

ហត្ថលេខា និងត្រា : ចាន់ វ៉ែន

---

ក្រសួងយុត្តធម៌

លេខ : ............................

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ១៩៩៥

អនុប្រធានមន្ទីរ

# ក្រមរដ្ឋប្បវេណី
# នៃ ព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ២
## ការបង្ហាញឆន្ទៈ និង កិច្ចសន្យា

### ផ្នែកទី ១
### ការបង្កើតកិច្ចសន្យា

**មាត្រា ៣៣៦.–** ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្នើការ

១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្នើការត្រូវគ្នា ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត ។

**មាត្រា ៣៣៧.–** និយមន័យនៃសំណើ និង ស្នើការ

១-សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើង ដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្នើការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ ។

២-សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ ។

៣-ស្នើការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ ។

៤-ស្នើការត្រូវមានអានុភាពនៅពេលដែលស្នើការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្នើការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្នើការដល់ ឬ មុនពេលស្នើការដល់ នោះអានុភាពនៃស្នើការ មិនត្រូវកើតឡើយ ។

**មាត្រា ៣៣៨.–** សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្នើការ និង ការដកសំណើនោះ

១-សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្នើការ ។ អំឡុងពេល

សម្រាប់ស្វីការ ត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ បើមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេង ។

២-សំណើដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសម្រាប់ស្វីការ មិនអាចដកវិញបានទេ ។

៣-ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្វីការ ក្នុងអំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះទេ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិនៅពេលផុតអំឡុងពេលសម្រាប់ស្វីការ ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្វីការនោះ សំណើនោះក៏ត្រូវបាត់បង់អានុភាពដែរ ។

**មាត្រា ៣៣៩.-** សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ

១-ចំពោះសំណើដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការរវាងគូភាគីដែលកំពុងនិយាយគ្នា នៅក្នុងស្ថានភាពដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព ។

២-ចំពោះសំណើដែលធ្វើរវាងគូភាគីដែលមិននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ ។

៣-ការដកសំណើត្រូវមានអានុភាព លុះត្រាតែការជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្វីការ ។

**មាត្រា ៣៤០.-** ពេលនៃការបង្កើតកិច្ចសន្យា : គោលការណ៍នៃការមកដល់នៃស្វីការ

កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលដំណឹងអំពីស្វីការបានមកដល់អ្នកស្នើ ។

**មាត្រា ៣៤១.-** ការមកដល់យឺតយ៉ាវនៃស្វីការ

១-ក្នុងករណីដែលការជូនដំណឹងអំពីស្វីការ ចំពោះសំណើដែលមានអំឡុងពេល

សម្រាប់ស្វីការ មកដល់ភាគីម្ខាងទៀត ក្រោយពេលអំឡុងពេលសម្រាប់ស្វីការនោះកន្លងផុត ប្រសិនបើអ្នកស្នើស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងថា ភាគីម្ខាងទៀតជូនដំណឹងអំពីស្វីការនោះ នៅពេលដែលអាចមកដល់ក្នុងអំឡុងពេលសម្រាប់ស្វីការក្នុងករណីធម្មតា នោះអ្នកស្នើត្រូវជូនដំណឹងអំពីការមកដល់ស្វីការដោយមានការយឺតយ៉ាវនោះ ទៅអ្នកធ្វើស្វីការ ដោយគ្មានការយឺតយ៉ាវ ។ ក្នុងករណីដែលអ្នកស្នើធ្វេសប្រហែសក្នុងការជូនដំណឹងអំពីការមកដល់ស្វីការដោយមានការយឺតយ៉ាវនោះ ស្វីការដែលមកដល់ដោយមានការយឺតយ៉ាវនោះ មានសុពលភាព ។

២-អ្នកស្នើ អាចចាត់ទុកថា ស្វីការដែលបានមកដល់អ្នកស្នើក្រោយពេលផុតអំឡុងពេលសម្រាប់ស្វីការ ជាសំណើថ្មី ។

**មាត្រា ៣៤២.–** ស្វីការដោយមានបន្ថែមការកែប្រែ

១-ស្វីការដែលអ្នកធ្វើស្វីការបានដាក់ល័ក្ខខ័ណ្ឌលើសំណើ ឬ កែប្រែសារធាតុផ្សេងនៃសំណើ មិនត្រូវក្លាយជាស្វីការសុពល តែស្វីការនោះមានអានុភាពជាសំណើថ្មី ។ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើម ធ្វើស្វីការចំពោះសំណើថ្មីនោះ ។

២-ប្រសិនបើល័ក្ខខ័ណ្ឌ ឬ ការកែប្រែដែលភ្ជាប់ជាមួយនឹងស្វីការមិនធ្វើឱ្យមានការកែប្រែសារធាតុនៃសំណើទេ ស្វីការនោះមានសុពលភាព លុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាម ។ អត្ថន័យនៃកិច្ចសន្យាដែលត្រូវកើតឡើងដោយស្វីការនោះ ត្រូវទៅតាមអត្ថន័យនៃស្វីការ លុះត្រាតែអ្នកស្នើដែលបានទទួលស្វីការមិនតវ៉ាភ្លាមៗទេ ។

**មាត្រា ៣៤៣.–** ការបង្កើតកិច្ចសន្យាដោយសកម្មភាពដែលត្រូវបានចាត់ទុកថាជាស្វីការ

ក្នុងករណីដែលមិនចាំបាច់ឱ្យមានដំណឹងអំពីស្វីការ ដោយសារឆន្ទៈរបស់អ្នកស្នើ ឬ ដោយសារទំនៀមទម្លាប់នៃកិច្ចការជំនួញ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលមានសកម្មភាពអាចទទួលស្គាល់ថាជាស្វីការ ។

**មាត្រា ៣៤៤.–** ការដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់

សំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់តាមការផ្សាយជាសាធារណៈ

ឬ តាមវិធីផ្សេងទៀត អាចដកបានតែតាមវិធីដូចគ្នានឹងសំណើនោះ ។

## ផ្នែកទី ២
## វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា

**មាត្រា ៣៤៥.-** ការបង្ហាញឆន្ទៈដែលមានវិការៈ

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ តាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) នេះ និង ផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ :

ក-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ។

ខ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។

គ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ ។

**មាត្រា ៣៤៦.-** ការភាន់ច្រឡំ

១-ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៣-ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៤-ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៧.–** ការឆបោក

១-បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ ។

៣-ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៨.–** ព័ត៌មានមិនពិត

១-នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមាន

វិការៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស ។

៣-ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៩.–** ការរំលោភបំពានលើស្ថានភាព

១-នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ ។

**មាត្រា ៣៥០.–** ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥១.–** អំពើកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយ

បានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥២.–** ឋបនីយផ្លូវចិត្ត

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ។

**មាត្រា ៣៥៣.–** ការបង្ហាញឆន្ទៈមិនពិត

១-កិច្ចសន្យា ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ ។

២-មោឃភាពនៃកិច្ចសន្យាដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬ មិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ ។

**មាត្រា ៣៥៤.–** ភាពខុសច្បាប់ ឬ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ក្នុងអត្ថន័យនៃកិច្ចសន្យា

១-ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈ ក្នុងករណីខាងក្រោមនេះ :

ក-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ។

ខ-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។

២-ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិដែល

អនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងទៀត ក៏មិនធ្វើឱ្យខូចសេចក្តីសង្ឃឹមសមហេតុសមផលរបស់គូភាគីទេ នោះមានតែចំណុចដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អតែប៉ុណ្ណោះទេ ដែលត្រូវទុកជាមោឃៈ ។

**មាត្រា ៣៥៥.-** អលទ្ធភាពតាំងពីដំបូង

១-ទោះបីជាអត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចបានតាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះមិនត្រូវបានចាត់ទុកជាមោឃៈដោយយកមូលហេតុនៃអលទ្ធភាពនោះដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងភាគីក្នុងការលុបចោលនូវកិច្ចសន្យាដោយយកមូលហេតុនៃការភាន់ច្រឡំឡើយ ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំត្រូវបានបំពេញ ។

២-ក្នុងករណីដែលភាគីដែលគួរតែអាចដឹងថា អត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចតាំងពីដំបូងបាន នាំឱ្យមានការខូចខាតដល់ភាគីម្ខាងទៀតដោយសារការបង្កើតកិច្ចសន្យា ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់ភាគីម្ខាងទៀត ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៣៩៨ (ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត) នៃក្រមនេះ ។

## ផ្នែកទី ៣
## មោឃភាព និង ការលុបចោល

**មាត្រា ៣៥៦.-** និយមន័យនៃសកម្មភាព

ពាក្យ “សកម្មភាព” ក្នុងផ្នែកទី ៣ (មោឃភាព និង ការលុបចោល) នេះ សំដៅទៅលើកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី ។

**មាត្រា ៣៥៧.–** អត្ថន័យនៃមោឃភាព

ប្រសិនបើអត្ថន័យនៃសកម្មភាព ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។ ក្នុងករណីដែលសកម្មភាពត្រូវចាត់ទុកជាមោឃៈ ដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារឱ្យមាន ដោយក្រមនេះ ឬ ច្បាប់ផ្សេង ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។

**មាត្រា ៣៥៨.–** សកម្មភាពដែលអាចលុបចោលបាន

១-សកម្មភាពដែលអាចលុបចោលបាន មានសុពលភាព រហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ ។

២-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង ។

៣-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានផ្តល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវមានសុពលភាពជាស្ថាពរ ។

**មាត្រា ៣៥៩.–** អ្នកដែលមានសិទ្ធិលុបចោល

១-ចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈដែលបានកំណត់ ចាប់ពីមាត្រា ៣៤៦ (ការភាន់ច្រឡំ) ដល់មាត្រា ៣៥១ (អំពើកេងយកចំណេញហួសហេតុ) នៃក្រមនេះ អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ អាចលុបចោលនូវសកម្មភាពនោះបាន ។ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

២-ចំពោះការលុបចោល ដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាព ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផ្សេងទៀត សាមីខ្លួន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈនៃជននោះ អាចលុបចោលនូវសកម្មភាពបាន ។ សន្តតិជន ឬ អច្ច័យលាភីសកលរបស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

**មាត្រា ៣៦០.-** វិធីនៃការលុបចោល ឬ សច្ចានុមតិ

ក្នុងករណីដែលភាគីម្ខាងទៀតនៃសកម្មភាពដែលអាចលុបចោលបាន ត្រូវបានកំណត់ច្បាស់លាស់ ការលុបចោល ឬ សច្ចានុមតិត្រូវធ្វើឡើងដោយការជូនដំណឹងទៅភាគីម្ខាងទៀតនោះ ។ អានុភាពនៃការលុបចោល ឬ សច្ចានុមតិ ត្រូវកើតឡើងនៅពេលដែលដំណឹងនោះបានដល់ភាគីម្ខាងទៀតនោះ ។

**មាត្រា ៣៦១.-** អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និង ល័ក្ខខ័ណ្ឌនៃការផ្តល់សច្ចានុមតិ

១-អ្នកមានសិទ្ធិលុបចោល អាចផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន ។ ប៉ុន្តែ ក្នុងករណីដែលលុបចោលសកម្មភាព ដោយយកការបង្ហាញឆន្ទៈដោយមានវិការៈជាមូលហេតុ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោលនោះបានដឹងអំពីមូលហេតុនៃការលុបចោល ។ រីឯសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពវិញ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន នៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវរលត់ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ៣ កថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពផ្តល់សច្ចានុមតិ ។

**មាត្រា ៣៦២.-** សច្ចានុមតិដែលច្បាប់បានកំណត់

នៅក្រោយពេលដែលអាចផ្តល់សច្ចានុមតិតាមបញ្ញត្តិនៃមាត្រា ៣៦១ (អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និង ល័ក្ខខ័ណ្ឌនៃការផ្តល់សច្ចានុមតិ) ខាងលើ សកម្មភាពដែលអាចលុបចោលបាន ត្រូវចាត់ទុកថា បានផ្តល់សច្ចានុមតិរួចហើយ ក្នុងករណីមានហេតុដូចខាងក្រោមនេះ :

ក-ការអនុវត្តកាតព្វកិច្ចទាំងមូល ឬ មួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬ ការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ ។

ខ-ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬ ការ

ទាមទារឱ្យភាគីម្ខាងទៀតអនុវត្ត ។

គ-អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬ មួយផ្នែក ចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើមានថបនីយថា ខ្លួនមិនបានផ្តល់សច្ចានុមតិ នៅពេលដែលហេតុដែលបានកំណត់នៅក្នុងករណីទាំងបីខាងលើនោះ កើតឡើង ។

**មាត្រា ៣៦៣.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល

១-ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេល ៣ (បី) ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ នោះសិទ្ធិលុបចោល និង សិទ្ធិទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារការលុបចោលនោះ ត្រូវរលត់ ។ បញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាលមិនត្រូវយកមកអនុវត្តឡើយ ចំពោះអំឡុងពេលនេះ ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើហួសអំឡុងពេល ១០ (ដប់) ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព នោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ ។

៣-ក្នុងករណីដែលបុគ្គលច្រើននាក់មានសិទ្ធិលុបចោលនូវសកម្មភាពតែមួយ បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះត្រូវយកមកអនុវត្ត ចំពោះសិទ្ធិលុបចោលនៃបុគ្គលនីមួយៗនោះ ។

## ផ្នែកទី ៤
## ការតំណាង

**មាត្រា ៣៦៤.–** និយមន័យនៃការតំណាង

ការតំណាងសំដៅទៅលើទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យាត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែលអ្នកតំណាង ធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀត

ដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះ គឺ ធ្វើសម្រាប់ម្ចាស់សិទ្ធិ ក្នុងទំហំនៃសិទ្ធិតំណាង ។

**មាត្រា ៣៦៥.–** កំណើតនៃសិទ្ធិតំណាង

សិទ្ធិតំណាងកើតមានឡើងដោយកិច្ចសន្យារវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ឬ ដោយបញ្ញត្តិនៃច្បាប់ ។

**មាត្រា ៣៦៦.–** ទំហំនៃសិទ្ធិតំណាង

១-ទំហំនៃសិទ្ធិតំណាងត្រូវកំណត់ដោយកិច្ចសន្យាដែលប្រគល់សិទ្ធិតំណាងទៅឱ្យអ្នកតំណាង ។ ក្នុងករណីដែលសិទ្ធិតំណាងត្រូវកើតឡើងដោយបញ្ញត្តិនៃច្បាប់ ទំហំនៃសិទ្ធិតំណាងក៏ត្រូវកំណត់ដោយច្បាប់នោះដែរ ។

២-ក្នុងករណីដែលទំហំនៃសិទ្ធិតំណាងមិនបានកំណត់ទេ អ្នកតំណាងត្រូវមានសិទ្ធិចំពោះអំពើថែរក្សា និង អំពើកែលំអ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះអំពើកែលំអដែលផ្លាស់ប្តូរលក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃការតំណាង ។

**មាត្រា ៣៦៧.–** ការកម្រិតសិទ្ធិតំណាង

១-ទោះបីក្នុងទំហំនៃសិទ្ធិតំណាងក៏ដោយ ចំពោះអំពើដែលផលប្រយោជន៍របស់អ្នកតំណាង និង របស់ម្ចាស់សិទ្ធិ មានភាពផ្ទុយគ្នា អ្នកតំណាងគ្មានសិទ្ធិទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការយល់ព្រម ពីម្ចាស់សិទ្ធិ ។

២-ចំពោះកិច្ចការជំនួញរវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ត្រូវសន្មតថា ផលប្រយោជន៍ម្ចាស់សិទ្ធិ និង ផលប្រយោជន៍អ្នកតំណាង មានភាពផ្ទុយគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកតំណាង ធ្វើជាតំណាងឱ្យម្ចាស់សិទ្ធិផង ធ្វើជាតំណាងឱ្យតតិយជនផង ហើយផលប្រយោជន៍ម្ចាស់សិទ្ធិ និង ផលប្រយោជន៍តតិយជន មានភាពផ្ទុយគ្នា ។

**មាត្រា ៣៦៨.–** មូលហេតុនៃការរលត់សិទ្ធិតំណាង

១-សិទ្ធិតំណាងដែលបានទទួលពីម្ចាស់សិទ្ធិដោយកិច្ចសន្យា ត្រូវរលត់ដោយសារមូលហេតុខាងក្រោមនេះ :

ក-មរណភាព ធនក្ស័យ ឬ ការរំលាយរបស់ម្ចាស់សិទ្ធិ ។

ខ-មរណភាព ធនក្ស័យ ឬ ការកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អ្នកតំណាង ។

គ-ការបញ្ចប់អាណត្តិ កិច្ចសន្យាការងារ ឬ ទំនាក់ទំនងគតិយុត្តផ្សេងទៀតដែលបានប្រគល់សិទ្ធិតំណាង ។

២-ការតំណាងដែលច្បាប់បានកំណត់ ត្រូវរលត់ដោយសារមូលហេតុដែលបានកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៦៩.–** ការតំណាងដោយគ្មានសិទ្ធិ

១-អំពើដែលអ្នកគ្មានសិទ្ធិតំណាងធ្វើក្នុងនាមជាអ្នកតំណាងរបស់អ្នកដទៃ មិនត្រូវបង្កើតអានុភាពចំពោះម្ចាស់សិទ្ធិទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់សិទ្ធិបានផ្តល់សច្ចានុមតិចំពោះអំពើនោះ ។

២-ភាគីម្ខាងទៀតនៃសកម្មភាពនៃការតំណាងដោយគ្មានសិទ្ធិ មិនអាចអះអាងថាអានុភាពនៃសកម្មភាពត្រូវមាន ចំពោះអ្នកតំណាងដោយគ្មានសិទ្ធិឡើយ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវរារាំងភាគីម្ខាងទៀត ក្នុងការទាមទារឱ្យអ្នកតំណាងដោយគ្មានសិទ្ធិទទួលខុសត្រូវដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៣៧១ (ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ) នៃក្រមនេះ ។

**មាត្រា ៣៧០.–** សច្ចានុមតិចំពោះអំពើតំណាងដោយគ្មានសិទ្ធិ និង សិទ្ធិលុបចោលរបស់ភាគីម្ខាងទៀត

១-ប្រសិនបើមិនបានផ្តល់សច្ចានុមតិចំពោះភាគីម្ខាងទៀតទេ ម្ចាស់សិទ្ធិមិនអាចអះអាងអានុភាពនៃសច្ចានុមតិនោះ ចំពោះភាគីម្ខាងទៀតបានឡើយ ។

២-អំពើតំណាងដោយគ្មានសិទ្ធិ ត្រូវមានសុពលភាពប្រតិសកម្ម ដោយសច្ចានុមតិតាំងពីពេលដែលអំពើនោះ ត្រូវបានធ្វើឡើង ។ ប៉ុន្តែ សច្ចានុមតិនោះមិនអាចធ្វើឱ្យខូចផលប្រយោជន៍តតិយជន ដែលបានកើតឡើងក្នុងអំឡុងពេល ចាប់តាំងពីពេលដែលអំពើតំណាងដោយគ្មានសិទ្ធិនោះត្រូវបានធ្វើឡើង រហូតដល់ពេលផ្តល់សច្ចានុមតិ ។

៣-ភាគីម្ខាងទៀតនៃអំពើតំណាងដោយគ្មានសិទ្ធិ អាចដាស់តឿនឱ្យម្ចាស់សិទ្ធិឆ្លើយអំពីការផ្តល់ ឬ មិនផ្តល់សច្ចានុមតិ ដោយកំណត់អំឡុងពេលមួយសមរម្យដើម្បីឆ្លើយ ។ ប្រសិនបើម្ចាស់សិទ្ធិមិនឆ្លើយក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា ម្ចាស់សិទ្ធិបដិសេធការផ្តល់សច្ចានុមតិ ។

៤-ភាគីម្ខាងទៀតអាចលុបចោលកិច្ចសន្យាដែលត្រូវបានធ្វើដោយអ្នកគ្មានសិទ្ធិតំណាង មុនពេលម្ចាស់សិទ្ធិផ្តល់សច្ចានុមតិបាន ។ នៅក្រោយពេលភាគីម្ខាងទៀតបានលុបចោលកិច្ចសន្យា ម្ចាស់សិទ្ធិមិនអាចផ្តល់សច្ចានុមតិចំពោះអំពើតំណាងដោយគ្មានសិទ្ធិបានឡើយ ។

**មាត្រា ៣៧១.–** ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ

ប្រសិនបើជនដែលធ្វើកិច្ចសន្យាក្នុងនាមជាអ្នកតំណាងសម្រាប់ជនដទៃ មិនអាចបញ្ជាក់នូវសិទ្ធិតំណាង ឬ មិនអាចទទួលសច្ចានុមតិពីសាមីខ្លួនបានទេ ជននោះត្រូវទទួលខុសត្រូវក្នុងការអនុវត្ត ឬ ទទួលខុសត្រូវក្នុងការសងការខូចខាត តាមការជ្រើសរើសរបស់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀតបានដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាង អ្នកតំណាងដោយគ្មានសិទ្ធិអាចរួចផុតពីការទទួលខុសត្រូវនោះបាន ។ អ្នកតំណាងដោយគ្មានសិទ្ធិដែលគ្មានកំហុស ក្នុងការធ្វើអំពើតំណាងដោយគ្មានសិទ្ធិ ក៏អាចរួចផុតពីការទទួលខុសត្រូវដែលបានកំណត់ក្នុងមាត្រានេះបានដែរ ទោះបីជាភាគីម្ខាងទៀតមិនបានដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាង ដោយកំហុសក៏ដោយ ។

**មាត្រា ៣៧២.–** ការតំណាងដែលមានលក្ខណៈជារូបភាព

១-ក្នុងករណីដែលអ្នកតំណាងធ្វើកិច្ចសន្យា ដោយហួសពីទំហំនៃសិទ្ធិតំណាង ប្រសិនបើភាគីម្ខាងទៀតជឿជាក់ថា អ្នកតំណាងមានសិទ្ធិតំណាងចំពោះកិច្ចសន្យានោះ ហើយគ្មានកំហុសក្នុងការជឿនោះទេ ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យានោះ ចំពោះភាគីម្ខាងទៀត ។

២-ក្រោយពីពេលដែលសិទ្ធិតំណាងបានរលត់ ប្រសិនបើភាគីម្ខាងទៀតបានធ្វើកិច្ចសន្យា ជាមួយនឹងអ្នកដែលបង្ហាញខ្លួនថា ជាអ្នកតំណាង ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវ

ក្នុងការអនុវត្តកិច្ចសន្យានោះចំពោះភាគីម្ខាងទៀត ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដឹងអំពីការរលត់នៃសិទ្ធិតំណាងនោះ ឬ មិនដឹងអំពីការរលត់នោះដោយមានកំហុស ។

៣-ក្នុងករណីដែលម្ចាស់សិទ្ធិមិនបានប្រគល់សិទ្ធិតំណាងទៅអ្នកផ្សេង ប៉ុន្តែ ម្ចាស់សិទ្ធិបានបង្ហាញដូចជាខ្លួនបានប្រគល់សិទ្ធិតំណាងនោះទៅឱ្យអ្នកផ្សេង ឬ អនុញ្ញាតឱ្យអ្នកផ្សេងនោះបង្ហាញថា អ្នកនោះមានសិទ្ធិតំណាង ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យាចំពោះភាគីម្ខាងទៀត ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាងនោះ ឬ មិនដឹងអំពីនត្ថិភាពនោះដោយមានកំហុស ។

**មាត្រា ៣៧៣.–** អំពើតំណាងដែលមិនបង្ហាញច្បាស់លាស់

១-ក្នុងករណីដែលអ្នកតំណាងមានឆន្ទៈក្នុងការធ្វើកិច្ចការសម្រាប់ម្ចាស់សិទ្ធិ តែបានធ្វើកិច្ចការនោះ ដោយមិនបង្ហាញថា ធ្វើសម្រាប់ម្ចាស់សិទ្ធិទេ ភាគីម្ខាងទៀតអាចអះអាងថាកិច្ចសន្យាត្រូវបានបង្កើតឡើងជាមួយនឹងអ្នកតំណាងនោះបាន ។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀតបានដឹងនៅពេលបង្កើតកិច្ចសន្យាថា អ្នកតំណាងធ្វើកិច្ចសន្យានោះ សម្រាប់ម្ចាស់សិទ្ធិ ភាគីម្ខាងទៀតនោះអាចអះអាងអំពីការបង្កើតកិច្ចសន្យាតែជាមួយម្ចាស់សិទ្ធិប៉ុណ្ណោះ ។

២-ប្រសិនបើភាគីម្ខាងទៀតបែរជាដឹងអំពីអត្ថិភាពនៃម្ចាស់សិទ្ធិ ក្រោយពេលបង្កើតកិច្ចសន្យាជាមួយនឹងអ្នកតំណាងដែលបានធ្វើកិច្ចការ ដោយមិនបង្ហាញថា ធ្វើសម្រាប់ម្ចាស់សិទ្ធិទេ ភាគីម្ខាងទៀតនោះអាចអះអាងការបង្កើតកិច្ចសន្យា ជាមួយម្ចាស់សិទ្ធិបាន ។

**មាត្រា ៣៧៤.–** វិការៈនៃអំពើតំណាង

១-ក្នុងករណីដែលអានុភាពនៃកិច្ចសន្យាដែលអ្នកបង្ហាញឆន្ទៈបង្កើត ត្រូវទទួលនូវឥទ្ធិពល ដោយសារមានការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង ឬ ដោយសារមានកំហុសក្នុងការដឹង ឬ មិនដឹងហេតុណាមួយ អត្ថិភាព ឬ នត្ថិភាពនៃហេតុនោះ ត្រូវវិនិច្ឆ័យចំពោះអ្នកតំណាង ។

២-ក្នុងការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ បើម្ចាស់សិទ្ធិបានប្រគល់ឱ្យអ្នកតំណាងធ្វើកិច្ចសន្យាដែលត្រូវបានកំណត់ពិសេស ម្ចាស់សិទ្ធិមិនអាចអះអាងថា អ្នកតំណាងមិនបានដឹងនូវហេតុណាដែលម្ចាស់សិទ្ធិដឹងនោះ បានឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាដែរ ចំពោះហេតុដែលម្ចាស់សិទ្ធិមិនបានដឹងដោយមានកំហុស ។

**មាត្រា ៣៧៥.–** សមត្ថភាពនៃអ្នកតំណាង

ម្ចាស់សិទ្ធិក៏អាចប្រគល់សិទ្ធិតំណាងដល់ជនដែលត្រូវបានកម្រិតសមត្ថភាពបានដែរ ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិមិនអាចលុបចោលនូវកិច្ចសន្យាដែលត្រូវបានធ្វើឡើងដោយអ្នកតំណាងដែលជាជនដែលត្រូវបានកម្រិតសមត្ថភាព ជាមួយនឹងភាគីម្ខាងទៀតដោយយកមូលហេតុនៃការកម្រិតសមត្ថភាពរបស់អ្នកតំណាងនោះ បានឡើយ ។

**មាត្រា ៣៧៦.–** អនុតំណាង

អ្នកតំណាងដោយកិច្ចសន្យាជាមួយនឹងម្ចាស់សិទ្ធិ មិនអាចជ្រើសតាំងអនុតំណាងបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានទទួលការយល់ព្រមពីម្ចាស់សិទ្ធិ ឬ មានហេតុដែលជៀសវាងមិនបាន។

**មាត្រា ៣៧៧.–** ការទទួលខុសត្រូវរបស់អ្នកតំណាង ក្នុងករណីដែលបានជ្រើសតាំងអនុតំណាង

១-នៅពេលដែលអ្នកតំណាង បានជ្រើសតាំងអនុតំណាង តាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ មាត្រា ៣៧៦ (អនុតំណាង) ខាងលើ អ្នកតំណាងត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ត្រួតពិនិត្យអនុតំណាងនោះ ចំពោះម្ចាស់សិទ្ធិ ។

២-ក្នុងករណីដែលអ្នកតំណាងបានជ្រើសតាំងអនុតំណាង តាមការកំណត់របស់ម្ចាស់សិទ្ធិ អ្នកតំណាងមិនត្រូវទទួលខុសត្រូវនូវអំពើរបស់អនុតំណាងនោះ លើកលែងតែក្នុងករណីដែលអ្នកតំណាងបានដឹងអំពីភាពមិនសមស្រប ឬ ភាពមិនស្មោះត្រង់របស់អនុ-តំណាង តែមិនបានជូនដំណឹងអំពីភាពនោះទៅម្ចាស់សិទ្ធិ ឬ មិនបានដកអនុតំណាងចេញ ។

៣-ប្រសិនបើអ្នកតំណាងបានជ្រើសតាំងអនុតំណាង ដោយមិនធ្វើតាមបញ្ញត្តិនៃ

វាក្យខណ្ឌទី ២ មាត្រា ៣៧៦ (អនុតំណាង) ខាងលើទេ អំពើរបស់អនុតំណាងគ្មានអានុភាពទៅលើម្ចាស់សិទ្ធិឡើយ ។ ប៉ុន្តែ ភាគីម្ខាងទៀតដែលមិនបានដឹងថា អនុតំណាងនោះគ្មានសិទ្ធិទេ អាចអះអាងនូវការទទួលខុសត្រូវក្នុងការអនុវត្ត ឬ ក្នុងការសងការខូចខាត ចំពោះអ្នកតំណាងបាន បើខ្លួនគ្មានកំហុសក្នុងការមិនបានដឹងនោះ ។

**មាត្រា ៣៧៨.–** ឋានៈនៃអនុតំណាង

១-អំពើដែលអនុតំណាងបានធ្វើក្នុងទំហំនៃសិទ្ធិរបស់ខ្លួន ដោយបញ្ជាក់ថាធ្វើសម្រាប់ម្ចាស់សិទ្ធិ ត្រូវជាចំណងចងម្ចាស់សិទ្ធិ ។

២-អនុតំណាងត្រូវមានសិទ្ធិ និង ករណីយកិច្ចចំពោះម្ចាស់សិទ្ធិ ដូចអ្នកតំណាង ។

៣-បញ្ញត្តិនៃផ្នែកទី ៤ នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និង អនុតំណាង ដោយចាត់ទុកថា អនុតំណាងជាអ្នកតំណាង ។

## ផ្នែកទី ៥
## កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន

**មាត្រា ៣៧៩.–** និយមន័យ

១-ភាគីនៃកិច្ចសន្យា អាចឱ្យតតិយជនទទួលសិទ្ធិដែលកើតឡើងដោយកិច្ចសន្យានោះបាន ។ ក្នុងករណីនេះ អ្នកដែលត្រូវផ្តល់តាវកាលិកទៅតតិយជននោះ ហៅថា “អ្នកព្រមផ្តល់” ។ រីឯភាគីម្ខាងទៀតរបស់អ្នកព្រមផ្តល់នោះ ហៅថា “អ្នកទាមទារការផ្តល់” ។ ម្យ៉ាងទៀត តតិយជនដែលនឹងទទួលតាវកាលិក ហៅថា “អ្នកទទួលផលប្រយោជន៍” ។

២-អ្នកទទួលផលប្រយោជន៍ អាចទាមទារអ្នកព្រមផ្តល់ឱ្យផ្តល់តាវកាលិកដោយចំពោះបាន ។

**មាត្រា ៣៨០.–** អ្នកទទួលផលប្រយោជន៍

នៅពេលធ្វើការសន្យា មិនចាំបាច់មានអត្ថិភាពអ្នកទទួលផលប្រយោជន៍ឡើយ

ប្រសិនបើល័ក្ខខ័ណ្ឌដើម្បីកំណត់អ្នកទទួលផលប្រយោជន៍នោះ មានភាពច្បាស់លាស់ ។ ប៉ុន្តែ ក្នុងករណីដែលគ្មានអ្នកទទួលផលប្រយោជន៍ នៅពេលដែលអ្នកព្រមផ្តល់ត្រូវផ្តល់តាវកាលិក នោះការសន្យាដែលត្រូវផ្តល់តាវកាលិកឱ្យតតិយជន ត្រូវបាត់បង់អានុភាព ហើយអ្នកព្រមផ្តល់ អាចរួចផុតពីការទទួលខុសត្រូវបាន ដោយអនុវត្តចំពោះអ្នកទាមទារការផ្តល់ ។

**មាត្រា ៣៨១.–** ការបង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍

១-ក្នុងអំឡុងពេលដែលអ្នកទទួលផលប្រយោជន៍មិនទាន់បង្ហាញឆន្ទៈទទួលផលប្រយោជន៍ ចំពោះអ្នកព្រមផ្តល់ ឬ អ្នកទាមទារការផ្តល់ អ្នកទាមទារការផ្តល់អាចដកការសន្យាផ្តល់សិទ្ធិឱ្យទៅអ្នកទទួលផលប្រយោជន៍នោះ នៅពេលណាក៏បានដែរ ដោយជូនដំណឹងទៅអ្នកព្រមផ្តល់ និង អ្នកទទួលផលប្រយោជន៍នោះ ។

២-ក្រោយពីអ្នកទទួលផលប្រយោជន៍បានបង្ហាញឆន្ទៈទទួលផលប្រយោជន៍ ភាគីនៃកិច្ចសន្យាមិនអាចប្តូរ ឬ រំលត់នូវសិទ្ធិរបស់អ្នកទទួលផលប្រយោជន៍នេះបានឡើយ ។

**មាត្រា ៣៨២.–** ការតវ៉ារបស់អ្នកព្រមផ្តល់

អ្នកព្រមផ្តល់អាចអះអាងការតវ៉ាដែលកើតមកពីកិច្ចសន្យា ចំពោះអ្នកទទួលផលប្រយោជន៍បាន ។

**មាត្រា ៣៨៣.–** មោឃភាព ការលុបចោល និង ការរំលាយកិច្ចសន្យា

១-ក្នុងករណីដែលកិច្ចសន្យាមានមូលហេតុនៃមោឃភាព ឬ ការលុបចោល រវាងអ្នកទាមទារការផ្តល់ និង អ្នកព្រមផ្តល់ ភាគីនៃកិច្ចសន្យាអាចអះអាងនូវមោឃភាពនៃកិច្ចសន្យា ឬ ការលុបចោលកិច្ចសន្យានោះបាន តាមបញ្ញត្តិស្តីពីមោឃភាព និង ការលុបចោល ក្នុងផ្នែកទី ៣ (មោឃភាព និង ការលុបចោល) នៃជំពូកទី ២ ទោះបីជាមានការសន្យាផ្តល់សិទ្ធិដល់តតិយជនក៏ដោយ ។

២-អ្នកព្រមផ្តល់អាចរំលាយកិច្ចសន្យា ដោយយកមូលហេតុនៃការបំពានកិច្ចសន្យារបស់អ្នកទាមទារការផ្តល់បាន ។ ក្នុងករណីដែលយកការបំពានកិច្ចសន្យារបស់អ្នកព្រម

ផ្តល់មកជាមូលហេតុនៃការរំលាយ បើមានអ្នកទទួលប្រយោជន៍ដែលបានបង្ហាញឆន្ទៈទទួលផលប្រយោជន៍ អ្នកទាមទារការផ្តល់អាចរំលាយកិច្ចសន្យា ដោយទទួលការយល់ព្រមពីតតិយជននោះ ។

## ជំពូកទី ៣
## ការអនុវត្តកិច្ចសន្យា

**មាត្រា ៣៨៤.–** ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច

១-កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

២-ការអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាការសង ដែលនាំឱ្យកាតព្វកិច្ចរលត់ ។

**មាត្រា ៣៨៥.–** សិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឱ្យអនុវត្តកាតព្វកិច្ច

១-ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ម្ចាស់បំណុលមិនអាចទាមទារឱ្យអនុវត្តកាតព្វកិច្ច តាមផ្លូវតុលាការបានឡើយ ក្នុងករណីដែលមានការព្រមព្រៀងគ្នារវាងភាគីនៃកិច្ចសន្យាថា មិនទាមទារឱ្យអនុវត្ត តាមផ្លូវតុលាការ ។

៣-ទោះបីជាមានការកម្រិតនូវសិទ្ធិទាមទារឱ្យអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ ដោយសារមានករណីត្រូវនឹងកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ប្រសិនបើកូនបំណុលបានអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តហើយ ម្ចាស់បំណុលអាចទទួល និង រក្សាទុកនូវតាវកាលិកនេះ ដោយចាត់ទុកថាជាការសងបាន ។

**មាត្រា ៣៨៦.–** ការតវ៉ាឱ្យអនុវត្តព្រមគ្នា

ភាគីនីមួយៗនៃកិច្ចសន្យាអញ្ញមញ្ញអាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន រហូតដល់ពេលដែលភាគីម្ខាងទៀតផ្តល់នូវការអនុវត្តកាតព្វកិច្ច ។ ប៉ុន្តែ បញ្ញត្តិនេះមិន

ត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់ភាគីម្ខាងទៀត មិនទាន់ដល់ពេលកំណត់ដើម្បីអនុវត្ត ។

**មាត្រា ៣៨៧.–** ការតវ៉ាដោយមានការបារម្ភ

ភាគីដែលត្រូវអនុវត្តកាតព្វកិច្ចជាមុន នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ អាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន ក្នុងករណីដែលមានការបារម្ភដែលគួរឱ្យកត់សម្គាល់ថា ភាគីម្ខាងទៀតនឹងមិនអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការផ្សេងទៀត ដើម្បីរំលត់ការបារម្ភនោះ ។

**មាត្រា ៣៨៨.–** ការអនុវត្តតាមបញ្ញត្តិស្តីពីការសង

ក្រៅពីបញ្ញត្តិនៃជំពូកទី ៣ (ការអនុវត្តកិច្ចសន្យា) នេះ បញ្ញត្តិស្តីពីការសងដែលបានកំណត់នៅក្នុងផ្នែកទី ១ (ការសង) នៃជំពូកទី ៧ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តកិច្ចសន្យា ។

# ជំពូកទី ៤
# ការសង្គ្រោះចំពោះការបំពានលើកិច្ចសន្យា

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅស្តីពីការមិនអនុវត្តកាតព្វកិច្ច

**មាត្រា ៣៨៩.–** និយមន័យ និង ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច

ការមិនអនុវត្តកាតព្វកិច្ច សំដៅទៅលើករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យា ។ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច មានដូចខាងក្រោមនេះ :

ក-កូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចឱ្យទាន់ពេលកំណត់ត្រូវអនុវត្ត ដោយសារការយឺតយ៉ាវក្នុងការអនុវត្ត ។

ខ-អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ។

# គំរូកិច្ចសន្យាសំខាន់ៗ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

# <u>កិច្ចសន្យាព្រមព្រៀងជួលដី</u>

**កិច្ចព្រមព្រៀងជួលនេះ ត្រូវបានធ្វើឡើងរវាង:**

១- លោក..........................................កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:..........................................និងភរិយាឈ្មោះ ..........................................កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ..........................................មានអាស័យដ្ឋានលេខ ....................ផ្លូវលេខ....................សង្កាត់ ..........................................ខណ្ឌ..........................................ខេត្ត.......................................... ជាម្ចាស់ដី ដែលមានទីតាំង ស្ថិតនៅ.................................................................................................................... ....................................................................................(ចាប់ពីពេលនេះតទៅ ហៅកាត់ថា **ភាគី"ក"**) ។

**និង**

២- លោក ..........................................ភេទ................

កើតនៅថ្ងៃទី............ខែ............ឆ្នាំ................កាន់លិខិតឆ្លងដែនលេខ..........................................មានអាស័យដ្ឋានលេខ ................  ផ្លូវ...............សង្កាត់ ..........................................ខណ្ឌ..........................................  ខេត្ត.......................................... ជាអ្នកជួលដី (ចាប់ពីពេលនេះតទៅ ហៅកាត់ថា **ភាគី"ខ"**) ។

**ភាគី"ក" និងភាគី"ខ" បានព្រមព្រៀងគ្នាតាមប្រការ និងលក្ខខណ្ឌដូចតទៅ:**

**<u>ប្រការ១:</u>  កិច្ចព្រមព្រៀងជួល**

**ភាគី"ក"** យល់ព្រមជួលដី អោយ **ភាគី"ខ"** ក្នុងរយៈពេល...........................ឆ្នាំ គិតចាប់ពីថ្ងៃទី .................... .ខែ ..................ឆ្នាំ ..................រហូតដល់ថ្ងៃទី..................ខែ..................ឆ្នាំ..................(តទៅនេះហៅកាត់ថា **"រយៈពេលជួល"**) ។

**<u>ប្រការ២:</u>  ថ្លៃឈ្នួលប្រចាំខែ**

ថ្លៃឈ្នួលប្រចាំខែគឺ ...........................USD (..................................ដុល្លារអាមេរិកក្នុងមួយខែ) ក្នុងរយៈពេលជួល ហៅថា ប្រាក់ឈ្នួល **ភាគី"ខ"** ត្រូវបង់ប្រាក់ឈ្នួលទៅអោយ **ភាគី"ក"** នៃដើមខែនីមួយៗនៅរៀងរាល់ខែដោយចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៧ នៃដើមខែនីមួយៗ ។ ប្រសិនបើ **ភាគី"ខ"** ខកខានមិនបានបង់ប្រាក់ឈ្នួលទៅតាមកិច្ចសន្យានេះទេ ប្រាក់កក់ និងត្រូវទុកជាអសារបង់ ហើយចំពោះកិច្ចសន្យាជួលដី ត្រូវទុកជាមោឃៈដោយស្វ័យប្រវត្តិ ។

**ប្រការ៣: ប្រាក់កក់**

**ភាគី "ខ"** បានយល់ព្រមបង់ប្រាក់កក់ជូនទៅ **ភាគី "ក"** ចំនួន .....................USD (.........................................ដុល្លារអាមេរិក) ស្មើនឹងប្រាក់ឈ្នួលប្រចាំខែ ...........ខែ ចាប់ពីពេលនេះតទៅហៅកាត់ថា ប្រាក់កក់ ប្រសិនបើ **ភាគី "ខ"** បញ្ចប់កិច្ចសន្យាជួលមុនកាលកំណត់ជួលនេះ ប្រាក់កក់ត្រូវទុកជាអសារបង់របស់ **ភាគី "ក"** ។ ប៉ុន្តែក្រោយពេលផុតកំណត់រយៈពេលជួល **ភាគី "ក"** ត្រូវបង្វិលប្រាក់កក់ជូន **ភាគី "ខ"** វិញគ្រប់ចំនួន ។

**ប្រការ៤: ការលក់ដី ឬផ្ទេរ**

ប្រសិនបើ **ភាគី "ក"** ធ្វើការលក់ដីខាងលើនេះទៅអោយភាគីណា ឬ ក្រុមហ៊ុនណាមួយផ្សេងនោះ **ភាគី "ក"** និងម្ចាស់កម្មសិទ្ធិថ្មីត្រូវរក្សា និងគោរពតាមគ្រប់លក្ខខណ្ឌនៃកិច្ចសន្យាជួលនៅដដែល រហូតដល់ពេលផុតកំណត់នៃកិច្ចសន្យាជួល ។ **ភាគី "ខ"** មិនត្រូវបានអនុញ្ញាតិអោយធ្វើការផ្ទេរ ឬ ជួលបន្តដីនេះទៅអោយភាគីទី៣ បានឡើយ ។ (អាចជួលបាន) ត្រូវតែជូនដំណឹង និងមានការឯកភាពយល់ព្រមពីសំណាក់ **ភាគី "ក"** ជាមុនសិន ។

**ប្រការ៥: លើប្រាក់ពន្ធ ទឹក ភ្លើង និងសេវាកម្មផ្សេងៗ**

**ភាគី "ខ"** ត្រូវទទួលខុសត្រូវថ្លៃប្រើប្រាស់ ទឹក ភ្លើងអគ្គិសនី សំរាម ទូរស័ព្ទ ទូរទស្សន៍ខ្សែកាប និងការបង់ពន្ធធ្វើអាជីវកម្មនៅលើដីនេះ ។ល។ តាមច្បាប់រដ្ឋដែលបានកំណត់អោយបង់ និងតាមវិក័យប័ត្រដែលក្រុមហ៊ុននីមួយៗបានផ្តល់អោយ ក្នុងកំឡុងពេលនៅកិច្ចសន្យាជួល ។ ប្រសិនបើវិក័យប័ត្រដែលមិនបានបង់ និងត្រូវកាត់យកពីប្រាក់កក់នៅពេលផុតកំណត់រយៈពេលជួល ។

**ប្រការ៦: សុវត្ថិភាពសង្គម និងការថែទាំ**

**ភាគី "ខ"** ត្រូវជួយថែទាំដីនេះក្នុងលក្ខណៈល្អត្រឹមត្រូវ និងមានអនាម័យក្នុងកំឡុងពេលជួល ហើយ **ភាគី "ខ"** មិនត្រូវប្រើប្រាស់ដីនេះ ដើម្បីធ្វើសកម្មភាពផ្ទុយ និងច្បាប់ ឬខុសច្បាប់ផ្សេងៗ ឡើយ ដូចជា: ជួញដូរគ្រឿងញៀន, បើកបន, ឬផ្ទុកអាវុធ ។ល។ ហើយត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះសកម្មភាពរបស់ខ្លួនផ្ទាល់ ។ ករណីអគ្គិភ័យ និងការបង្កជំលោះជាមួយអ្នកជិតខាង និងការបាត់បង់ដែលបង្កឡើងដោយការធ្វេសប្រហែសរបស់ **ភាគី "ខ"** នោះ ជាបន្ទុករបស់ **ភាគី "ខ"** ក្នុងការសងការខូចខាត ។

**ប្រការ៧: ការយល់អំពីកិច្ចសន្យាជួល**

កិច្ចសន្យានេះត្រូវធ្វើឡើងចំនួន ០៣ច្បាប់ ដែលមានខ្លឹមសារ និងសុពលភាពស្មើគ្នា ។ ភាគីទាំងពីរបាន អានគ្រប់ខ្លឹមសារ និងលក្ខខណ្ឌក្នុងកិច្ចសន្យានេះ ហើយភាគីនីមួយៗ ត្រូវគោរពគ្រប់ប្រការតាម លក្ខខណ្ឌនៃកិច្ចសន្យានេះ ។ ប្រសិនបើភាគីណាមួយប្រព្រឹត្តបទល្មើស និងកិច្ចសន្យានេះ ភាគីនោះត្រូវ ទទួលខុសត្រូវចំពោះមុខច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ហើយកិច្ចសន្យានេះ ភាគីនីមួយៗរក្សាទុក ម្នាក់មួយច្បាប់ និងសាក្សីមួយច្បាប់ និងយល់ព្រមផ្តិតមេដៃស្តាំទុកជាភស្តុតាង ។

ធ្វើនៅ, ថ្ងៃទី .............. ខែ.................... ឆ្នាំ ........................

**ស្នាមមេដៃភាគី "ខ"** **សាក្សី** **ស្នាមមេដៃភាគី "ក"**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>កិច្ចសន្យាលក់_ទិញដី_ផ្ទះ</u>**

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ...............................អាយុ...........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............. ចុះថ្ងៃទី..........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ................... ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី"ក" ជាអ្នកទិញ** ................................................ ។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ...............................អាយុ...........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............. ចុះថ្ងៃទី..........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ................... ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី"ខ" ជាអ្នកលក់** ................................................ ។

***ភាគី"ក" និងភាគី"ខ" បានព្រមព្រៀងចុះកិច្ចសន្យាលក់-ទិញ តាមប្រការដូចខាងក្រោម:***

**<u>ប្រការ១:</u> អចលនទ្រព្យ ដី ឬផ្ទះ**

ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យលេខ..................................ចុះថ្ងៃទី.........ខែ..........ឆ្នាំ........... ចេញ ដោយស្ថាប័នមានសមត្ថកិច្ច...................................................................................... ។

**<u>ប្រការ២:</u> អំពីតម្លៃអចលនទ្រព្យ និងការទូទាត់**

ភាគីទាំងពីរបានឯកភាពលើតម្លៃអចលនទ្រព្យ គឺ.....................ដុល្លារ (...........................................) ដែលត្រូវទូទាត់តាមរយៈ តាមសាច់ប្រាក់សុទ្ធ នៅពេលដែល ភាគី"ខ" រៀបចំឯកសាររួចរាល់ផ្តល់ឱ្យភាគី"ក" ចុះថ្ងៃទី.........ខែ.............ឆ្នាំ.............. ។

**<u>ប្រការ៣:</u> ការទទួលខុសត្រូវរបស់ភាគី"ខ"**

ត្រូវបំពេញបែបបទលើឯកសារ (កាត់ឈ្មោះ) នៃអចលនទ្រព្យនេះប្រគល់ឱ្យភាគី"ក" ដោយថ្លៃចំណាយ នៃសេវា ក្នុងកាត់ឈ្មោះនេះជាការទទួលខុសត្រូវរបស់ភាគី"ខ" ។

**<u>ប្រការ៤:</u> ការទទួលខុសត្រូវរបស់ភាគី"ក"**

ភាគី"ក" មានសិទ្ធិកាន់កាប់ឯកសារទៅជំរះបញ្ជីលក់-ទិញ នៅគ្រប់ស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ៥:** កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០៤ច្បាប់ សម្រាប់ភាគី"ក" និងភាគី"ខ" រក្សាទុកចំនួន ០១ច្បាប់ម្នាក់ មេធាវី ០១ច្បាប់ និងតំកល់ទុកនៅឃុំ/សង្កាត់ចំនួន ០១ច្បាប់ ។

**ប្រការ៦:** កិច្ចសន្យានេះធ្វើឡើងរវាងភាគី"ក" និងភាគី"ខ" ដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយកិច្ចសន្យានេះមានសុពលភាពនៅពេលដែលចុះហត្ថលេខា និងផ្ដិតស្នាមមេដៃស្ដាំ ជាភស្ដុតាង ។

ធ្វើនៅ................., ថ្ងៃទី...........ខែ............ឆ្នាំ.............

| **ភាគី"ខ"** | **សាក្សីភាគី"ខ"** | **សាក្សីភាគី"ក"** | **ភាគី"ក"** |
|---|---|---|---|
| ឈ្មោះ........................... | ឈ្មោះ........................... | ឈ្មោះ........................... | ឈ្មោះ........................... |

លេខៈ..................

បានឃើញ និង បញ្ជាក់ថា ស្នាមមេដៃស្ដាំទាំងអស់តាមឈ្មោះរៀងគ្នាខាងលើ ពិតជាបានផ្ដិតនៅចំពោះមុខយើងជាមេឃុំ/ចៅសង្កាត់ តាមខ្លឹមសារនៃកិច្ចសន្យាប្រាកដមែន ។

ធ្វើនៅ..............ថ្ងៃទី...........ខែ............ឆ្នាំ..........

**មេឃុំ/ចៅសង្កាត់** ....................

បានឃើញ និង បញ្ជាក់ថា

ភាគីទាំងពីរបានផ្ដិតមេដៃស្ដាំ ចំពោះមុខមេធាវីប្រាកដមែន ។

ធ្វើនៅ.............ថ្ងៃទី.........ខែ...........ឆ្នាំ..........

**មេធាវី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>លិខិតសងប្រាក់</u>

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ...........................អាយុ..........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ................... ចុះថ្ងៃទី.........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ។

**បានសងប្រាក់ចំនួន**.......................ដុល្លារ (...................................................) នៅថ្ងៃទី............ ខែ............ឆ្នាំ............. ។

ទៅឱ្យឈ្មោះ..............................អាយុ............ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ....................... ចុះថ្ងៃទី...........ខែ..........ឆ្នាំ........... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ។

សងប្រាក់គ្រប់ចំនួន ហើយសូមបញ្ចប់នូវកិច្ចសន្យាទិញ-លក់ដីនិងផ្ទះ ចុះថ្ងៃទី.........ខែ..........ឆ្នាំ............ ចាប់ពីពេលនេះតទៅ ។

**ធ្វើនៅ..............ថ្ងៃទី..........ខែ...........ឆ្នាំ២០.......**

**ស្នាមមេដៃស្តាំសងប្រាក់ សាក្សីអ្នកសងប្រាក់ សាក្សីអ្នកទទួលប្រាក់ ស្នាមមេដៃស្តាំអ្នកទទួលប្រាក់**

ឈ្មោះ........................... ឈ្មោះ........................... ឈ្មោះ........................... ឈ្មោះ...........................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>កិច្ចសន្យាខ្ចីប្រាក់_ដាក់បញ្ចាំ</u>

រវាងខ្ញុំបាទ-នាងខ្ញុំឈ្មោះ............................អាយុ..........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.............
ចុះថ្ងៃទី.........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ...................
ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី"ក" ម្ចាស់ប្រាក់**។

**និង**

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ................................អាយុ...........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.............
ចុះថ្ងៃទី..........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ.............ផ្លូវលេខ........... ក្រុមទី............ភូមិ..................
ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី"ខ" ជាអ្នកខ្ចីប្រាក់**។

***ភាគី"ក" និងភាគី"ខ" បានព្រមព្រៀង តាមប្រការដូចខាងក្រោម:***

**<u>ប្រការ១:</u>** ភាគី"ក" យល់ព្រមឱ្យភាគី"ខ" ខ្ចីប្រាក់ចំនួន......................ដុល្លារ (....................................................)
ភាគី"ខ"បានទទួលចំនួនទឹកប្រាក់នេះ នៅពេលចុះកិច្ចសន្យាចំពោះមុខសាក្សី និងមេធាវី ។

**<u>ប្រការ២:</u>** ភាគី"ខ" យល់ព្រមបង់ការប្រាក់ឱ្យភាគី"ក" ហើយភាគី"ក" យល់ព្រមទទួលការប្រាក់ពី ភាគី"ខ" ក្នុងអត្រាព្រមព្រៀង.............ភាគរយ ក្នុង១ខែ ស្មើនឹង....................(........................................................)
នៃប្រាក់ដែលបានខ្ចី។ រយៈពេល..................................នៃការខ្ចីប្រាក់ គិតចាប់ពីថ្ងៃទី...........ខែ............
ឆ្នាំ.......... រហូតដល់ថ្ងៃទី..........ខែ...........ឆ្នាំ...........។

**<u>ប្រការ៣:</u>** ភាគី"ខ" យល់ព្រមបង់ការប្រាក់ឱ្យ ភាគី"ក" នៅថ្ងៃទី............ដើមខែនិមួយៗ ។ ភាគី"ក" យល់ព្រមឱ្យភាគី"ខ" បង់សងនូវចំនួនទឹកប្រាក់ខ្ចីទាំងអស់ ឬមួយផ្នែកណានោះ នៃកិច្ចសន្យានៅពេលណាក៏បានក្នុងពេលអនុវត្តកិច្ចសន្យានេះ បើកាលណាភាគី"ខ" មានបំណងចង់ចេញសងរួមទាំងប្រាក់ដើមនិងការប្រាក់ផង។ ក្នុងករណីភាគី"ខ" ពុំបានបង់ការក្នុងរយៈពេល**<u>០៣ខែជាប់ៗគ្នានោះ</u>** ភាគី"ខ"យល់ព្រមឱ្យភាគី"ក" ប្រើសិទ្ធិរបស់ខ្លួនក្នុងការបញ្ឈប់ ឬបញ្ចប់កិច្ចសន្យានេះបានដោយឯកតោភាគី ។
ភាគី"ខ"បានយល់ព្រមថា ករណីបង់ការប្រាក់យឺតយ៉ាវរហូតដល់ ០៣ខែ អនុញ្ញាតឱ្យភាគី"ខ" រឹបអូសយកផ្ទះ និងដីដែលបានដាក់បញ្ចាំឱ្យភាគី"ខ" រួចចុះចេញពីផ្ទះ និងដី ដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់ ។

**ប្រការ៤:** យោងកិច្ចសន្យានេះ ដើម្បីធានាដល់ការបំពេញកាតព្វកិច្ចភាគី"ខ"បានដាក់អចលនទ្រព្យធានាមានដូចជា:

| ល.រ | រាយមុខទ្រព្យសម្បត្តិដាក់បញ្ចាំ | ចំនួនច្បាប់ | ផ្សេងៗ |
|---|---|---|---|
| ១ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព: .............................................. ចុះថ្ងៃទី.......ខែ..........ឆ្នាំ.........(ក្រុម/ភូមិ............ឃុំ/សង្កាត់..............) ស្រុក/ខណ្ឌ.........................ខេត្ត/ក្រុង..................................... ។ | | |
| ២ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព: .............................................. ចុះថ្ងៃទី.......ខែ..........ឆ្នាំ.........(ក្រុម/ភូមិ............ឃុំ/សង្កាត់..............) ស្រុក/ខណ្ឌ.........................ខេត្ត/ក្រុង..................................... ។ | | |
| ៣ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព: .............................................. ចុះថ្ងៃទី.......ខែ..........ឆ្នាំ.........(ក្រុម/ភូមិ............ឃុំ/សង្កាត់..............) ស្រុក/ខណ្ឌ.........................ខេត្ត/ក្រុង..................................... ។ | | |

**ប្រការ៥:** កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០៣ច្បាប់ សម្រាប់ភាគី"ក" និងភាគី"ខ" រក្សាទុកចំនួន ០១ច្បាប់ម្នាក់ មេធាវី ០១ច្បាប់ ។

**ប្រការ៦:** កិច្ចសន្យានេះធ្វើឡើងរវាងភាគី"ក" និងភាគី"ខ" ដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយកិច្ចសន្យានេះមានសុពលភាពនៅពេលដែលចុះហត្ថលេខា និងផ្តិតស្នាមមេដៃស្តាំ ជាភស្តុតាង ។

ធ្វើនៅ................., ថ្ងៃទី...........ខែ............ឆ្នាំ.............

**ភាគី"ខ"** **សាក្សីភាគី"ខ"** **សាក្សីភាគី"ក"** **ភាគី"ក"**

ឈ្មោះ........................... ឈ្មោះ........................... ឈ្មោះ........................... ឈ្មោះ...........................

បានឃើញ និង បញ្ជាក់ថា
ភាគីទាំងពីរបានផ្តិតមេដៃស្តាំ ចំពោះមុខមេធាវី
ប្រាកដមែន ។
ធ្វើនៅ,.............ថ្ងៃទី..........ខែ...........ឆ្នាំ..........
**មេធាវី**

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

## <u>កិច្ចព្រមព្រៀងលក់ផ្តាច់ (អចលនៈវត្ថុ)</u>
### <u>ធ្វើឡើងរវាង</u>

លោក...................................អាយុ...........ឆ្នាំ មានទីលំនៅ ភូមិ.............ឃុំ-សង្កាត់....................... ស្រុក-ខណ្ឌ.........................ខេត្ត-ក្រុង..................... លេខទូរស័ព្ទលេខ....................... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.......................... ទូរស័ព្ទលេខៈ.................................... ជាអ្នកទិញដី ( ហៅកាត់ថា **ភាគី"ក"** ) ។

**និង**

លោក...................................អាយុ...........ឆ្នាំ មានទីលំនៅ ភូមិ.............ឃុំ-សង្កាត់....................... ស្រុក-ខណ្ឌ.........................ខេត្ត-ក្រុង..................... លេខទូរស័ព្ទលេខ....................... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.......................... ទូរស័ព្ទលេខៈ.................................... ជាអ្នកទិញដី ( ហៅកាត់ថា **ភាគី"ខ"** ) ។

### <u>*ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោមៈ*</u>

**<u>ប្រការ១ៈ</u>** **ភាគី"ក"** មានដីទំហំ......................ស្ថិតនៅក្នុងភូមិ ....................ស្រុក.............. ខេត្ត................ ក្នុងតំលៃ .......... = ..........ដុល្លារ ( ...............ដុល្លារអាមេរិក) (ក្នុងចំនួនដី ..............ហិកតា) ។ រួមទាំងដើមឈើដែលមានដុះលើដី មានព្រំប្រទល់ៈ

- ខាងជើងទល់នឹង.............................
- ខាងត្បូងទល់នឹង...............................
- ខាងកើតទល់នឹង.............................
- ខាងលិចទល់នឹង...............................

**<u>ប្រការ២ៈ</u>** **ភាគី"ខ"** យល់ព្រមប្រគល់ប្រាក់កក់ចំនួន ៣០% ស្មើនឹង ........................................................ ជាប្រាក់កក់បណ្តោះអាសន្នលើចំណែកលើកទី១ នៃសរុបប្រាក់...................................................... នៅថ្ងៃទី...........ខែ............ឆ្នាំ.............ដើម្បីយកទៅដោះស្រាយការងារផ្សេងៗដែលពាក់ព័ន្ធជាមួយ **ភាគី"ក"** ។

**<u>ប្រការ៣ៈ</u>** **ភាគី"ខ"** យល់ព្រមប្រគល់ប្រាក់កក់ចំនួន ៥០% លើកទី២ ស្មើនឹង ...................................... នៅថ្ងៃទី...........ខែ............ឆ្នាំ............. ដើម្បីមកកាត់ឈ្មោះផ្ទេរសិទ្ធិជូនភាគី"ខ"រួចរាល់ ។

**<u>ប្រការ៣ៈ</u>** **ភាគី"ខ"** ត្រូវប្រគល់ប្រាក់គ្រប់ចំនួននៅពេលដែល **ភាគី"ក"** កាត់ឈ្មោះរួចរាល់ហើយ ត្រូវប្រាក់ដែលនៅចំនួន ២០%ស្មើនឹង.................................... នៃទឹកប្រាក់សរុបទាំង ។

**<u>ប្រការ៤ៈ</u>** **ភាគី"ក"** ក្រោយពីចុះកិច្ចព្រមព្រៀងនេះ និងទទួលប្រាក់កក់ថ្លៃដីរួចហើយ ត្រូវមានកាតព្វកិច្ចដូចខាងក្រោម :

- ត្រូវចេញមុខដោះស្រាយចំពោះមុខច្បាប់ និងចំណាយប្រាក់ដោយខ្លួនឯង ប្រសិនបើមានតតិយជនណាមួយមកតវ៉ាថា ដីលក់ខាងលើនេះ ជាដីរបស់ខ្លួនមិនបានលក់ទេ ។
- ក្នុងករណី**ភាគី"ក"** កែប្រែឈប់លក់វិញ មិនគោរពតាមកិច្ចសន្យានេះ **ភាគី"ក"** ត្រូវសងសងជំងឺចិត្តថ្លៃខាតពេលវេលា និងប្រាក់កក់ឱ្យ **ភាគី"ខ"** ស្មើនឹងប្រាក់កក់ទទួលបានគុណនិង ២ដង ។
- ក្នុងករណី **ភាគី"ខ"** ដែលបានកក់ប្រាក់រួចហើយ ប្រែជាឈប់ទិញដីនោះវិញ ឬ មិនគោរពតាមកិច្ចសន្យាខាងលើប្រាក់កក់ដែលកក់ឱ្យ **ភាគី"ក"** ត្រូវចាត់ទុកជាមោឃៈ ។

**ប្រការ៥:** កិច្ចសន្យានេះធ្វើឡើងចំនួន ០៤ច្បាប់ ភាគី"ក" រក្សាទុកចំនួន ០១ច្បាប់ ភាគី"ខ" ចំនួន ០១ច្បាប់ និងមេធាវីចំនួនខាងសង ០២ច្បាប់ មានតំលៃ និងប្រសិទ្ធិស្មើគ្នា ។

**ប្រការ៦:** ភាគីទាំងពីរក្រោយពីអានកិច្ចសន្យា ហើយឯកភាពតាមខ្លឹមសារ នៃកិច្ចព្រមព្រៀងដូចមានចែងខាងលើទាំងស្រុងហើយ ភាគីទាំងពីរត្រូវផ្តិតមេដៃស្នាំទុកជាចំណាំ និង ទទួលអនុវត្តឱ្យបានល្អត្រឹមត្រូវតាមគោលការណ៍ច្បាប់ ។ ករណីមិនគោរពតាមកិច្ចព្រមព្រៀងនេះ ភាគីដែលមិនគោរពត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

ធ្វើនៅ, ថ្ងៃទី..........ខែ............ឆ្នាំ ២០.......

**ស្នាមមេដៃស្តាំភាគី"ខ"** **ស្នាមមេដៃស្តាំភាគី"ក"**

បានឃើញ និង បញ្ជាក់ថា

គូភាគីទាំងពីរបានផ្តិតមេដៃនៅចំពោះមុខយើង

មេធាវីប្រាកដមែន ។

ធ្វើនៅ, ថ្ងៃទី...........ខែ.............ឆ្នាំ២០....

**មេធាវី**